**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economic


## សារណាបញ្ចប់ការសិក្សា

# ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **ខន មេសា**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

ស្រាវជ្រាវពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **ខន មេសា**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ម៉ម ចាន់ណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ខន មេសា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ក្រុម (L4A5) ជំនាន់ទី ២១ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១ ។ **ជាបឋម ខ្ញុំបាទ សូមលំឱនកាយ ខាចាចិត្តដើម្បីសម្តែងការគោរពដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាល ជ្រៅជាទីបំផុតជូនចំពោះ ៖**

**លោកឪពុក យ៉ាន សុខន អ្នកម្តាយ ហេង សុធិន** ដែលលោកជាអ្នកមានគុណយ៉ាងធំធេង បំផុតកាត់ថ្លៃមិនបានចំពោះកូន រាប់ចាប់ពីលោកទាំងពីរបានផ្តល់កំណើត និងបានផ្គត់ផ្គង់ចិញ្ចឹមបីបាច់ថែរក្សា រូបកូនតាំងពីនៅក្នុងផ្ទៃ រហូតដល់ចម្រើនវ័យពេញរូបរាង ហើយលោកទាំងពីរក៏បានតាមដាន ទូន្មាន អប់រំប្រៀន ប្រដៅ ដាស់តឿន ឱ្យកូនប្រព្រឹត្តតែអំពើល្អ ចេះយកអាសាទៅកាន់មនុស្សជុំវិញខ្លួន មិត្តភក្តិ បងប្អូន ញាតិមិត្ត ទាំងឡាយ។ ម្យ៉ាងវិញទៀតលោកទាំងពីរបានខិតខំធ្វើការទាំងថ្ងៃ ទាំងយប់ ក្តៅ ត្រជាក់ សព្វបែបយ៉ាងដើម្បីក សាងគ្រួសារផ្តល់នូវសេចក្តីសុខសុភមង្គល និងសេចក្តីថ្លៃថ្នូរក្នុងជីវភាពរស់នៅ ហើយលោកបានជួយទំនុក បម្រុងឱ្យកូនបានទៅសិក្សា ដើម្បីទទួលយកចំណេះដឹង និងការអប់រំបន្ថែមដើម្បីឱ្យកូនក្លាយខ្លួន ជាពលរដ្ឋល្អ យុ វជនល្អជាទីពឹងសម្រាប់ខ្លួន និងជាកោសិកាមួយដែលអាចរួមចំណែកកសាង និងអភិវឌ្ឍន៍សង្គមជាតិនាថ្ងៃអ នាគត។ ទាំងនេះគឺជាការផ្តល់ក្តីស្រឡាញ់ដោយស្មោះត្រង់ចេញអំពីសណ្តានចិត្ត ការសណ្តោសប្រណី ថ្នាក់ថ្នម ធ្វើឱ្យកូនមានភាពកក់ក្តៅ និងអាចរស់នៅដោយសេចក្តីថ្លៃថ្នូរ។ គុណូបក្ការៈរបស់លោកទាំងពីរ គឺជាមហា ករុណាទិគុណដ៏ធំធេងដែលកូនមិនអាចកាត់ថ្លៃ និងសងគុណលោកទាំងពីរអស់ឡើយ រឹតតែមិនមានថ្ងៃដែល អាចបំភ្លេចក្នុងមួយជីវិតរបស់កូនបានទៅទៀត ។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន និងសម្តេចគតិព្រឹទ្ធិបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** តាមរយៈ**ឯកឧត្តម ហ៊ុន ម៉ាណែត** ដែលលោកបានអនុញ្ញាតឱ្យខ្ញុំបាទបានទទួលនូវឱកាសសិក្សាតាមរយៈអាហារូបករណ៍ដ៏ថ្លៃថ្លាក្នុងរ យៈពេលពេញ ៤ឆ្នាំកន្លងនេះ ដែលកត្តានេះបានជួយជំរុញ និងសម្រួលនូវកត្តាផ្នែកជីវភាពរបស់ខ្ញុំបាទបានយ៉ាង ច្រើនលើសលុប ពេញមួយកម្មវិធីសិក្សាបរិញ្ញាប័ត្រនីតិសាស្ត្រនេះ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានការិយាល័យស្រាវជ្រាវ និងលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ**គ្រប់រូបនៃ សាកលវិទ្យល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងកំឡុងរយៈពេល ៤ឆ្នាំកន្លងមកនេះ ខ្ញុំបាទ បានទទួលនូវការ អប់រំ ណែនាំ បង្ហាត់បង្រៀន និងការផ្តល់នូវចំណេះដឹងជាច្រើនទាំងការអប់រំចំណេះវិជ្ជាទាក់ទង

ទៅនឹងចំណេះជំនាញ និងជាពិសេសនោះគឺលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិនខ្លាចការនឿយហត់ គឺមានតែខិតខំដាស់តឿនស្មារតីនិស្សិតឱ្យព្យាយាម ស្រាវស្រទេញសិក្សាដើម្បីពង្រឹងសមត្ថភាពឱ្យពេញលេញ ទៅតាមតម្រូវការនៃសង្គមជាតិ និងការស្រាវជ្រាវថ្មីៗ ដើម្បីជួយដល់ការសិក្សាឱ្យកាន់តែមានភាពរីកចម្រើន។ ទាំងនេះគឺ ជាគុណដែលលោកគ្រូ អ្នកគ្រូស្ត្រាចារ្យបានផ្តល់នូវពុទ្ធិ បទពិសោធន៍ការសិក្សា បទពិសោធន៍ការងារ និងទូន្មានប្រៀនប្រដៅឱ្យនិស្សិតទាំងឡាយបានយល់ដឹងពីរបៀបរបប និងការសម្របខ្លួនឱ្យមានភាពសមស្របក្នុងការរស់នៅ និងការបំពេញការងារក្នុងពេលអនាគតផងដែរ។

ជាពិសេសជាងនេះទៅទៀតខ្ញុំបាទ សូមថ្លែងនូវគារវកិច្ច និងថ្លែងអំណរគុណយ៉ាងជូនដល់លោកគ្រូសាស្ត្រាចារ្យ **ម៉ម ចាន់ណៃត** ដែលជាសាស្ត្រាចារ្យណែនាំខ្ញុំបាទនៅក្នុងកិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សានេះ ដែលលោកតែងតែផ្តល់នូវមតិ អនុសាសន៍ ទ្រឹស្តី នៃការអនុវត្តជាក់ស្តែង ក្នុងការស្វែងយល់លើប្រធានបទយ៉ាងយកចិត្តទុកដាក់ ដើម្បីឈានទៅដល់ការទទួលបានភាពជោគជ័យ បើទោះបីជាលោកជាប់រវល់នូវធុរៈការងារផ្ទាល់ខ្លួនក្តី ក៏លោកនូវតែជួយជ្រោមជ្រែងអស់ពីលទ្ធភាពក្នុងការផ្តល់ជាគំនិតយោបល់ និងឯកសារនានាដែលទាក់ទងនឹងប្រធានបទមួយនេះ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់**សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** និងមិត្តនិស្សិតទាំងឡាយ សូមមានសុខភាពល្អ និងបានសម្រេចជោគជ័យគ្រប់ភារកិច្ចការងារ ជៀសផុតពីជម្ងឺដង្កាត់ទាំងឡាយទាំងពួង ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សូមស្វាគមន៍ មិត្តៗ និស្សិត និងប្រិយមិត្តដែលនិយមចូលចិត្តនូវការអានសៀវភៅ ក៏ដូចជាស្វាគមន៍ចំពោះអ្នកដែលចូលចិត្តសិក្សា និងស្រាវជ្រាវនូវឯកសារច្បាប់ទាំងឡាយជាទីគោរពរាប់អាន! ខ្ញុំបាទឈ្មោះ ខន មេសា ជានិស្សិតសិក្សាផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ខ្ញុំបាទពិតជាមាននូវសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលមានឱកាសបានស្រាវជ្រាវ និងរៀបរៀងចងក្រងនូវសារណាមួយនេះឡើង។ ចំណេះដឹងដែលខ្ញុំបាទបានសិក្សារៀនសូត្រ និងស្វែងយល់ជ្រៅជ្រះក្នុងរយៈពេល ៤ឆ្នាំកន្លងមកគឺកើតមកពីការលះបង់ដ៏មានតម្លៃរបស់ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្នុងការអនុញ្ញាតឱ្យខ្ញុំបានក្រេបយកនូវចំណេះដឹង ទ្រឹស្តីដ៏មានភាពច្បាស់លាស់ពីការអនុវត្តផ្លូវច្បាប់កន្លងមកដែលលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យបានជួបប្រទះ និងទូន្មានបន្តគឺពិតជាមានសារៈប្រយោជន៍ជាខ្លាំង និងជាគ្រឹះយ៉ាងរឹងមាំមួយសម្រាប់ខ្ញុំក្នុងនាមជានិស្សិតច្បាប់ ក៏ដូចជានិស្សិតផ្សេងទៀត។ ប្រាកដណាស់ សង្គមមួយនេះត្រូវការជាចាំបាច់នូវការចូលរួមពីសំណាក់ប្រជាពលរដ្ឋដែលមានចំណេះដឹង ជាពិសេសគឺធនធានយុវជនដែលពោរពេញទៅដោយសក្តានុពល ដែលជាចលករក្នុងការកសាងសង្គមមួយឱ្យជួបប្រទះតែនូវការអភិវឌ្ឍន៍ និងភាពរីកចំរើន។

កម្មវិធីសិក្សារយៈពេល ៤ឆ្នាំនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តម្រូវឱ្យខ្ញុំបាទជានិស្សិតម្នាក់ និងជាបេក្ខជនមួយរូបបានទទួលនូវឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាដែលនេះជាកិត្តិយសដ៏ធំធេងរបស់ខ្ញុំដែលជាឱកាសក្នុងស្រាវជ្រាវ និងចែករំលែកចំណេះដឹង និងទស្សនៈតិចតួចដែលខ្ញុំបាទមាន សម្រាប់ការបន្សល់ជាស្នាដៃមុននឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងជាគុណប្រយោជន៍ទៅកាន់អ្នកសិក្សា សិស្ស និស្សិត អ្នកស្រាវជ្រាវសម្រាប់ពេលបច្ចុប្បន្ន និងទៅកាន់ថ្ងៃអនាគត។

គោលបំណងសំខាន់បំផុតនៃការសរសេរប្រធានបទមួយនេះ គឺដើម្បីធ្វើការចែករំលែកនូវចំណេះដឹងដែលបានមកពីការសិក្សា និងការប្រមូលនូវទស្សនៈពីប្រភពផ្សេងៗគ្នា ក្នុងន័យស្វែងយល់នូវចំណុចសំខាន់ពាក់ព័ន្ធទៅនឹងប្រធានបទ **ការញុះញង់ឱ្យប្រព្រឹត្តិបទល្មើស** ដែលជាបញ្ហាចោទឡើងក្នុងសង្គម និងមានភាពសាំញ៉ាំដែលកើតមានឡើងជារឿយៗ ហើយពិតណាស់ថាការញុះញង់នេះគឺពិតជាឧបសគ្គដ៏ស្មុគស្មាញមួយក្នុងការអភិវឌ្ឍន៍សង្គមជាតិ មិនត្រឹមតែប៉ុណ្ណោះរូបភាពនៃការញុះញង់មួយចំនួនក៏អាចជះឥទ្ធិពលខ្លាំងក្លាទៅលើសន្តិសុខ និងសណ្តាប់ធ្នាប់របស់ជាតិ ឬរហូតអាចនាំទៅដល់អំពើហិង្សា និងភ្លើងសង្គ្រាមផងក៏សឹងមាន។ ខ្ញុំយល់ឃើញថា ប្រធានបទ "**ការញុះញង់ឱ្យប្រព្រឹត្តិបទល្មើស**" នេះ ពិតជាមានសារៈសំខាន់ក្នុងជីវភាពរស់នៅ និងការ

ធានាបាននូវសុវត្ថិភាព សណ្ដាប់ធ្នាប់សង្គម ព្រមទាំងសុខសន្តិភាពដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលជាតម្រូវការដ៏ចាំបាច់មិនអាចខ្វះបានទាំងពេលនេះ និងតទៅពេលខាងមុខរហូតដល់អនាគត។

ជាទីបញ្ចប់ ខ្ញុំបាទសូមធ្វើការអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងទាំងឡាយដែលអាចនឹងកើតមានដោយអចេតនានៅក្នុងកិច្ចការស្រាវជ្រាវសារណាបញ្ចប់ការសិក្សានេះទាំងលើផ្នែកអក្ខរាវិរុទ្ធ ពាក្យពេចន៍ ការបកស្រាយ កំហុសឆ្គងវគ្គ-ឃ្លា ក៏ដូចជាការខ្វះខាតនូវអត្ថន័យពុំសមស្របត្រង់ប្រការណាមួយក្តី។ ខ្ញុំបាទពិតជារីករាយក្នុងការទទួលនូវមតិស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ដើម្បីកែប្រែនូវស្នាដៃក្រោយឱ្យកាន់តែមានភាពប្រសើរឡើង។ ខ្ញុំបាទពិតជាសង្ឃឹមយ៉ាងមុតមាំថា លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់មេត្តាយោគយល់ និងអធ្យាស្រ័យដោយក្តីអនុគ្រោះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**……………………………………………………………………………………………៥

**ជំពូកទី១**

**និដ្ឋភាព និងសញ្ញាណទូទៅនៃបទល្មើសញុះញង់ក្នុងច្បាប់ព្រហ្មទណ្ឌចាស់**

**ផ្នែកទី១៖ អំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦**………………..៦

១.១ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស……………………………………………………………...៦

១.២. ការញុះញង់ឱ្យមានការរើសអើង……………………………………………………………៧

**ផ្នែកទី២៖ អំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៩២**……………....៨

១.១ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ……………………………………………………....៨

១.២. ការញុះញង់ឱ្យមានការរើសអើង…………………………………………………………..៩

**ជំពូកទី២**

**សញ្ញាណនៃការផ្តើមគំនិត និងអ្នកប្រព្រឹត្តអំពើញុះញង់**

**ផ្នែកទី១៖ អ្នកផ្តើមគំនិត និងលក្ខខណ្ឌអត្ថិភាពនៃការញុះញង់**……………………………១១

១.១ អ្នកផ្តើមគំនិតដោយការញុះញង់……………………………………………………………...១១

១.២ លក្ខខណ្ឌអត្ថិភាពនៃការញុះញង់…………………………………………………………….១២

**ផ្នែកទី២៖ ចារីនៃអំពើញុះញង់**…………………………………………………………………...១៣

២.១ ចារីជារូបវន្តបុគ្គល…………………………………………………………………………….១៤

២.២ ចារីជានីតិបុគ្គល……………………………………………………………………………….១៥

**ផ្នែកទី៣៖ ភាពខុសគ្នារវាងអ្នកផ្តើមគំនិត និងអ្នកប្រព្រឹត្តអំពើញុះញង់**…………………១៥

៣.១ អ្នកផ្តើមគំនិតដោយការញុះញង់…………………………………………………………...១៦

៣.២ ចារីនៃអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើស……………………………………………………១៧

**ជំពូកទី៣**

**ការញុះញង់ឱ្យប្រព្រឹត្តិបទល្មើស និងការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន**

**ផ្នែកទី១៖ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទញុះញង់ឱ្យមានការរើសអើង**….២០

១.១ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍……………………………………………………២១

១.១.១ និយមន័យ…………………………………………………………………២១

១.១.២ ទោសដែលត្រូវអនុវត្ត……………………………………………..……………២៤
១.២ បទញុះញង់ឱ្យមានការរើសអើង…………………………………………………..…………២៤
១.២.១ និយមន័យនៃការញុះញង់ឱ្យមានការរើសអើង……………………….…………២៥
១.២.២ ទោសដែលត្រូវអនុវត្ត……………………………...………..……………២៧
១.៣. ទោសបន្ថែមដែលអាចប្រកាស…………………………………………………..……២៧
**ផ្នែកទី២៖ ការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន**…………………………………………២៨
២.១. ទំនួលខុសត្រូវរបស់សារព័ត៌មានចំពោះច្បាប់ស្តីពីរបបសារព័ត៌មាន……………………..…២៨
២.២ អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន…………………………………………..…២៩
២.២.១ និយមន័យ……………………………………………………………...….២៩
២.២.២ ការទទួលខុសត្រូវតាមច្បាប់ស្តីពីរបបសារព័ត៌មាន…………………………..…៣០
២.២.៣. ការទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌ……………………………………..…៣១
**ផ្នែកទី៣៖ បទល្មើសញុះញង់ក្នុងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា**...៣២
៣.១ គោលបំណងនៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា……………………...៣២
៣.២ បទល្មើស និងការផ្តន្ទាទោស…………………………………………..……………៣២
**សេចក្តីសន្និដ្ឋាន**…………………………………………………………………………៣៤
**អនុសាសន៍**……………………………………………………………………..………៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងជីវភាពរស់នៅរបស់មនុស្សគ្រប់ជាតិសាសន៍លើសកលលោកយើងនេះ រមែងតែងមាននូវទំនាក់ទំនងរវាងគ្នានឹងគ្នាទៅវិញទៅមក មិនថាក្នុងជីវភាពរស់នៅ ទំនាក់ទំនងផ្នែកនយោបាយ វប្បធម៌ សាសនា ការទូតនោះឡើយ។ សង្គមមួយអាចរីកចំរើន និងអភិវឌ្ឍន៍ជឿនលឿនទៅមុខបាន អាស្រ័យទៅនឹងការស្វែងយល់ សិក្សារៀនសូត្រពីគ្នា ក្នុងសម័យមួយទៅសម័យមួយ ពីជាតិសាសន៍មួយទៅជាតិសាសន៍មួយ ដើម្បីជៀសវាងនូវកត្តានានា ដែលអាចនាំឱ្យមាននូវទំនាស់ ល្អក់កករ ដែលអាចឈានទៅដល់ការខាតប្រយោជន៍ធំតូចទាំងឡាយទាំងពួង។ ពីសម័យដើមមក គេសង្កេតឃើញកត្តារើសអើងជាតិសាសន៍ ពុំសូវបានពិភពលោកចាត់ទុកថាជាបញ្ហាធំដុំឡើយ មិនត្រឹមតែប៉ុណ្ណោះ មនុស្សជាតិត្រូវបានគេបែងចែកវណ្ណៈ ពណ៌សម្បុរ ជាតិពន្ធុ ហើយលក់-ទិញដូចជាទំនិញដែលអាចកាត់ថ្លៃបាន។ ក្រោយមក ការតស៊ូមតិពីសំណាក់ជនដែលត្រូវបានគេរើសអើង ជនដែលត្រូវបានរំលោភបំពានសេរីភាពបានក្រោកឡើងមកជាបន្តបន្ទាប់ ដើម្បីទាមទារនូវសមភាព និងភាពថ្លៃថ្នូរក្នុងសង្គម ហើយចលនានេះត្រូវបានជោគជ័យ សិទ្ធិសេរីភាពត្រូវបានផ្តល់ឱ្យរហូតមកទល់បច្ចុប្បន្ននេះ។

យ៉ាងណាមិញ បើក្រឡេកមកមើលទិដ្ឋភាពជាក់ស្តែងនៅប្រទេសកម្ពុជាយើងវិញ បើទោះបីជាសិទ្ធិសេរីភាពត្រូវបានបើកទូលាយ បិទបញ្ចប់នូវការរើសអើងគ្រប់រូបភាព តែគេក៏នៅតែឃើញម្តងម្កាល ទង្វើដែលមិនគួរគប្បីនេះនៅតែកើតមានឡើង ដែលមួយផ្នែកនៅជិតជាប់នៅក្នុងការគិត និងរបត់នៃការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរមួយចំនួននៅឡើយ ខណៈទង្វើនេះមួយផ្នែកក៏កើតចេញពីការញុះញង់ដោយសារកត្តាមួយចំនួន។ ការញុះញង់នេះ មិនមែនកើតមានឡើងតែនៅលើប្រធានបទនៃពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា ឬនិន្នាការនយោបាយឡើយ ការញុះញង់នេះក៏ត្រូវបានប្រើប្រាស់សម្រាប់ជំរុញឱ្យមាននូវការប្រព្រឹត្តបទល្មើសតូចធំទាំងឡាយ រាប់ចាប់ពីទំនាស់រវាងបុគ្គល និងបុគ្គល ឬរហូតអាចឈានដល់បទល្មើសដែលបណ្តាលឱ្យមាននូវការប៉ះពាល់ធ្ងន់ធ្ងរទៅលើសណ្តាប់ធ្នាប់ និងសុខសុវត្ថិភាពជាតិទាំងមូល។

ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយបែងចែកជា ៦គន្ថី ហើយក្នុងនោះមាន ៣គន្ថីមានចែងអំពីបទល្មើសមានដូចជា បទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនឹងជាតិ ហើយសុទ្ធសឹងតែជាបទល្មើសដែលមានចំណុចសំខាន់ៗ មានសារប្រយោជន៍រៀងគ្នា ដែលគប្បីសិក្សាស្វែងយល់។ បើទោះជាកម្ពុជា មានចែងអំពីបទល្មើសដែលកើតចេញពីការញុះញង់នៅក្នុងក្រមព្រហ្មទណ្ឌដែលមានជាធរមានក៏ដោយ ក៏គេនៅតែមានឃើញនៅការអនុវត្តល្មើសទៅនឹងចំណុចដែលច្បាប់ហាមឃាត់ ហើយបង្កើតឱ្យមាននូវការទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមផ្លូវច្បាប់កើតមាន

ឡើងជាហូរហែរ។ មែនទែនទៅ ការញុះញង់អាចធ្វើឡើងបានតាមច្រើនរូបភាព ហើយបទល្មើសដែលកើតចេញពីការញុះញង់ក៏មានច្រើននៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដូចជា បទញុះញង់ឱ្យបោះបង់ទារក, បទញុះញង់ឱ្យអនីតិជនសេពគ្រឿងស្រវឹង និងបទល្មើសញុះញង់កុំឱ្យឃោធិនស្តាប់បង្គាប់ជាដើម។ យ៉ាងណាក្តី ប្រធានបទដែលយើងនឹងធ្វើការស្រាវជ្រាវនៅក្នុងសារណាបញ្ចប់ការសិក្សានេះ គឺផ្តោតតែទៅលើចំណុច "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" តែប៉ុណ្ណោះ ដែលចំណុចនេះមានចែងនៅក្នុងគន្ថីទី ៤ ពាក់ព័ន្ធទៅនឹងបទល្មើសប្រឆាំងនឹងជាតិ មាតិកាទី១ ការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ ហើយ "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" នេះមាននៅក្នុងផ្នែកទី៣ នៃជំពូកទី៣ ដែលកំណត់អំពីការប៉ះពាល់ដល់សន្តិសុខសាធារណៈ។

នៅក្នុងសារណាបញ្ចប់ការសិក្សានេះ ខ្ញុំបាទនឹងលើកយកនូវចំណុចសំខាន់ៗ ដែលមានចែងនៅក្នុងផ្នែក ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនេះ ដែលជានិច្ចកាល បទល្មើសនេះតែងតែលេចចេញជារូបភាពឡើងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប៉ុន្តែមានការជជែកវែកញែកច្រើនពីសំណាក់មហាជនថា តើការញុះញង់ឱ្យប្រព្រឹត្តបទល្មើសគឺជាអ្វី? តើវាពិតជាការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិពិតមែនឬទេ? តើក្នុងកម្រិតណាមួយដែលគេចាត់ទុកថាជាការបញ្ចេញមតិ ហើយក្នុងកម្រិតណាមួយគេហៅថាជាការញុះញង់ឱ្យប្រព្រឹត្តបទល្មើស? ចំណុចសំខាន់ៗទាំងនេះនឹងត្រូវបកស្រាយនៅក្នុងផ្នែកបន្តបន្ទាប់នៃសារណានេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ សង្គមកម្ពុជាមានការរីកចំរើនឡើងជាលំដាប់ ខណៈមនុស្សម្នាទាំងឡាយ សុទ្ធតែមានការយល់ដឹងខុសៗគ្នា ប៉ុន្តែអ្វីដែលគេឃើញមានជារួមនោះគឺការបំពេញការងារតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបនាសម័យកាលនេះ ដែលគេឱ្យឈ្មោះថាជាបដិវត្តន៍ឧស្សាហកម្ម ៤.០ ជាពិសេសអំឡុងពេលដែលពិភពលោកកំពុងជួបប្រទះនូវវិបត្តិសកលកូវីដ-១៩ ដែលទាមទារឱ្យមនុស្សស្ទើរតែទូទាំងពិភពលោកត្រូវធ្វើការងារ និងជួបប្រជុំជាដើមតាមប្រព័ន្ធអនឡាញ ដែលជារូបភាពសឹងតែមិនធ្លាប់ឃើញពីមុន។ ពីអតីតកាល សម្រាប់ការបញ្ចេញមតិយោបល់ ឬពណ៌នា ចែកចាយរឿងរ៉ាវណាមួយនោះ តោងឱ្យមាននូវការស្វះស្វែងរកនូវសមាជ ការជួបប្រជុំផ្ទាល់ ឬការចុះផ្សាយតាមសារព័ត៌មានជាដើម-ល- ហើយបទល្មើសញុះញង់ក៏គេកម្រឃើញថានឹងកើតមានឡើងក្នុងជីវភាពរស់នៅដែរ។ ប៉ុន្តែបច្ចុប្បន្ននេះខុសពីគ្រាមុន ទូរស័ព្ទទំនើប ឧបករណ៍បច្ចេកវិទ្យាកម្រិតខ្ពស់គ្រប់គ្នាសុទ្ធតែអាចក្លាយជាអ្នកបញ្ចេញមតិ ជាអ្នកចែកចាយព័ត៌មាន ប៉ុន្តែទន្ទឹមនឹងភាពងាយស្រួលនេះ គេក៏សង្កេតឃើញរូបភាពនៃបទល្មើសក៏កើតមានឡើងជាបន្តបន្ទាប់ បូករួមទាំងបទល្មើសកើតពីការញុះញង់នេះផងដែរ។ តើការញុះញង់អាចកើតមានឡើងក្នុងលក្ខខណ្ឌបែបណា? ត្រូវផ្តន្ទាទោសកម្រិតណា? យើងនឹងលើក

ឡើងក្នុងសារណានេះ រួមបញ្ចូលជាមួយនឹងបទដ្ឋានគតិយុត្តិដែលនឹងចូលជាធរមាននាពេលខាងមុខនេះ ក្នុងគោលបំណងបង្ការនូវបទល្មើសញុះញង់ក្នុងរូបភាពថ្មីលើសម័យកាលបច្ចេកវិទ្យាផងដែរ។

### ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណង និងហេតុផលនៃការស្រាវជ្រាវប្រធានបទ "**ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនេះ**" ក្នុងគោលដៅស្វែងយល់អំពីបទល្មើសញុះញង់ដែលធ្លាប់មាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល សញ្ញាណនៃបទល្មើសនៃការញុះញង់ ភាពខុសគ្នារវាងអ្នកផ្តើមគំនិតញុះញង់ និងអ្នកប្រព្រឹត្តអំពើផ្ទាល់ ក៏ដូចជាលក្ខខណ្ឌអត្ថិភាពនៃការញុះញង់ រួមទាំងបទល្មើសកើតចេញពីការញុះញង់ និងការផ្តន្ទាទោសតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងកិច្ចការស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទនេះ ខ្ញុំបាទក៏មានគោលបំណងក្នុងការសិក្សាស្វែងយល់ទៅលើបទល្មើសញុះញង់ប្រព្រឹត្តិតាមផ្លូវសារព័ត៌មាន ក៏ដូចជាការញុះញង់ និងការផ្តន្ទាទោសចំពោះអំពើទាំងនេះដែលមាននៅក្នុងសេចក្តីព្រាងនៃច្បាប់ឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា ដែលច្បាប់នេះក៏ទំនងជានឹងចូលជាធរមាននាពេលឆាប់ៗខាងមុខ ដោយផ្អែកទៅលើស្ថានភាពជាក់ស្តែង និងតម្រូវការចាំបាច់ក្នុងសង្គមកម្ពុជា ដែលកំពុងមានការរីកចំរើនចំពោះការវិវត្តន៍ទៅបច្ចេកវិទ្យា និងចំនួនអ្នកប្រើប្រាស់សេវាកម្មបច្ចេកវិទ្យា ព្រមទាំងបណ្តាញសង្គមមានការកើនឡើងយ៉ាងគំហុកក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅចុងបញ្ចប់នៅកិច្ចការស្រាវជ្រាវនេះ ខ្ញុំបានក៏បានធ្វើនូវសេចក្តីសន្និដ្ឋាន និងមានជាមតិយោបល់មួយចំនួនលើកឡើងអំពីតម្រូវការសំខាន់ៗមួយដើម្បីកែលម្អទៅលើចំណុចនៃការសិក្សាស្រាវជ្រាវនេះផងដែរ។

### ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដូចដែលបានបញ្ជាក់ជូនពីខាងដើម នៅក្នុងប្រធានបទនេះ ខ្ញុំបាទនឹងធ្វើការស្រាវជ្រាវ និងបកស្រាយតែសញ្ញាណនៃបទល្មើសញុះញង់ ទាំងច្បាប់អន្តរកាល និងក្រមព្រហ្មទណ្ឌជាធរមាននាពេលបច្ចុប្បន្ន និងអំពីចំណុច "ការញុះញង់ឱ្យប្រព្រឹត្តិបទល្មើស" ដែលមានចែងចាប់ពីមាត្រា ៤៩៤ រហូតដល់មាត្រា ៤៩៨ ព្រមទាំងផ្នែកដែលពាក់ព័ន្ធខ្លះៗទៅនឹងច្បាបស្តីពីរបបសារព័ត៌មាន និងពាក់ព័ន្ធខ្លះៗក្នុងសេចក្តីព្រាងនៃច្បាប់ឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យាប៉ុណ្ណោះ ដែលគេរំពឹងថានឹងអាចចូលជាធរមានឆាប់ៗនាពេលខាងមុខ ត្បិតយោងទៅលើតម្រូវការជាក់ស្តែង និងការរីកចំរើនខ្លាំងនៃបច្ចេកវិទ្យារបស់មនុស្សក្នុងសតវត្សថ្មីនេះ។

### ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំណុចសំខាន់ដំបូងបង្អស់ដែលជម្រុញឱ្យខ្ញុំនឹកភ្នក និងផុសចេញនូវគំនិតនៃការស្រាវជ្រាវនូវប្រធានបទនេះឡើង ត្បិតប្រធានបទនេះហាក់មានភាពផុសផុលក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ដែលជានិច្ចកាល

តែងតែមាននូវការភ័ន្តច្រឡំទៅលើបទល្មើសនេះ រហូតបង្កឱ្យមាននូវការចោទប្រកាន់ និងផ្តន្ទាទោសដោយតុលាការជាហូរហែរ។ ក្រោមដំបូលសន្តិភាព សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋត្រូវបានផ្តល់ឱ្យពេញទី និងការពារដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ ក៏ដូចជាសន្ធិសញ្ញា កតិកាសញ្ញា និងលិខិតបទដ្ឋានគតិយុត្តិដទៃទៀត ដែលកម្ពុជាបានចុះហត្ថលេខាផ្តល់សច្ចាប័នដើម្បីគោរព និងអនុវត្តតាម។ ប្រធានបទនេះ នឹងធ្វើការពន្យល់ និងបកស្រាយពាក់ព័ន្ធទៅនឹងចំណុចនៃបទល្មើសញុះញង់នេះ បើទោះជាមិនបានទូលំទូលាយពិស្តារក្តី តែខ្ញុំរំពឹងថាកិច្ចការនេះនឹងជាផ្នែកមួយដែលនឹងផ្តល់ជាពុទ្ធិក្នុងការពិចារណា ជាពិសេសសម្រាប់ប្រជាពលរដ្ឋទូទៅដែលមានបំណងចង់ស្វែងយល់អំពីច្បាប់ ដែលពួកគាត់នឹងអាចត្រិះរិះឱ្យកាន់តែលម្អិតបន្ថែមទៀត អំពីសិទ្ធិសេរីភាពរបស់ខ្លួនក្នុងដែនកំណត់មួយ ដែលមិនហួសចូលទៅដល់បទល្មើស ឬការចោទប្រកាន់ណាមួយឡើយ។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីជាយានជំរុញឱ្យការស្រាវជ្រាវនេះមានភាពល្អប្រសើរ និងទទួលបានជោគជ័យ ពិតប្រាកដណាស់គឺទាមទារឱ្យមាននូវការសិក្សាស្រាវជ្រាវទៅលើឯកសារពាក់ព័ន្ធជាច្រើន ជាពិសេសទៅលើការប្រមូលព័ត៌មានដែលពាក់ព័ន្ធ សម្រាប់ធ្វើជាគោលគំនិត និងជាមូលដ្ឋានសម្រាប់រួមចំណែកក្នុងប្រធានបទខាងលើនេះ។ ការសិក្សាស្រាវជ្រាវនេះត្រូវបានចងក្រងដោយផ្អែកលើការប្រមូលពីប្រភពឯកសារពីរប្រភេទគឺ ឯកសារចំបង និងឯកសារបន្ទាប់បន្សំ។ ក្នុងលទ្ធភាពសិក្សាស្រាវជ្រាវជាក់ស្តែង ជាពិសេសក្នុងបរិបទនៃការរាតត្បាតជាសកលនៃវីរុសកូវីដ-១៩ កិច្ចការស្រាវជ្រាវនេះពុំអំណោយផលដល់ការចុះសាកសួរផ្ទាល់ពីភាគីពាក់ព័ន្ធ ឬការធ្វើដំណើរការប្រមូលទិន្នន័យពីបណ្ណាល័យ ឬទីតាំងនានានោះទេ នាំឱ្យខ្ញុំបាទប្រមូលបាននូវប្រភពព័ត៌មានដូចខាងក្រោម៖

- **ឯកសារចំបង**
  - ឯកសារដែលបានមកពី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
  - ឯកសារដែលបានមកពី ច្បាប់ព្រហ្មទណ្ឌ(អន្តរកាល) ឆ្នាំ ១៩៥៦
  - ឯកសារដែលបានមកពី ច្បាប់ព្រហ្មទណ្ឌ(អន្តរកាល) ឆ្នាំ ១៩៩២
  - ឯកសារដែលបានមកពី ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
  - ច្បាប់ស្តីពីរបបសារព័ត៌មាន
  - សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា
- **ឯកសារបន្ទាប់បន្សំ**
  - ឯកសារដែលបានមកពី សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ

- ឯកសារដែលបានមកពីសៀវភៅដែលបានមកពី ការណែនាំរបស់សាស្ត្រាចារ្យណែនាំ
- ឯកសារដែលបានមកពីសៀវភៅដែលបានមកពី សៀវភៅច្បាប់នានា
- ឯកសារដែលបានមកពីសៀវភៅដែលបានមកពី មេរៀនដែលធ្លាប់បានសិក្សាកន្លងមក
- ឯកសារដែលបានមកពីសៀវភៅដែលបានមកពី ការស្រាវជ្រាវលើប្រព័ន្ធអ៊ីនធ័រណេត
- ឯកសារដែលបានមកពីសៀវភៅដែលបានមកពី សិស្សច្បង និងមិត្តរួមជំនាន់ជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះត្រូវបានបែងចែកចេញជា ៣ ជំពូកធំៗដូចជា៖

- សេចក្តីផ្តើម
- **ជំពូកទី១ ទិដ្ឋភាព និងសញ្ញាណទូទៅនៃបទល្មើសញុះញង់ក្នុងច្បាប់ព្រហ្មទណ្ឌចាស់**
- **ជំពូកទី២ សញ្ញាណនៃការផ្តើមគំនិត និងអ្នកប្រព្រឹត្តអំពើញុះញង់**
- **ជំពូកទី៣ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស និងការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន**
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង

# ជំពូកទី១

## និដ្ឋភាព និងសញ្ញាណទូទៅ

## នៃបទល្មើសញុះញង់ក្នុងច្បាប់ព្រហ្មទណ្ឌចាស់

# ជំពូកទី១

# ទិដ្ឋភាព និងសញ្ញាណទូទៅនៃបទល្មើសញុះញង់ក្នុងច្បាប់ព្រហ្មទណ្ឌចាស់

## ផ្នែកទី១៖ អំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៥៦

ប្រទេសកម្ពុជា ទើបតែបានអនុម័តឱ្យប្រើប្រាស់នូវក្រមព្រហ្មទណ្ឌថ្មី នាខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅប៉ុណ្ណោះ ហើយបើគិតទៅក្រោយឡើងវិញ ក្រមព្រហ្មទណ្ឌរបស់កម្ពុជា នៅមានអាយុកាលក្មេងខ្ចីនៅឡើយ ពោលគឺមានអាយុកាលប្រមាណជា ១២ឆ្នាំប៉ុណ្ណោះ ហើយបើប្រៀបធៀបទៅនឹងបណ្តាប្រទេសជិតខាងកម្ពុជា ដូចជាប្រទេសថៃ បានបង្កើតឱ្យមានច្បាប់ព្រហ្មទណ្ឌតាំងពីឆ្នាំ១៩៥៦ ដោយឡែក ម៉ាឡេស៊ី បានបង្កើតច្បាប់ព្រហ្មទណ្ឌតាំងពីឆ្នាំ ១៩៣៦ និងបានវិសោធនកម្មកែប្រែបន្ថែមតាំងពីឆ្នាំ១៩៩៧។ ប៉ុន្តែកាលពីអតីតកាលប្រទេសកម្ពុជាក៏ធ្លាប់មាននូវក្រមព្រហ្មទណ្ឌរបស់ខ្លួនកន្លងមកដែរ រួមមានដូចជា ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ និង ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៩២។ ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាន ៥គន្ថី និង ៥៤០មាត្រា[1] ដោយនៅក្នុងច្បាប់អន្តរកាលនេះក៏បានបញ្ញត្តិអំពីបទល្មើស ដែលមានលក្ខណៈស្រដៀងទៅនឹងអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើស ដែលជាចំណុចសំខាន់ និងជាស្នូលនៃប្រធានបទស្រាវជ្រាវនេះផងដែរ។ បទល្មើសញុះញង់មានចែងក្នុងមាត្រា ២៩៩ និងមាត្រា ៣០០។ បន្តទៅទៀតនេះ យើងនឹងស្វែងយល់អំពីទិដ្ឋទូទៅនៃបទល្មើសញុះញង់ ដែលមានក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលធ្លាប់មានក្នុងប្រព័ន្ធនីតិខ្មែរ និងធ្លាប់បានអនុវត្តនាពេលកន្លងមក។

### ១.១ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

តាមពិតទៅ មាត្រានេះច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦ បានហៅថាជាអំពើបញ្ចូលចិត្តឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងមជ្ឈិម ប៉ុន្តែដើម្បីឱ្យមានភាពងាយស្រួលក្នុងការប្រៀបធៀបមកទិដ្ឋភាពច្បាប់នាពេលបច្ចុប្បន្ន ខ្ញុំបាទបានដាក់ចំណងជើងចំណុចនេះថាជាការញុះញង់ឱ្យប្រព្រឹត្តបទល្មើសវិញ ត្បិតវាមាត្រាទាំងពីរនេះមានភាពស្រដៀងគ្នា។ មាត្រានេះចែងថា ជនណាបង្កហេតុ ឬបំណងនឹងបង្កហេតុ នៅមុខប្រជាជន ដោយវាចា ដោយលាយលក្ខណ៍អក្សរ, ដោយគំនូរ, រូប ឬទស្សនីយភាព, ទោះបី គ្រឿងប្រដាប់សម្រាប់មើល ឬសម្រាប់ស្តាប់ដែលយកមកប្រើដល់ការឃោសនាដល់ប្រជាជននោះ មានធុនដូចម្តេចក្តី, ទោះបីភាសាដែលប្រើនោះជាភាសាជាតិណាៗក្តី ដើម្បីឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទោសកម្ម ជននោះត្រូវចាត់ទុកជាអ្នកសមគំនិត ក្នុងឧក្រិដ្ឋកម្ម ឬទោសកម្មនោះ ប្រសិនបើបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តរួចហើយ ឬមានបំណងនឹងប្រព្រឹត្តពិតមែន។ បើការបង្កហេតុនេះគ្មានបានផលសោះទេ វិរុទ្ធជនត្រូវមានទោសមជ្ឈិម ថ្នាក់ទីពីរ។ បើពិនិត្យលើកថាខណ្ឌទី១នេះគេសង្កេតឃើញថា ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មិនបាននិយាយពីការញុះញង់ទេ ប៉ុន្តែនៅក្នុងច្បាប់នេះ នីតិនិពន្ធ

[1] ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦

ខ្មែរពីដើមគេបានប្រើពាក្យបង្កហេតុវិញ។ យ៉ាងណាក្តី នៅក្នុងមាត្រានេះ គេក៏បានបញ្ជាក់បន្ថែមក្នុងកថាខណ្ឌទី ២ផងដែរថា ការបង្កហេតុ គឺជាការញុះញង់ដោយផ្ទាល់ ឬដោយមិនផ្ទាល់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទោសកម្ម, ដោយបញ្ជោរ ឬចាក់ដើងជនដែលបានប្រព្រឹត្ត ឬបំណងនឹងប្រព្រឹត្តនូវអំពើល្មើសនោះជាដើម[2]។

ច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦នេះ ក៏បានចែងអំពីទោសប្បញ្ញត្តិនៃបទល្មើសនេះស្រាប់តែម្តង ពោលគឺ ប្រសិនបើការបង្កហេតុ (ការញុះញង់) នេះបានសម្រេចផល ត្រូវចាត់ទុកជាអ្នកសមគំនិតនៃអំពើនោះតែម្តង ប៉ុន្តែ ប្រសិនបើការបង្កហេតុនោះ គ្មានបានផលសោះទេ (គ្មានប្រសិទ្ធិភាព) ជននោះក៏ត្រូវផ្តន្ទាទោសមជ្ឈិម ថ្នាក់ទីពីរ ផងដែរ។ ទោសមជ្ឈិម ថ្នាក់ទីពីរត្រង់នេះមានន័យថា គឺជាទោសដាក់ពន្ធនាគាររយៈពេល ១ខែ ទៅ ១ឆ្នាំ និងការ ពិន័យជាប្រាក់ចាប់ពី ១២០១រៀល ទៅ ៤០០០រៀល[3] ដែលទោសទាំងពីរនេះតុលាការអាចធ្វើការប្រកាសទោស ណាមួយ ឬអាចត្រូវប្រកាសផ្តន្ទាទោសទាំងពីរតែម្តង។

### ១.២ ការញុះញង់ឱ្យមានការរើសអើង

ចំណុចបន្តទៀតនេះ យើងនឹងបន្តសិក្សាទៅលើអំពើមួយទៀត ដែលមានសញ្ញាណមួយផ្នែក ស្រដៀង ទៅនឹងការញុះញង់ឱ្យមានការរើសអើងនៅក្នុងច្បាប់ព្រហ្មទណ្ឌនាពេលបច្ចុប្បន្ននេះដែរ។ ជនណាបានផ្សាយ ដោយប្រើមធ្យោបាយណាមួយ បណ្តាមធ្យោបាយទាំងឡាយដូចដែលមានសំដែងក្នុងមាត្រា ២៩៩ (ដូចដែល បានបកស្រាយក្នុងចំណុចនៃការញុះញង់ឱ្យប្រព្រឹត្តបទល្មើសខាងលើ) ជាភាសាអ្វីក៏ដោយ នូវវិទ្ធង្សនាដែលមាន គោលបំណងជាប្រត្យក្សថានឹង អុចអាលឱ្យស្អប់ ឬឱ្យមើលងាយរវាងរាស្ត្រ និងអ្នករាជការក្តី, រវាងវណ្ណៈក្តី, រវាង ពួក និងធន់នៃពលរដ្ឋ នឹងពួក និងធន់នៃពលរដ្ឋក្តី, រវាងតំបន់មួយ នឹងតំបន់មួយនៃប្រទេសកម្ពុជាក្តី, រវាង សាសនា និងសាសនាដែលរដ្ឋាភិបាលទទួលស្គាល់ក្តី ឬប្រឆាំងនឹងសាសនាណាមួយ បណ្តាសាសនា ទាំងឡាយនោះក្តី ជននោះត្រូវផ្តន្ទាទោសឧក្រិដ្ឋថ្នាក់ទីមួយ ហើយទោសនេះក៏មិនមែនជាឧបសគ្គឱ្យខានអនុវត្ត ទោសធ្ងន់ជាងនេះទៅទៀតទេ ប្រសិនបើមានការណ៍ត្រូវអនុវត្ត[4]។

នេះគឺជាការដកស្រង់ផ្នែកដែលពាក់ព័ន្ធទៅនឹងការញុះញង់ឱ្យមានការរើសអើង ដែលមានចែងក្នុង មាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦។ ដូចដែលបានបង្ហាញជូនខាងលើនេះ ច្បាប់ពីសម័យអតីតកាលក្តី ក៏មានចរិតលក្ខណៈក្នុងការបង្ការនូវទង្វើដែលនាំឱ្យមានការរឹកវរក្នុងសង្គម តាមរយៈរូបភាពនៃការរើសអើងគ្រប់ ទម្រង់ផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ច្បាប់បានប្បញ្ញត្តិនូវការផ្តន្ទាទោសមានលក្ខណៈធ្ងន់ធ្ងរដែលចាត់ចូលជាបទ ឧក្រិដ្ឋថ្នាក់ទីមួយតែម្តង សម្រាប់ជនណាដែលបានប្រព្រឹត្តអំពើខាងលើនេះ។ បទឧក្រិដ្ឋថ្នាក់ទីមួយក្នុងច្បាប់នេះ

[2] សូមមើលមាត្រា ២៩៩ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦

[3] សូមមើលមាត្រា ២៩៩ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦

[4] សូមមើលមាត្រា ៣០០ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦

ត្រូវទទួលការអនុវត្តទោសដោយការបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ ខណៈដែលទោសឧក្រិដ្ឋធ្ងន់ជាងនេះ គឺទោសឧក្រិដ្ឋថ្នាក់ទីពីរ និងទោសឧក្រិដ្ឋថ្នាក់ទីបី គឺការបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត និងទោសសម្លាប់ (ប្រហារជីវិតតែម្តង)[5]។

## ផ្នែកទី២៖ អំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៩២

ប្រទេសកម្ពុជា ក្រោយកិច្ចព្រមព្រៀមទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដោយផ្អែកលើភាពចាំបាច់នៃតម្រូវការផ្នែកច្បាប់ និងវិស័យតុលាការ ក្រមព្រហ្មទណ្ឌមួយក៏ត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហៅកាត់ថា អេស អិន ស៊ី (SNC) ដើម្បីអនុវត្តក្នុងប្រទេសកម្ពុជានាសម័យអន្តរកាល និងត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៩២។ ក្រមព្រហ្មទណ្ឌនេះ ត្រូវបានបែងចែកចេញជា ៧មាតិកា និង ៧៥មាត្រា[6]។

នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះ គេក៏ឃើញមានចែងអំពីបទល្មើសញុះញង់នេះផងដែរ នៅក្នុងមាតិកាទី៥ ដែលចែងអំពីបទល្មើសមជ្ឈឹម នៅក្នុងមាត្រា ៥៩, មាត្រា ៦០ និងមាត្រា ៦១។ យ៉ាងណាមិញ ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស មាននិយមន័យ និងទិដ្ឋភាពប្រហាក់ប្រហែលគ្នា នឹងការញុះញង់ឱ្យប្រព្រឹត្តបទល្មើសដែរ បូករួមទាំងបទល្មើសការញុះញង់ឱ្យមានការរើសអើងផងដែរ។

### ១.១ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ

នៅក្នុងក្រមព្រហ្មទណ្ឌអន្តរកាល នីតិនិពន្ធខ្មែរជំនាន់នោះក៏បានបង្កើតឱ្យមានច្បាប់សម្រាប់បង្ការ និងជៀសវាងកុំឱ្យមាននូវអំពើដែលមានលក្ខណៈញុះញង់នាំឱ្យកើតមានបទល្មើសនានាទាំងឡាយ រាប់ទាំងបទឧក្រិដ្ឋ និងបទមជ្ឈឹមផង។ គេបានចែកការញុះញង់នេះជាពីរ ពោលគឺការញុះញង់ឱ្យប្រព្រឹត្តបទល្មើស និងការញុះញង់ឱ្យមានការរើសអើង។ ក្នុងមាត្រា ៥៩ នៃក្រមព្រហ្មទណ្ឌអន្តរកាលចែងថា នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ថាជាបទឧក្រិដ្ឋតាមបទបញ្ញត្តិនេះ ជនទាំងឡាយណាដែលតាមរយៈសុន្ទរកថា, តាមសម្រែក ឬការគំរាមកំហែង បន្ទរឡើងក្នុងទីកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ, តាមការសរសេរ, ការបោះពុម្ព, គំនូរ, ចម្លាក់, វិចិត្រកម្ម, និមិត្តរូប, រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ, សំដី ឬរូបភាពដែលដាក់លក់ ឬដាក់តាំងនៅទីកន្លែងនានា ឬទីប្រជុំជនសាធារណៈ, តាមផ្ទាំងបដា ឬបណ្ណប្រកាសដែលដាក់តាំងឱ្យសាធារណៈជនបានឃើញ, តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សនៈ បានបង្កដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើដូចបានពោលខាងលើនេះ បើការញុះញង់បានសំរេចផល[7]។ មាត្រានេះ បើប្រៀបធៀបទៅនឹងក្រម

[5] មាត្រា ២១ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦

[6] ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

[7] សូមមើលមាត្រា ៥៩ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

ព្រហ្មទណ្ឌថ្មីបច្ចុប្បន្នទៅលើការចង្អុលបង្ហាញពីលក្ខខណ្ឌអត្ថិភាពនៃការញុះញង់ គឺពិតជាមានលក្ខណៈសឹងតែដូចគ្នាទាំងស្រុង ដែលក្រមព្រហ្មទណ្ឌថ្មីបានប្បញ្ញត្តិអំពីចំណុចសំខាន់នេះដូចគ្នា គ្រាន់តែមិនបានបញ្ជាក់ច្បាស់បន្ថែមបែបនេះឡើយ ថាប្រសិនបើបទល្មើសបានសំរេច នោះការចោទប្រកាន់បទល្មើសញុះញង់នេះនឹងលែងអាចប្រើបាន តែប្ដូរមកវិញនឹងត្រូវចោទប្រកាន់ជាសហចារីក្នុងបទល្មើសនោះជំនួសវិញ។

ដោយឡែកមាត្រា ៥៩ នៃក្រមព្រហ្មទណ្ឌអន្តរកាល កថាខណ្ឌទី២ ក៏បានបញ្ជាក់ដែរថា លក្ខន្តិកៈនេះក៏អាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ។ ក្រឡេកមកកាន់ក្រមព្រហ្មទណ្ឌថ្មី ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋត្រូវចាត់ទុកជាបទល្មើសផងដែរ ដូច្នេះទាំងជនប្រព្រឹត្ត និងអ្នកញុះញង់ នឹងត្រូវចោទប្រកាន់ និងចាត់ទុកជាសហចារីដូចគ្នា។ ប៉ុន្តែយ៉ាងណាមិញ ក្នុងច្បាប់ចាស់គេក៏បានចែងកំណត់ផ្តន្ទាទោសដូចគ្នា បើសិនការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមនោះពុំបានសំរេចផល[8]។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងថា ជនណា តាមមធ្យោបាយណាមួយដូចមានរៀបរាប់ក្នុងមាត្រាខាងលើ (មាត្រា៥៩) នេះ ដែលបានញុះញង់ដោយផ្ទាល់ឱ្យមានបទឧក្រិដ្ឋ ឬមជ្ឈឹមណាមួយ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌអន្តរកាលនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ៥ឆ្នាំ ក្នុងករណីណាដែលការញុះញង់នោះពុំបានសំរេចផល។ ស្រដៀងគ្នានឹងចំណុចខាងលើនេះដែរ ក្នុងក្រមព្រហ្មទណ្ឌថ្មី ក៏បានកំណត់ចំពោះការផ្តន្ទាទោសចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈឹមដែរ ប៉ុន្តែក្នុងករណីដែលច្បាប់បានកំណត់ បូករួមទាំងលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញដូចជា៖

- ចារីបានចាប់ផ្ដើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។[9]

### ១.២. ការញុះញង់ឱ្យមានការរើសអើង

ជនណា តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ (ក្រមព្រហ្មទណ្ឌអន្តរកាល) ដែលបានញុះញង់ឱ្យមានសម្អប់ជាតិ, ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់ឱ្យមានការរើសអើង, អរិភាព ឬហិង្សា នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០រៀល ទៅ ១០,០០០,០០០រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន[10]។ នេះគឺជាបទប្បញ្ញត្តិកថាខណ្ឌទី១

[8] មាត្រា ៦០ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

[9] មាត្រា ២៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[10] សូមមើលត្រា ៦១ ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២

ដែលបានចែងក្នុងច្បាប់ចាស់ ឬច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលពាក់ព័ន្ធនឹងការញុះញង់ឱ្យមានការរើសអើង។ ប៉ុន្តែយ៉ាងណាក៏ដោយគេសង្កេតឃើញថា បើមកមើលក្នុងក្រមព្រហ្មទណ្ឌថ្មី បទល្មើសនេះនៅតែមានដាក់បញ្ចូលដដែល ហើយថែមទាំងបន្ថែមទម្ងន់ទោសទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ខ្លាំងជាងច្បាប់ចាស់ទៀតផង។

មិនត្រឹមតែប៉ុណ្ណោះ មាត្រា ៦១នេះក៏បានចែងបន្ថែមលើការអនុវត្តលើលក្ខខណ្ឌមួយចំនួនដែលស្រដៀងគ្នាទៅនឹងការអនុវត្តទោសបន្ថែមក្នុងក្រមព្រហ្មទណ្ឌថ្មីដែរ ពោលគឺតុលាការអាចបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួនជាសាធារណៈ និង/ឬអាចចុះផ្សាយសាលក្រមនេះក្នុងទំព័រសារព័ត៌មានមួយឬច្រើន ដោយឱ្យជនជាប់ទោសជាអ្នកទទួលបន្ទុកសោហ៊ុយចំណាយដែលច្រើនបំផុតរហូតដល់ ១០លានរៀលនាសម័យនោះ។ ជាងនេះទៅទៀត ច្បាប់នាសម័យនោះថែមទាំងបានគិតគូរដល់ការទទួលខុសត្រូវដោយនិយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬក្រុមហ៊ុនផ្សព្វផ្សាយទាំងឡាយ នឹងត្រូវទទួលខុសត្រូវរួមក្នុងការផ្តល់សំណងទៅដល់ជនរងគ្រោះទាំងអស់ ដែលទទួលរងគ្រោះដោយសារការប្រព្រឹត្តអំពើល្មើសរបស់ខ្លួននេះ។ ចំណុចចុងក្រោយនេះ វាហាក់ប្លែកបន្តិចសម្រាប់ក្រមព្រហ្មទណ្ឌថ្មីរបស់យើង ដោយសារការតម្រូវឱ្យមានការផ្តល់សំណងដោយនិយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬក្រុមហ៊ុនផ្សព្វផ្សាយនេះ គេហាក់មិនឃើញមានចែងឡើយ។ ការមិនមានចែងក្នុងក្រមព្រហ្មទណ្ឌនេះ មិនមែនមានន័យថាការទទួលខុសត្រូវនៃផ្នែកនេះត្រូវបានលុបបំបាត់ចោលនោះឡើយ ផ្ទុយទៅវិញការទទួលខុសត្រូវផ្នែកនេះ ត្រូវបានដាក់បញ្ចូលឱ្យអនុវត្តនៅក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ដែលបានចូលជាធរមាននៅតាំងពីឆ្នាំ ១៩៩៥ ជំនួសវិញ។

ទិដ្ឋភាពការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនេះ ហាក់មានភាពចាំបាច់ខ្លាំងក្នុងសង្គមកម្ពុជា ដោយជាក់ស្តែងចាប់តាំងពីប្រព័ន្ធច្បាប់ព្រហ្មទណ្ឌបានបង្កើតឡើង ច្បាប់នេះជានិច្ចកាលតែងតែមានវត្តមានជានិច្ច គ្រាន់តែមានការផ្លាស់ប្តូរនូវចំណុចមួយចំនួនប៉ុណ្ណោះដូចជាការបន្ថយនិយមន័យ និងការបន្ថែមទម្ងន់នៃការផ្តន្ទាទោសជាដើម។ បែបណាក៏ដោយ យើងនឹងបន្តទៅសិក្សាលម្អិតស៊ីជម្រៅបន្ថែមទៀតពីការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនៃក្រមព្រហ្មទណ្ឌ រួមទាំងការទទួលខុសត្រូវក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងទិដ្ឋភាពច្បាប់បច្ចុប្បន្ននេះនៅក្នុងចំណុចបន្តបន្ទាប់។

# ជំពូកទី២
# សញ្ញាណនៃការផ្ដើមគំនិត
# និងអ្នកប្រព្រឹត្តអំពើញុះញង់

# ជំពូកទី២

# សញ្ញាណនៃការផ្ដើមគំនិត និងអ្នកប្រព្រឹត្តអំពើញុះញង់

## ផ្នែកទី១៖ អ្នកផ្ដើមគំនិត និងលក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដូចដែលបានជម្រាបជូនពីខាងដើម នៅក្នុងកិច្ចការស្រាវជ្រាវនេះយើងនឹងសិក្សាលម្អិតទៅលើ "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" ដែលជាផ្នែកមួយក្នុងគន្ថីទី ៤ ស្ដីពីបទល្មើសប្រឆាំងនឹងជាតិ។ ប៉ុន្តែយ៉ាងណាមិញ ក្រមព្រហ្មទណ្ឌក៏បានប្បញ្ញត្តិពីនិយមន័យការញុះញង់នេះក្នុងផ្នែកមួយផ្សេងទៀតផងដែរ ដែលពាក់ព័ន្ធទៅនឹងអ្នកផ្ដើមគំនិត ឬអាចហៅបានម្យ៉ាងទៀតថាជាចារីបញ្ញា ដែលចារីបញ្ញានេះគឺជាតួអង្គសំខាន់ ដែលនាំឱ្យមានការញុះញង់រហូតដល់មានការប្រព្រឹត្តបទល្មើស។ តទៅទៀតនេះ យើងនឹងធ្វើការស្វែងយល់លម្អិតអំពីភាពខុសគ្នារវាងការញុះញង់ដោយអ្នកផ្ដើមគំនិត និងការញុះញង់ដែលមានក្នុងផ្នែកនៃការញុះញង់ឱ្យប្រព្រឹត្តបទល្មើស។

### ១.១ អ្នកផ្ដើមគំនិតដោយការញុះញង់

ក្រមព្រហ្មទណ្ឌបានចាត់ទុកបុគ្គលទាំងឡាយណាដែលបានជំរុញឱ្យបុគ្គលម្នាក់ផ្សេងទៀត ប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬតាមការបញ្ជា ជាអ្នកផ្ដើមគំនិតក្នុងបទល្មើសនោះ។ មិនត្រឹមតែការណែនាំ ឬការបញ្ជានោះឡើយ រាល់បុគ្គលទាំងឡាយណាដែលបានបង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមកើតមានឡើងដោយការផ្ដល់អំណោយ ដោយការសន្យា ការគំរាមកំហែង ការញុះញង់ ការលួងលោម ការរំលោភអាជ្ញារបស់ខ្លួន[11] នឹងត្រូវចាត់ទុកក្នុងឋានៈជាអ្នកផ្ដើមគំនិត និងជាសហចារីនៃបទល្មើសនោះផងដែរ។ ប៉ុន្តែយ៉ាងណាមិញ ដោយសារបទល្មើសព្រហ្មទណ្ឌទាមទារឲ្យមានអំពើ(ធាតុផ្សំសត្យានុម័ត) ក៏ប៉ុន្តែអ្នកញុះញង់មិនបានប្រព្រឹត្តអំពើដែលជាបទល្មើសនោះដោយផ្ទាល់ ដូច្នេះ គេមិនអាចចាត់ទុកអ្នកញុះញង់ជាជនប្រព្រឹត្តបទល្មើសទេ ក៏ប៉ុន្តែច្បាប់ចាប់ឲ្យអ្នកញុះញង់ទទួលខុសត្រូវដូចជាជនប្រព្រឹត្តដែរ។ មានន័យថា បើជនប្រព្រឹត្តមានទោស អ្នកញុះញង់ក៏មានទោសដែរ។ ឧទាហរណ៍៖ បើបុគ្គល "ក" បានធ្វើការញុះញង់ឱ្យបុគ្គល "ខ" ទៅលួចទ្រព្យសម្បត្តិអ្នកដទៃ ក្នុងគោលបំណងលក់ដើម្បីបានលុយទិញគ្រឿងញៀនប្រើប្រាស់ជាមួយគ្នា ហើយ "ខ" ទៅលួចគេបានសម្រេចពិតមែន នោះ "ក" ក៏ត្រូវទទួលខុសត្រូវក្នុងនាមជាអ្នកផ្ដើមគំនិតក្នុងអំពើលួចនោះដែរ។ លើសពីនេះទៅទៀត នៅក្នុងមាត្រា ២៨ នេះ ច្បាប់ក៏បានប្បញ្ញត្តិបន្ថែមទៀតថា អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ មិនត្រឹមតែប៉ុណ្ណោះ អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នាទៅនឹងចារីដែរ។ អ្នកផ្ដើមគំនិតត្រង់ចំណុចនេះ អាចត្រូវបានផ្ដន្ទាទោសតែចំពោះការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមតែប៉ុណ្ណោះ តែច្បាប់មិនតម្រូវឱ្យផ្ដន្ទាទោសចំពោះបទល្មើសលហុ

[11] សូមមើលមាត្រា ២៨ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ឡើយ។ ឧទាហរណ៍៖ អ្នកបើកបររថយន្តឱ្យគេម្នាក់ កំពុងបំពេញការងារបើកបរជូនថៅកែរបស់ខ្លួនលើដងផ្លូវ។ គាប់ជួនជាភ្លើងសញ្ញាចរាចរណ៍កំពុងមានពណ៌ក្រហម ប៉ុន្តែថៅកែនោះបានបង្គាប់បញ្ជាឱ្យអ្នកបើកបរនៅតែបន្តបើកនៅមុខទៀតដោយមានការប្រញាប់។ ពេលនោះមាននគរបាលចរាចរណ៍បានចេញមកឃាត់ និងផាកពិន័យពីបទល្មើសច្បាប់ចរាចរណ៍។ ក្នុងករណីនេះ អនុលោមតាមមាត្រា ២៨ ថៅកែដែលជាងអ្នកបញ្ជានោះគឺជាអ្នកផ្តើមគំនិត ប៉ុន្តែការទទួលខុសត្រូវនៃអ្នកផ្តើមគំនិតមានតែនៅក្នុងបទមជ្ឈិម និងបទឧក្រិដ្ឋប៉ុណ្ណោះ ដូច្នេះហើយអ្នកបើកបររថយន្តនោះផ្ទាល់ នឹងទទួលខុសត្រូវលើបទល្មើសមិនគោរពភ្លើងសញ្ញាចរាចរណ៍ នៃមាត្រា ៧(ថ្មី) នៃអនុក្រឹត្យលេខ៣៩ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក។

### ១.២ លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

នៅក្នុងផ្នែក "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" នៃគន្ថីទី ៤ ស្តីពីបទល្មើសប្រឆាំងនឹងជាតិ ក្រមព្រហ្មទណ្ឌបានបញ្ញត្តិអំពីបទល្មើសចំនួន ២ ដែលកើតចេញពីការញុះញង់នេះ។ ខុសប្លែកពីនិយមន័យនៃអ្នកផ្តើមគំនិតតាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ លក្ខខណ្ឌអត្ថិភាពនៃការញុះញង់ សំដៅទៅលើភាពដែលអាចចោទប្រកាន់បាន ក្នុងលក្ខខណ្ឌជនល្មើស ប្រព្រឹត្តអំពើញុះញង់នាំឱ្យមានបទឧក្រិដ្ឋជាអាទិ៍ ឬញុះញង់នាំឱ្យមានភាពរើសអើង។ អត្ថិភាព មានន័យថា ការកើតមាន ហើយការញុះញង់ មានន័យថា ជាការពន្យុះលើកទឹកចិត្ត ជំរុញ ឬធ្វើយ៉ាងណាឱ្យបុគ្គលផ្សេងប្រព្រឹត្តបទល្មើស។ តាមក្រមព្រហ្មទណ្ឌ ការញុះញង់អាចត្រូវបានផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយលក្ខខណ្ឌ ៣ រួមមាន[12]៖

១. ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ។ លក្ខខណ្ឌទី១ នេះសំដៅទៅលើការប្រើប្រាស់សំដីដែលមានលក្ខណៈញុះញង់ ដែលប្រកាសឱ្យសាធារណជនបានដឹងក្នុងទីកន្លែងសាធារណៈ ឬក្នុងពេលប្រជុំជាសាធារណៈ។ ទីកន្លែងសាធារណៈត្រង់នេះ សំដៅទៅលើទីតាំង បរិវេណ អគារ មធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋ សាធារណៈ ឬឯកជនដែលបើកទូលាយ និងផ្តល់សេវាដល់សាធារណជនទូទៅ[13] ដូចជា ក្រសួង ស្ថាប័ន មន្ទីរ កន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា ជាដើម-ល-។

២. ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលបានផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធារណជនមើល។ លក្ខខណ្ឌទី២នេះ ស្រដៀងទៅនឹងលក្ខខណ្ឌទី១ខាងលើដែរ តែខុសគ្នាពីការប្រើ

[12] សូមមើលមាត្រា ៤៩៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[13] មាត្រា ៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ២០០៩

ពាក្យសំដីញុះញង់ មកជាការបង្ហាញនូវសំណេរ ឬគំនូរជំនួសវិញ ដោយអនុវត្តដែលចំពោះការផ្សព្វផ្សាយក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធារណជនបានមើល។

៣. ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។ នៅសម័យមុនពេលដែលបច្ចេកវិទ្យាមានការរីកចំរើន ហើយកំឡុងពេលដែលជីវភាពប្រជាជនខ្មែរនៅមានកម្រិតនៅឡើយ ការញុះញង់ដោយប្រើមធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន មិនទាន់មានភាពទូលំទូលាយនោះទេ ម្ល៉ោះហើយការញុះញង់ដោយផ្នែកនេះពីដើមមកក៏មិនសូវសំបូរបែបដែរ។ ដោយឡែកចំពោះពាក្យទូរគមនាគមន៍សោតទស្សន៍នេះទៀតសោត តាមសន្ទានុក្រមពាក្យច្បាប់ គឺមានន័យថាប្រព័ន្ធផ្សព្វផ្សាយនឹងទូរទស្សន៍។[14]

យ៉ាងណាក្តី ឈានមកដល់សម័យបច្ចុប្បន្ននេះ ប្រព័ន្ធផ្សព្វផ្សាយហាក់មានភាពទូលំទូលាយខ្លាំងក្នុងប្រទេសកម្ពុជា រាប់ចាប់ពីព្រឹត្តិប័ត្រ កាសែត ទស្សនាវដ្តី គេហទំព័រ ស្ថានីយ៍វិទ្យុ ស្ថានីយ៍ទូរទស្សន៍ជាដើម។ មិនត្រឹមតែប៉ុណ្ណឹងឡើយ ក្នុងសម័យបដិវត្តន៍ឧស្សាហកម្មបច្ចេកវិទ្យា ៤.០ ប្រព័ន្ធផ្សព្វផ្សាយទូទាំងសកលលោក មិនមានភាពលំបាកក្នុងការនាំយកព័ត៌មានមកដល់ដៃមនុស្សទៀតឡើយ ផ្ទុយទៅវិញមនុស្សអាចទៅក្បែរប្រព័ន្ធផ្សព្វផ្សាយកាន់តែកៀក ឬរហូតអាចបង្កើតឱ្យមានប្រព័ន្ធផ្សព្វផ្សាយនៅក្នុងដៃតែម្តងក៏សឹងមាន។ នៅកម្ពុជាបច្ចុប្បន្ននេះប្រជាជនស្ទើរតែគ្រប់គ្នា មានលទ្ធភាពក្នុងការប្រើប្រាស់ទូរស័ព្ទដៃទំនើប ដែលនាំឱ្យមានភាពងាយស្រួលក្នុងការទទួលព័ត៌មាន និងការផ្សព្វផ្សាយនានា។ បើនិយាយពីគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញវិញ មានចំនួនច្រើនសឹងតែរាប់មិនអស់។ បើទោះបីរដ្ឋធម្មនុញ្ញកម្ពុជាបានធានានូវសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញមតិក៏ដោយ ក៏ពលរដ្ឋមិនត្រូវយល់ច្រលំក្នុងការប្រើប្រាស់សេរីភាពបញ្ចេញមតិរបស់ខ្លួនរហូតនាំឱ្យកើតមានជាបទល្មើសដែរ។

## ផ្នែកទី២៖ ចារីនៃអំពើញុះញង់

នៅក្នុងប្រព័ន្ធនីតិខ្មែរយើងបានឃើញមាត្រា ២៥ ដែលបានឱ្យនិយមន័យចំពោះចារី ដោយចាត់ទុករាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់។ និយមន័យនេះក៏ត្រូវបានផ្តល់ឱ្យផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់ចែងទុកចំពោះបទមជ្ឈិម[15]។ អំពើញុះញង់ នៅក្នុងក្រមព្រហ្មទណ្ឌខ្មែរ អ្នកប្រព្រឹត្តអាចត្រូវបានចោទប្រកាន់ជាសហចារី (ក្នុងនាមជាអ្នកផ្តើមគំនិត) ឬជាចារីផ្ទាល់នៃអំពើញុះញង់នោះតែម្តង។ សហចារី[16] សំដៅទៅលើបុគ្គលច្រើននាក់ ដែលបានព្រម

[14] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

[15] កថាខណ្ឌទី២ មាត្រា ២៥ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[16] មាត្រា ២៦ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ព្រៀងគ្នា ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ដូចគ្នាទៅនឹងមាត្រា ២៥ ច្បាប់ចាត់ទុកថាជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់ចែងទុក។

បើតាមការស្រាវជ្រាវនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អំពើញុះញង់អាចប្រព្រឹត្តបានដោយរូបវន្តបុគ្គលប៉ុណ្ណោះ។ ប៉ុន្តែយ៉ាងណាមិញ ប្រសិនបើនីតិបុគ្គលក៏តម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ ចំពោះអំពើល្មើសទាំងឡាយណាដែលមានចែងជាក់លាក់ក្នុងច្បាប់ ហើយត្រូវបានប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។

### ២.១ ចារីជារូបវន្តបុគ្គល

រូបវន្តបុគ្គលគឺជាមនុស្សពិតតាមធម្មជាតិ ពោលគឺមានរូបរាង មានសាច់ឈាម មានជីវិត ហើយផ្ទុយពីនីតិបុគ្គល។ ចារីជារូបវន្តបុគ្គលសំដៅទៅលើការប្រព្រឹត្តបទល្មើសទាំងឡាយណាដែលប្រព្រឹត្តដោយបុគ្គលទូទៅដែលបានបង្គាប់បញ្ជា ណែនាំ លួងលោម បង្កឱ្យមាននូវបទល្មើសកើតឡើង។ ឧទាហរណ៍៖ នៅក្នុងអំពើហិង្សា ពោលគឺបុគ្គល "ក", "ខ", និង "គ" មានទំនាស់ជាមួយបុគ្គល "ឃ" ហើយបុគ្គល "ក" មានគំនិតក្នុងការប្រដៅទៅលើបុគ្គល "ឃ" នោះ ដោយបានប្រើពាក្យសម្ដីញុះញង់ឱ្យ "ខ" និង "គ" ប្រព្រឹត្តអំពើហិង្សា ដោយប្រើប្រាស់កាំបិតកាប់ទៅលើ "ឃ" រយៈក្បាលដេរជាច្រើនថ្នេរ ។ ជាធម្មតា ក្នុងករណីអំពើហិង្សាមួយកើតឡើង ច្បាប់តម្រូវឱ្យមានការផ្តន្ទាទោសទៅលើជនល្មើសដោយការដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ ព្រមទាំងពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល[17]ប៉ុណ្ណោះ ប្រសិនបើអំពើនោះត្រូវបានប្រព្រឹត្តឡើងដោយចារីតែម្នាក់។ យ៉ាងណាមិញ ក្នុងបទល្មើសហិង្សាដដែលនេះ ច្បាប់តម្រូវឱ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរជាង ប្រសិនបើប្រព្រឹត្តដោយមានស្ថានទម្ងន់ទោស[18]។ បទល្មើសអំពើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ ៤លានរៀល ទៅ ១០លានរៀល កាលណាបើបទល្មើសនេះត្រូវបានប្រព្រឹត្ត ១.ដោយមានការគិតទុកជាមុន ២. ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ៣.ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។ ចារីជារូបវន្តបុគ្គលនៃអំពើញុះញង់ក្នុងករណីហិង្សានេះ សំដៅទៅលើអ្នកផ្តើមគំនិតដោយការញុះញង់ បង្កឱ្យមានបទល្មើសនេះកើតឡើង ពោលគឺ "ក" ដែលបានញុះញង់ និងចង្អុលបង្ហាញឱ្យ "ខ" និង "គ" ឱ្យប្រព្រឹត្តអំពើហិង្សានេះ។ បើទោះបីជា "ក" មិនបានប្រព្រឹត្តអំពើនេះដោយផ្ទាល់ក៏ដោយ ប៉ុន្តែបុគ្គលនេះគឺជាអ្នក

[17] មាត្រា ២១៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[18] មាត្រា ២១៨ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ញុះញង់ឱ្យមានការប្រព្រឹត្តបទល្មើស ដែលត្រូវទទួលខុសត្រូវក្នុងឋានៈជាអ្នកផ្ដើមគំនិត ហើយក៏ជាចារីនៃអំពើ អំពើញុះញង់ជារូបវន្តបុគ្គល។

### ២.២ ចារីជានីតិបុគ្គល

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬជាមូលនិធិដែលមានបុគ្គលភាពគតិយុត្តិ ហើយជាម្ចាស់នៃសិទ្ធិ និង កាតព្វកិច្ច[19]។ ជាទូទៅនីតិបុគ្គលមានពីរនីតិបុគ្គលជារដ្ឋ ឬគេហៅថានីតិបុគ្គលសាធារណៈ និងនីតិបុគ្គលមិន មែនជារដ្ឋ ឬគេហៅថានីតិបុគ្គលឯកជន។ នីតិបុគ្គលទាំងអស់លើកលែងតែនីតិបុគ្គលជារដ្ឋចេញ សុទ្ធតែអាច ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបានទាំងអស់។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានប្បញ្ញត្តិពីចំណុចច្បាស់លាស់មួយដែលបង្ហាញថា ប្រសិនបើក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្ម ទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ[20]។ តាមជាក់ស្ដែង នីតិបុគ្គលមិនមែនជាមនុស្ស ដូច្នេះនីតិបុគ្គលមិនអាចប្រព្រឹត្តអំពើញុះញង់បានទេ។ ប៉ុន្តែករណី មួយចំនួន នីតិបុគ្គលអាចតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌបានផងដែរ ចំពោះអំពើផ្ដើមគំនិតរបស់រូបវន្ត បុគ្គលដែលជាអភិបាល ឬអ្នកតំណាងរបស់នីតិបុគ្គលនោះ។ ឧទាហរណ៍៖ ម្ចាស់រោងចក្រមួយកន្លែង បានបញ្ជា ឱ្យកម្មកររបស់ខ្លួនបិទកង្ហារក្នុងរោងចក្រចំនួនពាក់កណ្ដាល ដើម្បីកុំឱ្យមានការប្រើប្រាស់អគ្គិសនីច្រើនពេក ដែល អាចនាំឱ្យរោងចក្រមានការចំណាយខ្ពស់។ ក្រោយពីបិទរួចរាល់ មានកម្មករ-កម្មការិនីមួយចំនួនបានខ្យល់គ ហើយបានស្លាប់ក្រោយពេលបញ្ជូនទៅដល់មន្ទីរពេទ្យ។ ក្នុងករណីនេះ ម្ចាស់រោងចក្រខាងលើអាចត្រូវចោទ ប្រកាន់ពីបទមនុស្សឃាតដោយអចេតនា[21] ក្នុងឋានៈជាអ្នកផ្ដើមគំនិត ហើយនីតិបុគ្គល ពោលគឺរោងចក្រនោះក៏ អាចត្រូវតុលាការប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ចំពោះបទល្មើសមនុស្សឃាតដោយចេតនា ដែល ប្រព្រឹត្តដោយអ្នកតំណាង (ម្ចាស់រោងចក្រ) ខាងលើ[22]។

## ផ្នែកទី៣៖ ភាពខុសគ្នារវាងអ្នកផ្ដើមគំនិត និងអ្នកប្រព្រឹត្តអំពើញុះញង់

ដូចដែលបានលើកឡើងខាងដើម ការចាត់ទុកជាអ្នកផ្ដើមគំនិតសំដៅទៅលើបុគ្គលទាំងឡាយណា ដែលជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទបជ្ជិមតាមការណែនាំ ឬ ការបញ្ជា ឬបង្កឲ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិម នោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភ

---

[19] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧ លេខរៀងទី ៧១

[20] មាត្រា ៤២ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[21] មាត្រា ២០៧ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[22] មាត្រា ២០៩ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

អាជ្ញា ឬ អំណាចរបស់ខ្លួន។ អ្នកផ្តើមគំនិតនឹងត្រូវអាចផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវបានសម្រេច ឬ ប៉ុនប៉ង។ ផ្ទុយពីនេះ ក្នុងក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិផងដែរ អំពីបទល្មើសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍[23] ដែលបង្ហាញឱ្យឃើញថា អ្នកប្រព្រឹត្តអំពើញុះញង់ក្នុងឋានៈជាចារីផ្ទាល់នៅក្នុងបទល្មើសនេះ ត្រូវច្បាប់កំណត់ផ្តន្ទាទោសតែម្តង ដោយមិនចាំបាច់ទាល់តែបទឧក្រិដ្ឋដែលជាគោលដៅនៃការញុះញង់នោះបានសម្រេចផល ឬប៉ុនប៉ងនោះឡើយ។ ដូច្នេះ យើងសង្កេតឃើញនូវភាពខុសគ្នា ក្នុងនាមជាចារីនៃអំពើញុះញង់ក្នុងឋានៈជាអ្នកផ្តើមគំនិត និងចារីផ្ទាល់នៃអំពើញុះញង់។ ចំណុចបន្តទៀតនេះ យើងនឹងធ្វើការវិភាគ និងបែងចែកអំពើការញុះញង់ក្នុងឋានៈជាអ្នកផ្តើមគំនិតតាមមាត្រា ២៨ និងចារីជាអ្នកប្រព្រឹត្តអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសដោយផ្ទាល់តាមមាត្រា ៤៩៥។

### ៣.១ អ្នកផ្តើមគំនិតដោយការញុះញង់

តាមមាត្រា ២៨ ខាងលើ មានអំពើពីរដែលចាត់ទុកជាការញុះញង់ ទីមួយៈ ការណែនាំ ទីពីរៈ ការបង្ក។

**ក.ការណែនាំ**: សំដៅទៅអ្នកដែលបានផ្តល់ឱ្យនូវការណែនាំ ឬការបង្គាប់បញ្ជាដល់អ្នកប្រព្រឹត្តផ្ទាល់។ បុគ្គលនេះគឺជាអ្នកផ្តល់ពត៌មានដល់អ្នកប្រព្រឹត្តផ្ទាល់ដូចជា ពីរបៀបនៃការប្រព្រឹត្តបទល្មើស ពីព័ត៌មាននៃគោលដៅដែលជាកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស) ឬអាចនិយាយជារួមថា បុគ្គលនោះបានប្រាប់ពីពត៌មានដើម្បីសំរួលដល់ការប្រព្រឹត្តផ្ទាល់នោះ។ ឧទាហរណ៍ៈ ក្នុងបទហិង្សា បុគ្គលជាអ្នកញុះញង់នោះបានណែនាំចារីឱ្យប្រព្រឹត្តហិង្សា ដោយណែនាំការប្រើប្រាស់អាវុធណាមួយ(ដូចជាខ្សែក្រវ៉ាត់ជាដើម) ឬអាចប្រាប់ពីគោលដៅដែលជនរងគ្រោះបំរុងនឹងធ្វើដំណើរទៅ-ល-។ និយាយរួមអ្នកញុះញង់ដោយការណែនាំ គឺជាមេប្រាជ្ញា ជាអ្នកផ្តល់ប្រាជ្ញាឲ្យអ្នកប្រព្រឹត្តផ្ទាល់ ឬចារីអាចប្រព្រឹត្តបទល្មើសណាមួយបាន។

**ខ. ការបង្ក**: ជាទូទៅ ការញុះញង់ជាការបង្កឱ្យមានបទល្មើស អាចចោទប្រកាន់ទៅបាន គេឃើញមានការចូលរួមដោយលក្ខខណ្ឌសំខាន់ៗចំនួន ៣ ដូចជាៈ ១.ការបង្កនោះត្រូវធ្វើដោយផ្ទាល់, ២. ការបង្កត្រូវតែមានលក្ខណៈជាឯកត្តភូត និង ៣. ការបង្កត្រូវតែមានទម្ងន់ជម្រុញ តាមមធ្យោបាយណាមួយដែលរៀបរាប់ក្នុងមាត្រា ២៨ កថាខណ្ឌទី២ ដូចជា ការផ្តល់អំណោយ ការសន្យា ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬការរំលោភអាជ្ញា ឬ អំណាច។ មែនទែនទៅ ការបង្កមិនសូវទាក់ទងនឹងការផ្តល់គំនិតដល់ជនប្រព្រឹត្តផ្ទាល់ប៉ុន្មានទេ ប៉ុន្តែមួយជ្រុងផ្សេងទៀត វាជាការអន្ទងចិត្ត គាបសង្កត់ផ្លូវចិត្ត ឬផ្លូវកាយ និងអាចជាការអូសទាញឲ្យអ្នកប្រព្រឹត្តផ្ទាល់មានទឹកចិត្តនឹងប្រព្រឹត្ត។ អំពើទាំងនេះមានដូចជាការគំរាមកំហែង ការរំលោភអាជ្ញា ឬ អំណាចរបស់អ្នកផ្តើមគំនិត ឬការផ្តល់អំណោយ ការសន្យានឹងឲ្យអ្វីមួយ ការលួងលោមបុគ្គលណាម្នាក់ បើជនម្នាក់ទៀតមិនមាន

[23] មាត្រា ៤៩៥ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចេតនាខ្លួនឯងដើម្បី ប្រព្រឹត្តបទល្មើសមួយទេនោះ។ ឧទាហរណ៍៖ បុគ្គលម្នាក់ជាអ្នកប្រកបរបរខុសច្បាប់ ដោយជាអ្នកប្រកបរបរពេស្យាចារលើកុមារ ហើយគាប់ជួនជួបស្ត្រីម្នាក់ដែលកំពុងមានជីវភាពខ្វះខាត បុគ្គលនោះក៏បានអូសទាញក្នុងន័យញុះញង់ឱ្យស្ត្រីម្នាក់នោះយល់ព្រមឱ្យកូនស្រីជាអនីតិជនរបស់ខ្លួនយល់ព្រមទៅផ្តល់សេវាផ្លូវភេទ ជាថ្នូរនឹងការបានប្រាក់មួយចំនួនធំសម្រាប់ការចាយវាយ ដោះស្រាយជីវភាព។ ក្នុងករណីនេះ យើងឃើញថា នារីម្នាក់នោះគ្មានគំរោងក្នុងការប្រព្រឹត្តអំពើសញ្ចារកម្មនេះ ប៉ុន្តែនាងត្រូវបានណែនាំដោយបុគ្គលដែលជាអន្តរការី ហើយក៏ព្រមព្រៀងក្នុងការប្រព្រឹត្តអំពើនេះ ដោយមានការសន្យាថានឹងផ្តល់ប្រាក់ជាថ្នូរ ។ ករណីមួយផ្សេងទៀត បុរសម្នាក់ជាប្រធានក្រុមហ៊ុនដឹកជញ្ជូនមួយ បានបង្គាប់បញ្ជាឱ្យបុគ្គលិករបស់ខ្លួនម្នាក់ដឹកជញ្ជូនទំនិញខុសច្បាប់។ បុគ្គលិកនោះត្បិតដឹងថានោះជាទំនិញខុសច្បាប់ក៏ពិតមែន ប៉ុន្តែមិនហ៊ានប្រកែកត្បិតរងការគំរាមកំហែងថានឹងត្រូវបញ្ឈប់ពីការងារប្រសិនបើមិនព្រមដឹកទំនិញនោះ។ ក្នុងបទល្មើសនេះ បុគ្គលិកជាអ្នកដឹកជញ្ជូននោះបានយល់ព្រមប្រព្រឹត្តបទល្មើស ដោយមានការគំរាមកំហែងឱ្យប្រព្រឹត្តពីប្រធានក្រុមហ៊ុននោះផ្ទាល់។

ការញុះញង់ប្រព្រឹត្តដោយអ្នកផ្តើមគំនិតនេះ ច្បាប់របស់កម្ពុជាបានកំណត់ផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តអំពើផ្ទាល់ ឬចារីផងដែរ ប្រសិនបើបទល្មើសមជ្ឈិម ឬបទឧក្រិដ្ឋនោះត្រូវបានសម្រេច ឬប៉ុនប៉ង។[24] ខុសគ្នាពីនេះ សម្រាប់បទល្មើសក្នុងផ្នែកការញុះញង់ឱ្យប្រព្រឹត្តបទល្មើស ច្បាប់ពុំតម្រូវឱ្យមាននូវការប៉ុនប៉ង ឬបទល្មើសបានសម្រេចផលនោះឡើយ ពោលគឺការចោទប្រកាន់អាចធ្វើទៅបាន បើទោះជាបីជាការញុះញង់នោះគ្មានប្រសិទ្ធិភាពក៏ដោយ ចំណុចនេះយើងនឹងធ្វើការបញ្ជាក់នៅចំណុចបន្ទាប់។

### ៣.២ ចារីនៃអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើស

ផ្ទុយពីចារីជាអ្នកញុះញង់ ឬហៅបានថាជាអ្នកផ្តើមគំនិត ដែលជាចារីបញ្ញា ពោលជននោះគឺជាអ្នកណែនាំ អ្នកចង្អុលបង្ហាញឱ្យប្រព្រឹត្តបទល្មើស ប៉ុន្តែមិនបានប្រព្រឹត្តអំពើល្មើសដោយផ្ទាល់នោះឡើយ។ ប៉ុន្តែចារីនៃអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើសវិញ គឺជាអ្នកប្រព្រឹត្តអំពើល្មើសនេះដោយផ្ទាល់តែម្តង។ លក្ខខណ្ឌអត្ថិភាព ឬលក្ខខណ្ឌនាំឱ្យមានអំពើញុះញង់ដែលបានបង្ហាញជូននៅខាងលើបានបង្ហាញឱ្យឃើញថា ដើម្បីអាចចោទប្រកាន់ទៅលើបុគ្គលណាមួយថាជាអ្នកប្រព្រឹត្តអំពើញុះញង់បាន លុះណាតែបានបំពេញនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌចំនួនបី ដែលរួមមានការញុះញង់តាមពាក្យសម្តី តាមគំនូរ ឬសំណេរ ឬតាមមធ្យោបាយគមនាគមន៍សោតទស្សន៍ ដែលបង្ហាញឱ្យសាធារណជនបានឃើញជាសាធារណៈជាអាទិ៍។ ក្នុងផ្នែកការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនេះ ច្បាប់មានគោលបំណងក្នុងការបង្ការ ថែរក្សាសណ្តាប់ធ្នាប់សង្គម និងជៀសវាងបាតុភាពធ្ងន់ធ្ងរណាមួយដែលអាចប៉ះពាល់ដល់សន្តិសុខជាតិ។

[24] កថាខណ្ឌទី២ មាត្រា២៨ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

អ្នកប្រព្រឹត្តបទល្មើសក្នុងផ្នែកនេះ ឧទាហរណ៍ បទល្មើសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ លក្ខខណ្ឌដែលនាំឱ្យមានការចោទប្រកាន់បាន ចារីត្រូវតែបង្ហាញទង្វើដែលមានលក្ខណៈជាការញុះញង់ទៅកាន់សាធារណជន មិនថាតាមរយៈពាក្យសំដី សំណេរ គំនូរ ទៅកាន់សាធារណជន នៅទីតាំងសាធារណៈ ឬតាមមធ្យោបាយគមនាគមន៍សោតទស្សន៍ដែលបើកទូលាយសម្រាប់សាធារណជនបានឃើញ និងប្រើប្រាស់។ ខុសពីអ្នកផ្ដើមគំនិត ការចោទប្រកាន់អាចធ្វើទៅបាន លុះត្រាតែបទល្មើសបានសម្រេចផល ឬមានការប៉ុនប៉ងជាក់ស្ដែង ប៉ុន្តែក្នុងការញុះញង់នៃផ្នែកនេះ លក្ខខណ្ឌដែលអាចចោទប្រកាន់បាន មិនចាំបាច់ទាល់តែមានការប៉ុនប៉ង រៀបចំផែនការដើម្បីប្រព្រឹត្តបទល្មើស ឬមានបទល្មើសណាមួយសម្រេចទើបអាចចោទប្រកាន់បានឡើយ ពោលគឺការញុះញង់គ្មានប្រសិទ្ធិភាពក្តី ក៏តំណាងអយ្យការអាចធ្វើការចោទប្រកាន់អំពីបទល្មើសញុះញង់បានដូចគ្នា។ ដូចដែលបានបកស្រាយពីខាងដើម ផ្នែកនេះមានគោលដៅក្នុងការទប់ស្កាត់ និងបង្ការចលាចលក្នុងសង្គមដែលកើតមានពីការញុះញង់ ត្បិតព្យសនកម្មដែលកើតឡើងអំពីបទល្មើសនេះវាមានលក្ខណៈធំទូលាយ និងហានិភ័យដល់សន្តិសុខ និងសុវត្ថិភាពសង្គមជាតិទាំងមូល។

ឧទាហរណ៍៖ នៅក្នុងករណីមានការទាមទារតវ៉ាមួយរបស់ប្រជាពលរដ្ឋ ក្នុងជម្លោះដីធ្លីមួយដែលកើតឡើងក្រោយរដ្ឋាភិបាលអនុញ្ញាតឱ្យមានការវិនិយោគសាងសង់រោងចក្រហើយមានការប៉ះពាល់នាំឱ្យមានវិវាទ។ ក្រោយមកក្នុងការប្រមូលផ្តុំតវ៉ា និងទាមទារឱ្យមានដំណោះស្រាយនោះ ស្រាប់តែបុគ្គលដែលជាតំណាងបានលើកឡើងក្តែងក្នុងចំណោមពលរដ្ឋផ្សេងៗ និងញុះញង់ឱ្យប្រជាពលរដ្ឋតវ៉ាដោយប្រើប្រាស់អាវុធតបតនិងអាជ្ញាធរកម្លាំងសមត្ថកិច្ចដែលកំពុងរក្សាសុវត្ថិភាពនៅក្បែរនោះ ព្រមទាំងញុះញង់ឱ្យមានការបំផ្លិចបំផ្លាញទីតាំងស្ថាប័នសាធារណៈរបស់រដ្ឋនោះដោយដុំថ្ម -ល-។ ប្រសិនបើប្រជាពលរដ្ឋទាំងនោះ ប្រព្រឹត្តអំពើដូចការញុះញង់ខាងលើនោះពិតមែន បុគ្គលដែលបានញុះញង់ឱ្យមានអំពើហិង្សា និងការបំផ្លិចបំផ្លាញនោះ លែងអាចត្រូវចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋទៀតហើយ តែអាចត្រូវចោទប្រកាន់ពីបទដឹកនាំចលនាកុបកម្ម[25] ជំនួសវិញ។ ប៉ុន្តែក្នុងគ្រានោះ ប្រជាពលរដ្ឋដែលនៅក្បែរនោះពុំបានប្រព្រឹត្តទង្វើតាមការញុះញង់របស់បុគ្គលនោះឡើយ។ ក្នុងករណីនេះ សមត្ថកិច្ចអាចធ្វើការឃាត់ខ្លួនបុគ្គលដែលបានប្រើពាក្យសម្តីញុះញង់នេះបាន ហើយតុលាការអាចធ្វើការចោទប្រកាន់បុគ្គលនេះពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (បទកុបកម្ម) ជំនួសវិញ។

យ៉ាងណាមិញ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស មិនមែនទាល់តែជាករណីផ្ទាល់ដូចឧទាហរណ៍ដូចដែលបានឃើញខាងលើនេះឡើយ។ ករណីដែលបានជួបប្រទះក្រោយៗមកទៀត ភាគច្រើនគឺជាការញុះញង់ដែលប្រព្រឹត្តតាមប្រព័ន្ធគមនាគមន៍សោតទស្សន៍ ជាពិសេសគឺលើប្រព័ន្ធបណ្តាញសង្គម (បណ្តាញសង្គមហ្វេស

[25] មាត្រា ៤៥៩ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ប៊ុក, ធ្វីតធ័រ,អ៊ីនស្តាក្រាម, ទីកតុក ....) ដែលយើងឃើញថាវាជារូបភាពថ្មីដែលនាំឱ្យមានការភ័ន្តច្រឡំពីសំណាក់សាធារណជនទូទៅរវាងការញុះញង់ និងសេរីភាពនៃការបញ្ចេញមតិដែលជាសេរីភាពជាមូលដ្ឋានមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

មកដល់ចំណុចចុងក្រោយនៃផ្នែកនេះ យើងអាចសង្ខេបបានថាអ្នកផ្តើមគំនិតឱ្យមានបទល្មើសដោយការញុះញង់ គឺជាចារីផ្នែកបញ្ញានៃបទល្មើសនេះផ្ទាល់ បើទោះបីជាបុគ្គលខាងលើមិនបានប្រព្រឹត្តបទល្មើសនោះដោយផ្ទាល់ក៏ដោយ ក៏បុគ្គលនោះគឺជាតួអង្គយ៉ាងសំខាន់ក្នុងបទល្មើសនោះ ពោលគឺបទល្មើសដែលកើតឡើងបានអាស្រ័យលើគំនិតបញ្ញារបស់ជននោះផ្ទាល់ ហើយការផ្តន្ទាទោសអាចធ្វើទៅបានលុះត្រាតែបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមនោះបានសម្រេច ឬមានការប៉ុនប៉ង។ ដោយឡែក ចារីនៃអំពើញុះញង់ឱ្យប្រព្រឹត្តបទល្មើស (ប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍) មិនមែនជាអ្នកផ្តើមគំនិតនោះឡើយ ពោលគឺជាចារីផ្ទាល់តែម្តងនៃបទល្មើសនេះ ហើយការផ្តន្ទាទោសជននោះអាចធ្វើទៅបានដោយមិនចាំបាច់រង់ចាំឱ្យមានការសម្រេចបទល្មើស ឬមានការប៉ុនប៉ងឡើយ។ ទំហំព្យសនកម្មកើតចេញពីអំពើនៃការញុះញង់តាមមាត្រា ៤៩៥ ហាក់មានលក្ខណៈធំធេង បើប្រៀបជាមួយបទល្មើសឧក្រិដ្ឋដែលប្រព្រឹត្តតាមការញុះញង់របស់អ្នកផ្តើមគំនិត មាត្រា ២៨ ដែលទាមទារឱ្យច្បាប់ទប់ស្កាត់ជាមុនមិនឱ្យមានការប៉ុនប៉ងញុះញង់បណ្តាលឱ្យកើតមាននូវបទឧក្រិដ្ឋ ឬការប្រព្រឹត្តអំពើទាំងឡាយណាដែលបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមទាំងមូល។

នៅជំពូកក្រោយ យើងនឹងធ្វើការសិក្សាទៅលើបទល្មើសដែលកើតចេញអំពីការញុះញង់ រួមមានបទញុះញង់ឱ្យប្រព្រឹត្តបទល្មើសជាអាទិ៍ (មាត្រា ៤៩៥) បទញុះញង់ឱ្យមានការរើសអើង (មាត្រា ៤៩៦) និងអំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន (មាត្រា ៤៩៧) រួមជាមួយទោសប្បញ្ញត្តិនៃអំពើល្មើសទាំងនោះ។

# ជំពូកទី៣
# ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស
# និងការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

# ជំពូកទី៣

# ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស និងការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិបានចែងយ៉ាងជាក់ច្បាស់ថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មានត្រូវបានកំណត់ដោយច្បាប់។[26] បើទោះបីជាសិទ្ធិនេះត្រូវបានចាត់ទុកជាសិទ្ធិសេរីភាពជាមូលដ្ឋានដែលមិនអាចកាត់ផ្តាច់បានពីពលរដ្ឋម្នាក់ៗ ថែមទាំងទទួលបានការការពារពីច្បាប់កំពូលរបស់ជាតិ និងសន្ធិសញ្ញាអន្តរជាតិក៏ដោយ ក៏ប៉ុន្តែពលរដ្ឋទាំងឡាយ ពុំអាចទទួលបាន និងប្រើប្រាស់សិទ្ធិនេះហួសដែនកំណត់ និងរហូតបង្កភាពអនាធិបតេយ្យនោះដែរ។

ដោយសារតែបែបនេះហើយ ទើបក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីដែនកំណត់នៃសិទ្ធិនេះក្នុងករណីដែលការប្រើប្រាស់សិទ្ធិលើសលុបនោះ អាចនាំទៅរកការប្រាសចាកពីសីលធម៌សង្គម ក៏ដូចជាកើតមាននូវអសន្តិសុខក្នុងសង្គមជាតិជាដើម។ ជាក់ស្តែងនៅខាងក្រោមនេះ ខ្ញុំបាទនឹងបន្តលើកឡើងពាក់ព័ន្ធនឹងផ្នែកសំខាន់នៃកិច្ចការស្រាវជ្រាវនេះ ពោលគឺបទល្មើសក្នុងផ្នែក "**ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស**"។

## ផ្នែកទី១៖ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទញុះញង់ឱ្យមានការរើសអើង

ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បទល្មើសដែលកើតចេញពីការញុះញង់មានច្រើនមាត្រាមានដូចជាបទញុះញង់ឱ្យបោះបង់ទារក (មាត្រា ៣២៦), បទញុះញង់អនីតិជនឱ្យបរិភោគគ្រឿងស្រវឹង (មាត្រា ៣៤៣), បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម (មាត្រា ៣៤៥), បទញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ (មាត្រា ៤៦៤), បទញុះញង់ឱ្យយោធិនចូលបម្រើរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស (មាត្រា ៤៦៨), បទញុះញង់កុំឱ្យយោធិនស្តាប់បង្គាប់ (មាត្រា ៤៧១), បទញុះញង់ឱប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ (មាត្រា ៤៩៥) និងបទញុះញង់ឱ្យមានការរើសអើង (មាត្រា ៤៩៦) ជាដើម-ល-។ នៅក្នុងបទល្មើសដូចបានលើកឡើងខាងលើ មានបទល្មើសខ្លះតម្រូវឱ្យមានការប៉ុនប៉ង ឬបទល្មើសបានសម្រេចទើបអាចផ្តន្ទាទោសបាន ហើយបទល្មើសខ្លះទៀតប្រសិនបើពុំបានសម្រេចផលទេត្រូវផ្តន្ទាទោសស្រាល ឬត្រឹមបទមជ្ឈិមប៉ុណ្ណោះ តែបើការញុះញង់នោះបានសម្រេចផលនាំឱ្យច្បាប់ផ្តន្ទាទោសធ្ងន់ធ្ងរតែម្តង ហើយបទល្មើសខ្លះទៀតមិនទាមទារការ

---

[26] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

សម្រេចផល ឬតម្រូវឱ្យការញុះញង់នោះមានប្រសិទ្ធិភាពឡើយ ក៏ច្បាប់អាចចោទប្រកាន់ និងផ្តន្ទាទោសបានដូចគ្នា។ ជាក់ស្តែងក្នុងគន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ ជំពូកទី៣ ការប៉ះពាល់ដល់សន្តិសុខសាធារណៈ ផ្នែកទី៣ លើកឡើងអំពីការញុះញង់ឱ្យប្រព្រឹត្តបទល្មើស ដែលជាចំណុចសំខាន់នៃប្រធានបទកិច្ចការស្រាវជ្រាវនេះ ត្បិតបទល្មើសដែលកើតមានក្នុងផ្នែកនេះ គេសង្កេតឃើញមានការចោទប្រកាន់ច្រើនពីសំណាក់អង្គការអយ្យការ ជាពិសេសបទល្មើសក្នុងផ្នែកនេះក៏មានផ្សារភ្ជាប់ទៅនឹងរបបសារព័ត៌មានទៅទៀត ដែលកន្លងមកធ្លាប់មានជាការលើកឡើងក្រៅផ្លូវការថា សារព័ត៌មានគឺជាអំណាចទី៤ ក្រៅពីអំណាចធំៗទាំងបីដែលយើងទទួលស្គាល់នាពេលបច្ចុប្បន្នរួមមាននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ។ បន្តទៅទៀតនេះ យើងនឹងសិក្សាទៅលើបទល្មើសចំនួន ២ រួមមានបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ដែលមានចែងក្នុងមាត្រា ៤៩៥ និងបទញុះញង់ឱ្យមានការរើសអើង មានចែងក្នុងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

## ១.១ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍

### ១.១.១ និយមន័យ

បើតាមឯកសារគោល ពោលគឺវចនានុក្រមខ្មែរ ញុះញង់ មានន័យថា ញុះញយៗ គឺនិយាយចាក់រុកនាំអុចអាលឱ្យអ្នកដទៃធ្វើការអ្វីៗដែលមិនគប្បី ឱ្យឈ្លោះទាស់ទែងគ្នា ឱ្យបាក់បែកគ្នា។[27] ដោយឡែក សម្រាប់ន័យធម្មតា គេអាចយល់បានថាការញុះញង់ គឺជាការបញ្ចុះបញ្ចូលចិត្តឱ្យអ្នកណាម្នាក់ធ្វើអ្វីមួយដើម្បីឱ្យសម្រេចតាមគោលបំណងដែលចង់បាន ដែលភាគច្រើនក្នុងគោលបំណងអាក្រក់។ ក្នុងន័យច្បាប់ ការញុះញង់គឺជាការផ្តើមគំនិត ជំរុញ ពន្យុះ លើកទឹកចិត្ត ធ្វើយ៉ាងណាឱ្យបុគ្គលណាមួយប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តល្មើសអាជ្ញា។ បទឧក្រិដ្ឋ សំដៅទៅលើទោសទាំងឡាយណាដែលអតិបរមានៃទោសត្រូវរងជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ[28]។ ឧទាហរណ៍នៅក្នុងករណីដែលបុគ្គលម្នាក់ប្រព្រឹត្តអំពើដឹកនាំកុបកម្ម ដែលនៅក្នុងច្បាប់ព្រហ្មទណ្ឌ បទដឹកនាំកុបកម្ម តម្រូវឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ២០ឆ្នាំទៅ ៣០ឆ្នាំ ដូច្នេះនាំឱ្យ បទដឹកនាំកុបកម្ម[29]នេះ ស្ថិតក្នុងចំណាត់ថ្នាក់ជាប្រភេទនៃបទឧក្រិដ្ឋ។ ដោយឡែក ពាក្យ "អាទិ៍"[30] បើតាមវចនានុក្រមខ្មែរ មានន័យថា ដើម ខាងដើម ដើមដំបូង ការផ្តួចផ្តើមមុន ឧទាហរណ៍: មានដូច្នេះជាអាទិ៍ គឺមានដូច្នេះជាដើម។ សរុបជារួម ការញុះញង់ឱ្យប្រព្រឹត្ត

[27] វចនានុក្រមខ្មែរ ទំព័រ២៩៦ ចេញផ្សាយដោយពុទ្ធសាសនាបណ្ឌិត្យ ឆ្នាំ១៩៦៨

[28] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[29] មាត្រា ៤៥៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[30] វចនានុក្រមខ្មែរ ទំព័រ១៧២៩ ចេញផ្សាយដោយពុទ្ធសាសនាបណ្ឌិត្យ ឆ្នាំ១៩៦៨

បទឧក្រិដ្ឋជាអាទិ៍ មានន័យថាជាអំពើផ្តើមគំនិត ជំរុញ ពន្យុះ លើកទឹកចិត្ត ធ្វើយ៉ាងណាឱ្យបុគ្គលណាមួយប្រព្រឹត្តបទល្មើសទាំងឡាយដែលស្ថិតក្នុងកម្រិតដែលច្បាប់ចែងទុកជាបទឧក្រិដ្ឋ។

តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា តុលាការអាចចោទប្រកាន់ និងផ្តន្ទាទោសទៅលើជនណាដែលបានប្រព្រឹត្តអំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងក្នុងមាត្រា ៤៩៤ អំពីលក្ខខណ្ឌអត្ថិភាព ឬលក្ខខណ្ឌដែលនាំឱ្យឈានដល់ការចោទប្រកាន់ពីអំពើញុះញង់ ដោយមាត្រានេះក៏បានបញ្ជាក់ភ្ជាប់ជាមួយថា ការចោទប្រកាន់ និងផ្តន្ទាទោសដោយអំពើនេះនូវតែមាន ទោះបីជាការញុះញង់នេះគ្មានប្រសិទ្ធភាពក៏ដោយ។ កត្តានេះអាចបង្ហាញឱ្យឃើញថា នីតិនិពន្ធរបស់កម្ពុជាបានគិតគូរជាមុន នូវការរារាំងកុំឱ្យមាននូវគោលបំណងទុច្ចរិតក្នុងគោលដៅនាំឱ្យមានភាពវឹកវរធ្ងន់ធ្ងរក្នុងសង្គមជាតិ។ កន្លងមក តែងមានមតិលើកឡើងថាបទល្មើសញុះញង់នេះមានលក្ខណៈតឹងរ៉ឹងហួសហេតុ ដែលអាចនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ឬអាចនាំឱ្យមានការធ្លាក់ចុះនូវសេរីភាពរបស់ពលរដ្ឋ។ មូលហេតុចំបងដែលគេឃើញមានយល់ច្រឡំថាបទល្មើសនេះមានលក្ខណៈរឹតត្បិត និងប៉ះពាល់ដល់ការនិយាយស្តី បង្ហាញមតិក្នុងសង្គម ក៏ដោយសារតែមានការប្រើប្រាស់ពាក្យសំដី និងរូបភាពមួយចំនួនដែលមានលក្ខណៈញុះញង់ ដោយបុគ្គលនោះពុំបានពិចារណា និងសិក្សាលម្អិតជាក់ស្តែង និងយល់ច្រលំថានោះគឺជាសិទ្ធិសេរីភាពទូទៅរបស់ពលរដ្ឋដែលអាចប្រើប្រាស់បានក្នុងសង្គម។

ប៉ុន្តែយ៉ាងណាក៏ដោយ បុគ្គលសំខាន់ៗដែលបានរួមចំណែកតាក់តែង ចងក្រង ប្រមូលផ្តុំឱ្យមានក្រមព្រហ្មទណ្ឌបានមើលឃើញជាមុនអំពីព្យសនកម្ម ផលប៉ះពាល់ និងភាពវឹកវរធ្ងន់ធ្ងរក្នុងសង្គមជាតិដែលអាចកើតមានឡើង ប្រសិនណាបើច្បាប់ពុំបានបង្ការ និងចែងហាមឃាត់ទៅលើទង្វើនោះជាមុនទេ។ ប្រាកដណាស់ ធាតុផ្សំសំខាន់បំផុតនៃបទល្មើសមួយក្នុងចំណោមធាតុផ្សំទាំងបីដែលមិនអាចខ្វះបាននោះគឺ ធាតុផ្សំសត្យានុម័ត ឬធាតុច្បាប់ ដែលបានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចត្រូវផ្តន្ទាទោសបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[31]។ ដូច្នេះប្រាកដណាស់ ច្បាប់ត្រូវតែប្បញ្ញត្តិទុកជាមុននូវមាត្រានេះ ដើម្បីជាការព្រមានជាមុនទៅកាន់ជនទាំងឡាយឱ្យបានយល់ដឹងថា រាល់ការញុះញង់ទាំងឡាយដែលមានបំណងឱ្យជនណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋណាមួយនោះ គឺត្រូវតែទទួលរងនូវការផ្តន្ទាទោសជាដាច់ខាត បើទោះបីជាការញុះញង់នោះគ្មានប្រសិទ្ធិភាពក៏ដោយ។ ចំណុច

[31] មាត្រា ៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

នេះ បើតាមការបកស្រាយកន្លងមករបស់ឯកឧត្តម ហ៊ី សោភា កន្លងមក[32]បានបញ្ជាក់ថា នេះគឺជាបទល្មើសឯករាជ្យ ដែលមានន័យថាមិនចាំបាច់ទាល់តែបទល្មើសបានសម្រេចផល ឬមានការប៉ុនប៉ងទើបតម្រូវឱ្យអ្នកញុះញង់ទទួលខុសត្រូវឡើយ។ ឧទាហរណ៍៖ បុគ្គលម្នាក់នៅក្នុងសកម្មភាពបាតុកម្មមួយបានប្រើប្រាស់ពាក្យសំដីញុះញង់ និងជំរុញបាតុករឱ្យប្រព្រឹត្តអំពើសម្រុកទៅកាន់កាប់ និងបំផ្លិចបំផ្លាញស្ថាប័នសាធារណៈណាមួយ។ ករណីនេះយើងឃើញច្បាស់ណាស់ថាបុគ្គលដែលជាអ្នកញុះញង់បានប្រើប្រាស់ពាក្យសំដីញុះញង់ដោយផ្ទាល់នៅក្នុងទីកន្លែងសាធារណៈ ដែលជំរុញឱ្យមាននូវសកម្មភាពកុបកម្ម។ តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា កុបកម្ម គឺជាអំពើហិង្សាជាសមូហភាព ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ[33]។ ចលនាកុបកម្ម ដោយការបំផ្លិចបំផ្លាញ កាន់កាប់អគារ ឬបនីយកណ្ឋដោយកម្លាំង ឬកលល្បិច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ ដោយថេរវេលានៃការផ្តន្ទាទោសនេះត្រូវបានចាត់ថ្នាក់ថាជាបទឧក្រិដ្ឋ។

ដោយឡែក ក្នុងឧទាហរណ៍ជាក់ស្តែងមួយទៀតនាពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ឬហៅកាត់ខ្លីថាច្បាប់កូវីដ-១៩ ដែលទើបត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១កន្លងទៅ ក៏មានបទប្បញ្ញត្តិមាត្រាមួយចំនួនបានចែងទុកអំពើល្មើសមួយចំនួនជាបទឧក្រិដ្ឋផងដែរ។ ក្នុងរូបភាពមួយផ្សេងទៀត ដែលពាក់ព័ន្ធទៅនឹងច្បាប់ខាងលើ កាលៈទេសៈដែលបច្ចេកវិទ្យាបច្ចុប្បន្នមានការរីកចម្រើន បុគ្គលម្នាក់បានផ្សព្វផ្សាយតាមបណ្តាញសង្គមក្នុងន័យបង្កភាពជ្រួលច្របល់ និងការភ័យខ្លាចដល់ប្រជាពលរដ្ឋ ឬជាពិសេសអ្នកដែលមានវិជ្ជមានកូវីដ-១៩ ឱ្យគេចវេសចេញពីការទទួលសេវាព្យាបាលរបស់អាជ្ញាធរផ្នែកសុខាភិបាល ដោយនិយាយថាសេវាសុខាភិបាលរបស់រដ្ឋមានភាពទន់ខ្សោយ ហើយអ្នកសម្រាកព្យាបាលប្រឈមនឹងអត្រាស្លាប់បាត់បង់ជីវិតខ្ពស់។ ឧទាហរណ៍ដែលបានលើកឡើងខាងលើនេះ ពិតណាស់វាជាករណីញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ត្បិតការប្រើប្រាស់ពាក្យសំដីខាងលើប្រាកដណាស់ថាវាមានលក្ខណៈញុះញង់ និងនាំឱ្យមានភាពរីករាលធ្ងន់ធ្ងរដល់សង្គមជាតិ ដែលជម្រុញទឹកចិត្តឱ្យជនដែលមានវិជ្ជមានកូវីដ-១៩ គេចវេសចេញមិនទទួលការព្យាបាល ដែលអាចនាំឱ្យមានការចម្លងជំងឺនេះទៅអ្នកដទៃ ដែលតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត តម្រូវឱ្យមានការផ្តន្ទាទោសជាបទឧក្រិដ្ឋ ដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០

[32] ការការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៤

[33] មាត្រា ៤៥៦ នៃក្រមព្រហ្មទណ្ឌ

ឆ្នាំ[34]។ ក្នុងឧទាហរណ៍ទាំងពីរដែលបានលើកឡើងខាងលើ ក្នុងករណីមានការប្រព្រឹត្តអំពើញុះញង់ដោយផ្ទាល់ ដោយមធ្យោបាយណាមួយដូចមានចែងក្នុងលក្ខខណ្ឌអត្ថិភាពនៃការញុះញង់ (មាត្រា៤៩៤) ប៉ុន្តែការញុះញង់គ្មានប្រសិទ្ធិភាពនោះទេ តុលាការអាចចោទប្រកាន់ជននោះពីបទល្មើសញុះញង់នេះបាន ប៉ុន្តែប្រសិនបើអំពើញុះញង់នោះបង្កឱ្យមានបទល្មើសកើតឡើង នោះជនល្មើសត្រូវទទួលការចោទប្រកាន់ក្នុងនាមអ្នកផ្ដើមគំនិតវិញ មិនមែនជាអ្នកញុះញង់ទៀតឡើយ។ ដូច្នេះជារួមមក ការផ្តន្ទាទោសបទល្មើសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ មានគោលបំណងក្នុងការបង្ការ កុំឱ្យបុគ្គលណាម្នាក់មានការព្យាយាមបង្កអំពើអសន្តិសុខ និងការបង្កភាពវឹកវរក្នុងសង្គមជាតិដែលនាំឱ្យមានភាពអសណ្ដាប់ធ្នាប់ ឬនាំឱ្យមានការខូចខាតធ្ងន់ធ្ងរជាដើម។

### ១.១.២ ទោសដែលត្រូវអនុវត្ត

ក្រមព្រហ្មទណ្ឌបានចែងផ្តន្ទាទោសបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តម្រូវឱ្យមានការដាក់ពន្ធនាគារចាប់ពី ៦ខែទៅ ២ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ១លានរៀលទៅ ៤លានរៀល[35] ដែលយើងឃើញបទល្មើសនេះត្រូវចាត់ចូលជាបទមជ្ឈិមប៉ុណ្ណោះ។ យើងឃើញថា ការផ្តន្ទាទោសមានលក្ខណៈស្រាល ក្នុងគោលបំណងអប់រំ និងផ្តល់ការកែប្រែជននោះ ដើម្បីឆាប់ទទួលបាននីតិសម្បទាចូលទៅរស់នៅក្នុងសង្គមឡើងវិញ។ មែនទែនទៅ! ក្នុងក្រមព្រហ្មទណ្ឌក៏មានចែងអំពីការប្រព្រឹត្តអំពើញុះញង់ផ្សេងៗទៀតដែរ ហើយបទល្មើសញុះញង់មួយចំនួនច្បាប់បានកំណត់ផ្តន្ទាទោសធ្ងន់ធ្ងរជាងបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ទៅទៀត ដូចជាបទញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ ដោយតម្រូវឱ្យមានការដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ១០លានរៀល[36]។ ជាងនេះទៅទៀត អំពើញុះញង់ដទៃទៀតដូចជា បទញុះញង់ឱ្យយោធិនចូលបម្រើរដ្ឋបរទេស ឬភ្នាក់ងារបរទេស ក្រមព្រហ្មទណ្ឌបានចាត់ទុកបទល្មើសនេះជាបទឧក្រិដ្ឋតែម្តង ដោយផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី ៥ឆ្នាំ ទៅ១០ឆ្នាំ[37]។ ចំណុចបន្ទាប់ យើងនឹងសិក្សាទៅលើបទល្មើសមួយទៀតក្នុងផ្នែកនេះដែរ នោះគឺ "បទញុះញង់ឱ្យមានការរើសអើង"។

## ១.២ បទញុះញង់ឱ្យមានការរើសអើង

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទង

[34] មាត្រា ៩ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

[35] មាត្រា ៤៩៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[36] មាត្រា ៤៦៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[37] មាត្រា ៤៦៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ។ ការប្រើប្រាស់សិទ្ធិ សេរីភាពនេះ ត្រូវបានប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់[38]។

ដោយឡែក បើតាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ការអំពាវនាវណានាំឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់នាំឱ្យកើតមានការរើសអើង ការប្រទូស្តរ៉ាយ ឬហិង្សា ត្រូវបានហាមឃាត់ដោយច្បាប់[39]។ ក្នុងក្រមព្រហ្មទណ្ឌក៏បានហាមឃាត់ចំពោះការញុះញង់នាំឱ្យមានការរើសអើងនេះដូចគ្នា ត្បិតប្រទេសកម្ពុជាប្រកាន់យកលទ្ធិប្រជាធិបតេយ្យ មានប្រជាជនរស់នៅចម្រុះជាតិសាសន៍ ព្រមទាំងប្រកាន់ជំនឿសាសនាផ្សេងគ្នា។ ទោះបីជាកម្ពុជា ប្រកាន់យកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ[40]ក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលជានិច្ចកាលតែងតែប្រកាន់យកនូវគោលការណ៍សុខដុមនីយកម្មសាសនា ដើម្បីឱ្យសង្គមជាតិទាំងប្រមូលប្រកបដោយសន្តិភាព ចីរភាព និងអភិវឌ្ឍន៍ទៅមុខ។ ដូច្នេះហើយទើបនីតិនិពន្ធខ្មែរបានប្បញ្ញត្តិនូវមាត្រានេះ ដើម្បីបង្ការទុកជាមុនក្នុងគោលបំណងជៀសវាងនូវការញុះញង់ឱ្យមានការរើសអើង ដែលអាចនាំឱ្យឈានទៅដល់អំពើហិង្សា និងភាពវឹកវរក្នុងសង្គមជាតិ។

### ១.២.១ និយមន័យនៃការញុះញង់ឱ្យមានការរើសអើង

ការញុះញង់ឱ្យមានការរើសអើង គឺជាអំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមព្រហ្មទណ្ឌ ឱ្យប្រព្រឹត្តការរើសអើង គុំកួន ឬហិង្សាចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬ នៃសាសនាណាមួយជាកំណត់[41]។ បទល្មើសញុះញង់ឱ្យមានការរើសអើងមិនតម្រូវឱ្យមានផលសម្រេច ឬការប៉ុនប៉ងដើម្បីចោទប្រកាន់ឡើយ ពោលគឺតុលាការអាចចោទប្រកាន់បានតែម្តងនៅពេលដែលបុគ្គលណាម្នាក់បានចាប់ផ្តើមប្រព្រឹត្តអំពើញុះញង់តាមលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងបីនៃមាត្រា ៤៩៤។ ពីដើមមក បទល្មើសនេះគេមិនសូវឃើញមានការចោទប្រកាន់ណាមួយកើតឡើងណាស់ ប៉ុន្តែមួយរយៈចុងក្រោយពោលគឺចាប់តាំងពីប្រព័ន្ធបណ្តាញសង្គមត្រូវបានគេប្រើប្រាស់ច្រើន និង

[38] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[39] វាក្យខណ្ឌទី២ មាត្រា ២០ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

[40] មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[41] មាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

មានភាពទូលំទូលាយក្នុងសង្គម បទល្មើសនេះចាប់ផ្តើមកើតមានជាបន្តបន្ទាប់ ហើយក៏មានបុគ្គលជាច្រើនហូរហែរត្រូវបានផ្តន្ទាទោសដោយសារការញុះញង់ឱ្យមានការរើសអើងក្នុងសង្គម។

មុននឹងលើកយកឧទាហរណ៍ក្នុងទិដ្ឋភាពសង្គមកម្ពុជាមកបរិយាយក្នុងចំណុចនេះ យើងទៅចាប់អារម្មណ៍បទល្មើសញុះញង់ឱ្យមានការរើសអើងនេះ នៅក្នុងបរិបទសង្គមបរទេសបន្តិចសិន។ កាលពីអំឡុងខែមីនា ឆ្នាំ២០២១ នេះ នៅក្នុងប្រទេសបារាំង មានប្រជាពលរដ្ឋសញ្ជាតិបារាំង ដើមកំណើតអាស៊ីជាច្រើន បានមកប្រមូលផ្តុំគ្នានៅក្បែរទីតាំងតុលាការក្រុងប៉ារីស (Paris) ដើម្បីតវ៉ា និងទាមទារឱ្យមានការដាក់ទោសធ្ងន់ធ្ងរទៅលើជនជាតិបារាំងចំនួន ៥នាក់ ដែលបានប្រើប្រាស់ពាក្យសំដីញុះញង់ អុចអាលឱ្យមានអំពើហិង្សាទៅលើប្រជាជនដើមកំណើតអាស៊ី ជាពិសេសទៅលើជនជាតិចិនតែម្តង ក្រោយពីប្រទេសបារាំងបានប្រកាសបិទខ្ទប់ប្រទេសដើម្បីបង្ការការរាលដាលជំងឺកូវីដ-១៩[42]។ ប្រជាជនដើមកំណើតអាស៊ីជាច្រើននាក់ដែលមិនមែនមានតែជនជាតិចិនប៉ុណ្ណោះទេ ក្នុងនោះក៏មានជនជាតិកូរ៉េ វៀតណាម រួមទាំងកម្ពុជាផងបានបង្ហាញការមិនពេញចិត្ត និងខឹងសម្បារ ចំពោះសារស្អប់ខ្ពើម រើសអើងទៅលើជនជាតិអាស៊ីនេះ ដែលការតវ៉ាបង្កជាភាពវឹកវរក្នុងសង្គម និងជាផលលំបាកមួយផងដែរសម្រាប់រដ្ឋាភិបាលកំឡុងពេលដែលកូវីដ-១៩ កំពុងតែរាតត្បាតពិភពលោក ក៏ដូចជាប្រទេសបារាំងទាំងមូល។ ដោយឡែក នៅសហរដ្ឋអាមេរិកឯណោះវិញ បើទោះបីជាមិនមានការប្រើប្រាស់ពាក្យសំដី សារ គំនូរ សំណេរ ឬ ការញុះញង់តាមមធ្យោបាយទូរគមនាគមន៍ណាមួយក៏ដោយ ក៏បញ្ហានៃការរើសអើងពូជសាសន៍ ជាតិពន្ធុជាដើម នៅតែជាបញ្ហាចោទឡើងក្នុងសង្គមនៃប្រទេសជឿនលឿនមួយនេះ។ យុទ្ធនាការ "Black Live Matter" ដែលជាការទាមទារឱ្យបញ្ឈប់ការរើសអើង និងទាមទារឱ្យផ្តល់នូវសមភាពស្មើគ្នាទៅដល់ប្រជាជនអាមេរិកស្បែកខ្មៅ រហូតដល់មានការបាតុកម្មតវ៉ាតាមបណ្តារដ្ឋធំៗជាច្រើន និងបង្កជាអំពើកុបកម្ម ដុតបំផ្លាញអគារ ទីតាំងឯកជនជាច្រើនថែមទៀតផង ដែលករណីទាំងអស់ដូចដែលបានលើកឡើងខាងលើ កើតចេញពីការញុះញង់ ក៏ដូចជាស្មារតីរើសអើងរបស់ប្រជាពលរដ្ឋក្នុងសង្គមជាតិនៃបណ្តាប្រទេសនីមួយៗ។ នៅមានឧទាហរណ៍ជាច្រើន ដែលបង្ហាញពីទម្រង់នៃការរើសអើងផ្សេងៗទៀត ដែលខ្ញុំសុំមិនលើកយកមកនិយាយបន្ថែមនៅក្នុងកិច្ចការស្រាវជ្រាវនេះឡើយ។

ត្រឡប់មកកាន់បរិបទច្បាប់កម្ពុជាវិញ ការញុះញង់ឱ្យមានការរើសអើង គឺជាអំពើញុះញង់ទាំងឡាយដែលនាំឱ្យមានការរើសអើង គុំកួន ហិង្សាលើបុគ្គលម្នាក់ ឬមនុស្សមួយក្រុម ដោយមូលហេតុដូចដែលបានលើកឡើងពីខាងដើមនៃចំណុចនេះ។ ឧទាហរណ៍៖ ក្រោយពីមានបព្វជិតសាសនាមួយក្រុមបាននាំគ្នាទៅតាំងទីសក្ការៈសាសនារបស់ខ្លួនក្នុងឃុំមួយ ហើយក្រោយមកឃុំខាងលើនោះបានជួបរាំងស្ទួតខុសប្លែកធម្មតា ហើយក្រោយ

[42] ការផ្សាយរបស់គេហទំព័រវិទ្យុបារាំងអន្តរជាតិ RFI ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

មកមានបុគ្គលម្នាក់ដោយក្ដីខឹងសម្បារបានប្រកាសខ្លាំងៗក្នុងការជួបជុំមនុស្សក្នុងឃុំនោះថា បញ្ហាទាំងអស់ដែលឃុំកំពុងកើតមានគឺដោយសារតែបព្វជិតសាសនាថ្មីមួយក្រុមនោះចូលមក បណ្ដាលឱ្យប្រជាជនទាំងអស់មានការគុំកួនលើបព្វជិតសាសនាទាំងនោះជាខ្លាំង។ ករណីដូចក្នុងឧទាហរណ៍ខាងលើ បុគ្គលនោះបានប្រព្រឹត្តអំពើញុះញង់ឱ្យមានការរើសអើង ដោយប្រើប្រាស់ពាក្យសំដី ក្នុងទីកន្លែងសាធារណៈ បណ្ដាលឱ្យមានការគុំកួនលើក្រុមមនុស្សដទៃដោយមូលហេតុក្រុមមនុស្សនោះជាក្រុមមនុស្សកាន់សាសនាដទៃ។ ករណីមួយទៀតដែលធ្លាប់កើតមានឡើង បុគ្គលម្នាក់បានបង្ហោះវីដេអូមួយតាមបណ្ដាញសង្គមដោយបានប្រើពាក្យពេចន៍ប្រមាថទៅលើជាតិសាសន៍ ដែលក្រោយមកក៏នាំឱ្យមានការចោទប្រកាន់ពីតុលាការពីបទញុះញង់ឱ្យមានការរើសអើងផងដែរ។ បទល្មើសនេះ ក្រមព្រហ្មទណ្ឌបានចែងផ្ដន្ទាទោសធ្ងន់ជាងបទល្មើសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ទៅទៀត ដែលតាមការស្វែងយល់ និងពិចារណាទៅទំនងជាការញុះញង់ឱ្យមានការរើសអើងនេះ វាអាចនឹងជះឥទ្ធិពលអាក្រក់ និងភាពរីករាលដល់សង្គមយូរអង្វែង ជាពិសេសបញ្ហាសុខសន្តិភាពរវាងជាតិសាសន៍មួយ និងជាតិសាសន៍មួយ សុខដុមនីយកម្មរវាងសាសនាមួយ និងសាសនាមួយទៀតជាដើម ត្បិតកន្លងមកការរើសអើងសាសនាក៏ធ្លាប់បង្កទៅជាសង្គ្រាមសាសនារ៉ាំរ៉ៃនៅតាមបណ្ដាប្រទេសមួយចំនួននៅក្នុងពិភពលោកផងដែរ។

**១.២.២ ទោសដែលត្រូវអនុវត្ត**

បទញុះញង់ឱ្យមានការរើសអើង ក្នុងក្រមព្រហ្មទណ្ឌតម្រូវឱ្យមានការផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ២លានរៀល ទៅដល់ ៦លានរៀល។ ដូច្នេះផ្អែកតាមអតិបរមានៃទោសដាក់ពន្ធនាគារនេះ បទញុះញង់ឱ្យមានការរើសអើងស្ថិតក្នុងកម្រិតបទល្មើសមជ្ឈិមប៉ុណ្ណោះ។ ប៉ុន្តែថ្វីបើស្ថិតក្នុងកម្រិតបទមជ្ឈិមដូចទៅនឹងបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ក៏ដោយ ប៉ុន្តែយើងឃើញថាអតិបរមា និងអប្បបរមានៃទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់នៃបទល្មើសនេះ មានកម្រិតខ្ពស់ជាងអតិបរមា និងអប្បបរមានៃទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់នៃបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ហើយដូចដែលបានលើកឡើងខាងលើ ទំនងជាក្រុមការងារស្រាវជ្រាវ គាត់តែងក្រមព្រហ្មទណ្ឌរបស់កម្ពុជយល់ឃើញថា អំពើញុះញង់ឱ្យមានការរើសអើងនេះអាចបង្កឱ្យមានព្យសនកម្ម និងភាពរីករាលធ្ងន់ធ្ងរក្នុងសង្គមជាតិ ប្រសិនបើការញុះញង់នោះបានសម្រេចផល។ ដូច្នេះដើម្បីបង្ការជាមុនកុំឱ្យកើតមាននូវបាតុភាពទាំងនោះ ច្បាប់បានកម្រិតនូវអប្បបរមា និងអតិបរមានៃទោសឱ្យមានកម្រិតខ្ពស់ដើម្បីឱ្យពលរដ្ឋមានការខ្លាចរអារ ញញើតច្បាប់ មិនហ៊ានប្រព្រឹត្តអំពើបំពានដែលនាំឱ្យកើតមាននូវបទល្មើស។

**១.៣. ទោសបន្ថែមដែលអាចប្រកាស**

ក្រៅពីមូលទោសដែលរួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ បទល្មើសទាំងពីរដែលបានសិក្សាខាងលើក៏មាននូវទោសបន្ថែមដែលអាចត្រូវប្រកាសផងដែរ។ តាមក្រមព្រហ្មទណ្ឌកម្ពុជា ចំពោះជន

ដែលប្រព្រឹត្តបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទញុះញង់ឱ្យមានការរើសអើង តុលាការក៏អាច ប្រកាសទោសបន្ថែមមួយ ឬច្រើន បន្ថែមពីលើមូលទោសបានទៀតផង[43]។ ទោសបន្ថែមដែលតុលាការអាច ប្រកាសបានរួមមាន៖

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

២. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

៣. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ខែយ៉ាងច្រើន។

៤. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៥. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈ ពេល ៨ថ្ងៃយ៉ាងច្រើន។

ផ្នែកបន្តទៅទៀតនេះ យើងនឹងធ្វើការសិក្សាទៅដល់ចំណុចសំខាន់មួយទៀត ដែលនិយាយអំពី "**អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន**" ដែលមាននៅក្នុងច្បាប់ដោយឡែកមួយផ្សេងទៀត ពោលគឺ "**ច្បាប់ស្តីពីរបបសារព័ត៌មាន**"។

## ផ្នែកទី២៖ ការញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

នៅក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា បានចែងការពារនូវសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ ជាពិសេសទៅការប្រើប្រាស់ខ្លឹមសារ ពាក្យពេជន៍ សំណេររបស់អ្នកប្រកប អាជីពក្នុងវិស័យសារព័ត៌មាន ហើយក៏បានបង្ហាញអំពីដែនកំណត់នៃការប្រើប្រាស់សិទ្ធិនេះផងដែរ ពោលគឺសិទ្ធិ នេះមិនអាចប៉ះពាល់ទៅលើអ្នកដទៃ ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់របស់សង្គមជាតិបានឡើយ។ អ្នកសារ ព័ត៌មានទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបបសារព័ត៌មាន និងប្រតិបត្តិតាមច្បាប់ស្តីពីរបបសារព័ត៌មា ន។

### ២.១. ទំនួលខុសត្រូវរបស់សារព័ត៌មានចំពោះច្បាប់ស្តីពីរបបសារព័ត៌មាន

ច្បាប់ស្តីពីរបបសារព័ត៌មាន មានគោលបំណងកំណត់របបសារព័ត៌មាននិងធានារ៉ាប់រងសេរីភាពសារ ព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឱ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា[44]។ ការបោះពុម្ពផ្សព្វផ្សាយនូវព័ត៌មានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ពេលប្រជុំ

[43] សូមមើលមាត្រា ៤៩៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[44] មាត្រា ៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយ មិនអាចត្រូវបានផ្តន្ទាទោសឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត។[45] អ្នកសារព័ត៌មានមានសិទ្ធិទទួល និងចុះផ្សាយព័ត៌មានទាំងឡាយទៅកាន់សាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួន ក៏ប៉ុន្តែយ៉ាងណាក្តី ច្បាប់ក៏បានហាមឃាត់ផងដែរ រាល់ការចុះផ្សាយនូវព័ត៌មានប្រភេទណាដែលអាចបណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ អន្តរាយដល់ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសដទៃ ឬការបំពានលើសិទ្ធិបុគ្គលណាម្នាក់ រាប់ទាំងសំណុំរឿងពេទ្យ សំណុំឯកសារមន្ត្រីរាជការ ឯកសារផ្លូវការ និងឯកសារសម្ងាត់ដទៃទៀត ឬព័ត៌មានដែលមានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ ដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវណាមួយ និងការលាតត្រដាងនូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ញា ឬការត្រួតពិនិត្យរបស់ស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងមិនអាចចុះផ្សាយនូវព័ត៌មានទាំងឡាយណាដែលអាចប៉ះពាល់ដល់ការជំនុំជំរះក្តីប្រកបដោយយុត្តិធម៌ ឬព័ត៌មានណាមួយដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មន្ត្រីដែលចុះអនុវត្តច្បាប់ ឬបំពេញបេសកកម្មរបស់ខ្លួន[46]។ ដោយឡែក ពាក់ព័ន្ធទៅនឹងកិច្ចការស្រាវជ្រាវផ្នែកនេះដែលនិយាយពី "ការញុះញង់តាមផ្លូវសារព័ត៌មាន" ច្បាប់ស្តីពីរបបសារព័ត៌មានក៏បានប្បញ្ញត្តិយ៉ាងច្បាស់ដែរថា អ្នកសារព័ត៌មានទាំងអស់មានកាតព្វកិច្ចជៀសវាងការផ្សព្វផ្សាយនូវព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត[47]។ តាមរយៈការបរិយាយខាងលើបានសបញ្ជាក់ឱ្យឃើញថា អ្នកសារព័ត៌មានទទួលបានសិទ្ធិយ៉ាងទូលំទូលាយសម្រាប់ការទទួលបានព័ត៌មាន និងចុះផ្សាយនូវដំណឹងទាំងនោះ ប៉ុន្តែយ៉ាងណាក៏ដោយ សិទ្ធិដែលទទួលបានការការពារដោយច្បាប់ដោយឡែកនេះក៏មានដែនកំណត់ផងដែរ ពោលប្រសិនបើអ្នកសារព័ត៌មានប្រព្រឹត្តខុសទៅនឹងច្បាប់របស់រដ្ឋ ក៏នៅតែត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដូចប្រជាពលរដ្ឋធម្មតាដែរ ដែលការទទួលខុសត្រូវទាំងនោះរាប់បញ្ចូលទាំងការខុសត្រូវផ្នែករដ្ឋប្បវេណី និងការទទួលខុសត្រូវព្រហ្មទណ្ឌ។

## ២.២ អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

### ២.២.១ និយមន័យ

យោងតាមវចនានុក្រមខ្មែរ របស់**សម្តេចព្រះសង្ឃរាជ ជួន ណាត** ព័ត៌មាន មានន័យថាជាប្រព្រឹត្តការណ៍ដំណឹងផ្សេងៗក្នុងបច្ចុប្បន្នកាល ហើយបើយើងបន្ថែមពាក្យ សារ មានន័យថាព័ត៌មានដ៏មានសារៈ គឺកាសែតប្រាប់ដំណឹងដែលគួរអាន គួរដឹង។ មកដល់បច្ចុប្បន្ននេះ ព័ត៌មានត្រូវបានចែកចាយយ៉ាងទូលំទូលាយ

[45] កថាខណ្ឌទី១ មាត្រា ៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥
[46] វាក្យខណ្ឌទី១ មាត្រា ៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥
[47] វាក្យខណ្ឌទី៣ មាត្រា ៧ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

និងឆាប់រហ័ស ដែលមិនមែនត្រឹមតែតាមរយៈកាសែតដូចមុនឡើយ ពោលគឺមានទាំងវិទ្យុ ទូរទស្សន៍ ជាដើម-ល-ហើយកាន់តែមានភាពឆាប់រហ័សសម្រាប់ការជូនដំណឹងទៅកាន់ប្រជាជនទូទៅ ដោយបច្ចេកវិទ្យាកាន់តែរីកចំរើនឡើង ព័ត៌មានភាគច្រើននៅបច្ចុប្បន្ននេះត្រូវបានចែកផ្សាយតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ដែលមានដូចជា ទូរទស្សន៍ គេហទំព័រ បណ្ដាញសារព័ត៌មានអេឡិចត្រូនិច ឬហៅសារព័ត៌មានអនឡាញទៀតផង។ ការចុះផ្សាយ ចែកចាយ ឬបញ្ចេញមតិតាមរយៈសារព័ត៌មានអាចក្លាយជាបទល្មើស ប្រសិនបើខ្លឹមសារនៃព័ត៌មាននោះជារឿងមិនពិត ហើយមានចរិតលក្ខណៈញុះញង់បង្កឱ្យមានការរើសអើង ឬប៉ះពាល់ដល់សណ្ដាប់ធ្នាប់សុវត្ថិភាពសន្តិសុខសង្គម។ បទល្មើសដែលមានចែងក្នុងផ្នែកនេះ (សំដៅដល់បទល្មើសញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបទល្មើសញុះញង់ឱ្យមានការរើសអើង) ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីរបបសារព័ត៌មាន[48]។ សារព័ត៌មានដែលបានប្រព្រឹត្តអំពើល្មើសនានា រួមទាំងការផ្សាយដែលមានចរិតញុះញង់នាំឱ្យមានបទល្មើសកើតឡើង តុលាការមានសមត្ថកិច្ចអាចបង្គាប់ឱ្យសារព័ត៌មាននោះចុះផ្សាយកែតម្រូវ ឬសងជំងឺចិត្ត ឬទាំងពីរតែម្ដង ។ យ៉ាងណាក្ដី ក៏ការទទួលខុសត្រូវនៃសារព័ត៌មាន ពុំអាចនាំឱ្យបុគ្គលដែលប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ រួចផុតអំពីការទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌបានដែរ។

### ២.២.២ ការទទួលខុសត្រូវតាមច្បាប់ស្ដីពីរបបសារព័ត៌មាន

តាមច្បាប់ស្ដីពីរបបសារព័ត៌មាន សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឱ្យប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា[49]។ ចំពោះសារព័ត៌មានដែលប្រព្រឹត្តល្មើស ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១លានរៀល ទៅ ៥លានរៀល។ បន្ថែមពីលើនេះ ជនរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទៅតុលាការ សម្រាប់ការទាមទារសំណងចំពោះព្យសនកម្មដែលកើតមានឡើង។ យ៉ាងណាក៏ដោយ តុលាការក៏នឹងពិនិត្យមើលលើគ្រប់ទំនាក់ទំនងដោយផ្ទាល់រវាងអំពើញុះញង់នៅលើសារព័ត៌មានទៅនឹងអំពើហិង្សាដែលកើតឡើងនោះ។ ច្បាប់នេះក៏បានការពារទៅលើសារព័ត៌មានផងដែរ ដោយបានបញ្ជាក់ថា រាល់អត្ថបទដែលមានចំណាស់ ឬមានន័យថាបានចុះផ្សាយលើពី ៣ខែ មិនអាចត្រូវបានយកមកជាសំអាងក្នុងការចោទប្រកាន់បានឡើយ។

ច្បាប់ស្ដីពីរបបសារព័ត៌មានក៏បានចែងផងដែរថា សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្ដាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយឡើយ[50]។ ចំណុចនេះមានភាពស្រដៀងគ្នាទៅនឹង មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌផងដែរ ដែលមានគោលដៅទប់ស្កាត់នូវភាពចលាចល ដែល

---

[48] មាត្រា ៤៩៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[49] កថាខណ្ឌទី១ មាត្រា ១១ នៃច្បាប់ស្ដីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

[50] កថាខណ្ឌទី១ មាត្រា ១២ នៃច្បាប់ស្ដីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

នាំឱ្យមានភាពរីករវធ្ងន់ធ្ងរដល់សង្គម ប៉ុន្តែក្នុងច្បាប់ស្តីពីរបបសារព័ត៌មានបានបន្ថែមនូវពាក្យស្ថេរភាពនយោបាយ។ ជាក់ស្តែង កន្លងមកមានការដកស្រង់នូវឃ្លាណាមួយ ឬពាក្យសំដីមួយផ្នែកដែលនាំឱ្យមាននូវការរិះគន់វាយប្រហារហួរហែរមកលើរដ្ឋាភិបាល ដែលនាំឱ្យប៉ះពាល់ដល់ស្ថេរភាពនៃនយោបាយ ជាពិសេសអំឡុងពេលនៃប្រទេសជាតិកំពុងមាននូវទុកអាសន្នណាមួយ ដូចជាកំឡុងពេលប្រទេសជាតិកំពុងជួបផលលំបាកដោយសារកូវីដ-១៩ជាដើម ដែលបណ្តាលឱ្យប្រជាពលរដ្ឋដែលមិនមានការពិចារណាច្បាស់លាស់ មានការគុំកួន ស្អប់ខ្ពើមមកកាន់រដ្ឋាភិបាល ព្រមទាំងមិនចូលរួមសហការនូវវិធានការនានាដែលរដ្ឋបានដាក់ចេញ នាំឱ្យស្ថាប័នរដ្ឋកាន់តែទទួលបន្ទុកបន្ថែមទៀត។ ក្រោយមក ការចុះផ្សាយនូវព័ត៌មានខាងលើនេះ ត្រូវបានក្រសួងព័ត៌មានដែលជាក្រសួងមានសមត្ថកិច្ច រួមទាំងតុលាការ បានរួមគ្នាអនុវត្តនូវវិធានការតាមច្បាប់ដែលមានជាធរមានចំពោះទង្វើខាងលើនេះ។ ការលើកឡើងចំណុចនេះ ទំនងជាមានមតិខ្លះប្រាកដជាលេចឡើងនូវចម្ងល់ថា ចុះសេរីភាពសារព័ត៌មានដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនោះ អាចនឹងមានផលប៉ះពាល់ដែរ ឬយ៉ាងណា ប្រសិនបើការចុះផ្សាយព័ត៌មានត្រូវប្រឈមនឹងទោសទណ្ឌផ្នែកច្បាប់បែបនេះ? ធាតុពិតទៅ! ច្បាប់ស្តីពីរបបសារព័ត៌មាន ធានានូវការចុះផ្សាយបានដោយសេរីនូវរាល់ព័ត៌មានផ្លូវការទាំងឡាយដែលច្បាប់ស្តីពីរបបសារព័ត៌មានបានប្បញ្ញត្តិ ប៉ុន្តែប្រសិនបើការចុះផ្សាយនូវព័ត៌មានទាំងនោះនាំឱ្យកើតមាននូវបទល្មើសដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់ដោយឡែកនេះ ពោលគឺនិយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទនៃសារព័ត៌មាននោះត្រូវទទួលខុសត្រូវចំពោះការផ្តន្ទាទោសពិន័យជាប្រាក់ ៥លានរៀល ទៅ១៥លានរៀល ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។

**២.២.៣. ការទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌ**

អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ[51]។ នេះគឺជាខ្លឹមសារដែលបានប្បញ្ញត្តិក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ដែលពិតប្រាកដណាស់ថានេះជាការក្រើនរំឭកទៅដល់ស្ថាប័នសារព័ត៌មានទាំងអស់ បូករួមទាំងបុគ្គលដែលជាអ្នកប្រកបអាជីពជាអ្នកសារព័ត៌មានផង ឱ្យមានការគិតគូរ និងពិចារណាឱ្យបានខ្ពស់នូវរាល់ខ្លឹមសារនៃអត្ថបទព័ត៌មានទាំងឡាយរបស់ខ្លួន មុននឹងចេញផ្សាយអត្ថបទព័ត៌មាននោះជាសាធារណៈ ទៅដល់សាធារណជនទូទៅ។ អ្នកសារព័ត៌មានដែលបង្កឱ្យមានជាបទល្មើសនានាដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ នៅតែជៀសមិនផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ត្បិតអ្នកសារព័ត៌មានក៏ជារូបវន្តបុគ្គលដែលស្ថិតនៅក្រោម

[51] មាត្រា ២០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

ច្បាប់ដូចគ្នា។ ឧទាហរណ៍៖ បុគ្គលម្នាក់ជាអ្នកសារព័ត៌មាន បានបង្ហោះសារ និងចែកចាយព័ត៌មានណាមួយជាសាធារណៈដែលនាំឱ្យមានភាពវឹកវរដល់សង្គម តាមមធ្យោបាយណាមួយដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ មាត្រា ៤៩៤ នឹងត្រូវទទួលរងការចោទប្រកាន់បានដូចគ្នាតាមមាត្រា ៤៩៥ បន្ថែមពីលើការទទួលខុសត្រូវចំពោះច្បាប់ស្តីពីរបបសារព័ត៌មាន ដូចដែលបានបកស្រាយនូវចំណុចខាងលើ។

## ផ្នែកទី៣៖ បទល្មើសញុះញង់ក្នុងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា

ការចាប់បដិសន្ធិឡើងនូវប្រព័ន្ធអ៊ីនធ័រណេត និងការរីកចម្រើនឡើងនូវប្រព័ន្ធបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ បានជម្រុញឱ្យមនុស្សជាតិទាំងមូល ទទួលបាននូវការអភិវឌ្ឍន៍លើគ្រប់វិស័យ ទទួលរងនូវការផ្លាស់ប្តូររបស់ជីវិតផ្ទុយស្រឡះ បើប្រៀបនឹងជីវិតមុនមាននូវប្រព័ន្ធអ៊ីនធ័រណេត។ ពីដើមឡើយ ប្រសិនបើជនណាម្នាក់ ឬស្ថាប័នណាមួយចង់ចែករំលែកមតិ មាតិកា ឬពាក្យសំដី និងដំណឹងផ្សេងៗទៀត គេត្រូវនឹកភ្នកដល់ប្រព័ន្ធផ្សព្វផ្សាយមានដូចជា កាសែត វិទ្យុ ទូរទស្សន៍ជាដើម ប៉ុន្តែនាពេលបច្ចុប្បន្ន បរិបទនេះត្រូវបានផ្លាស់ប្តូរស្ទើរតែទាំងស្រុង។ មនុស្សជាតិចាប់ផ្តើមទាញយកប្រយោជន៍ពីបណ្តាញអ៊ីនធ័រណេតបានយ៉ាងច្រើន និងជានវានុវត្តន៍ថ្មីមួយទៀតដែលបង្កនូវលក្ខណៈងាយស្រួលក្នុងការចែកចាយដំណឹង មតិយោបល់ ស្ថានភាពវិវត្តថ្មីនៃនយោបាយ សង្គម សេដ្ឋកិច្ច ក្នុងប្រទេស ក៏ដូចជានៅទូទាំងពិភពលោក ហើយសាធារណជនដែលចង់តាមដាន និងទទួលបានដំណឹងនេះក៏កាន់តែមានភាពងាយស្រួលដូចគ្នា ដោយដំណឹងទាំងអស់ត្រូវបានផ្តល់ជូនយ៉ាងរហ័សដល់ដៃភ្លាមៗតែម្តង ដោយមិនចាំបាច់រង់ចាំដូចសម័យកាលមុនទៀតឡើយ។ ប៉ុន្តែទន្ទឹមនឹងភាពងាយស្រួលនេះ ខ្លឹមសារដំណឹង និងព័ត៌មានមួយចំនួនដែលអាចបង្កគ្រោះថ្នាក់ដល់សង្គម ក៏អាចត្រូវបានផ្សព្វផ្សាយ និងចែករំលែកបានងាយស្រួល ដែលអាចងាយបង្កគ្រោះថ្នាក់ដល់សង្គមបានផងដែរ។

### ៣.១ គោលបំណងនៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា

ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា បានធ្វើសេចក្តីព្រាងតាំងពីខែមិថុនា ឆ្នាំ២០១៤ ដែលមានគោលបំណងកំណត់វិធានការអប់រំ បង្ការទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តអំពើល្មើសនានា តាមប្រព័ន្ធបច្ចេកវិទ្យា[52]។ ការតាក់តែងសេចក្តីព្រាងច្បាប់នេះឡើង ក៏មានគោលដៅក្នុងការធានាឱ្យបាននូវការអនុវត្តច្បាប់ ប្រយុទ្ធប្រឆាំង និងបង្ក្រាបរាល់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា និងធានាសុវត្ថិភាព ការពារផលប្រយោជន៍ស្របច្បាប់ក្នុងការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យា ឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់សង្គមជាតិ ដែលទាមទារចាំបាច់ឱ្យមាននូវការគ្រប់គ្រងឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត នូវសកម្មភាពទាំងឡាយនៅក្នុងប្រព័ន្ធបច្ចេកវិទ្យា។

### ៣.២ បទល្មើស និងការផ្តន្ទាទោស

[52] មាត្រា ១ នៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា

នៅក្នុងសេចក្តីព្រាងច្បាប់នេះ ការចែងអំពីបទល្មើស ការផ្តន្ទាទោស ទោសបន្ថែមសម្រាប់អនុវត្តចំពោះបទល្មើសបច្ចេកវិទ្យា រួមទាំងទោសបន្ថែមសម្រាប់ការអនុវត្តទៅលើនីតិបុគ្គលសរុបចំនួន១៥មាត្រា ចាប់ពីមាត្រា ២១ រហូតដល់មាត្រា ៣៥។ ចំពោះបទល្មើសនៃការញុះញង់ក៏គេឃើញមានបញ្ចូលទៅក្នុងផ្នែកនេះដូចគ្នា ដែលគេសំដៅទៅដល់បទល្មើសតាមរយៈខ្លឹមសារ និងគេហទំព័រ។ ក្នុងសេចក្តីព្រាងច្បាប់នេះ គេក៏បានបង្ហាញពីនិយមន័យនៃខ្លឹមសារផងដែរ ដែលសំដៅដល់ខ្លឹមសារអេឡិចត្រូនិច ដោយរួមមានអត្ថបទ រូបភាព គំនូរជីវចល និមិត្តសញ្ញា សំឡេង ឬវីដេអូ ហើយចំពោះគេហទំព័រវិញ គេសំដៅដល់ទីកន្លែងនៅលើអ៊ីនធឺណេត ដែលអាចស្វែងរកព័ត៌មានអំពីអ្វីមួយ[53]។

បទល្មើសដែលពាក់ព័ន្ធនឹងការញុះញង់នៅក្នុងច្បាប់នេះរួមមាន ការធ្វើការផ្សព្វផ្សាយខ្លឹមសារអ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា និងបទល្មើសមួយផ្សេងទៀតដែលហាមឃាត់ការផ្សព្វផ្សាយខ្លឹមសារដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ ដែលក្នុងនោះក៏មានចែងអំពីការហាមឃាត់មិនឱ្យផ្សព្វផ្សាយខ្លឹមសារព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា មតិឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន និងស្ថានភាពដទៃទៀត។ បទល្មើសដែលបានលើកឡើងខាងលើនេះ ក្នុងសេចក្តីព្រាងច្បាប់ស្តីពីបច្ចេកវិទ្យា បានកំណត់ការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ឆ្នាំ ទៅ ៣ឆ្នាំ និងមានការពិន័យជាប្រាក់ ចាប់ពី ២លានរៀលទៅ ៦លានរៀល។ បន្ថែមពីលើនេះ សេចក្តីព្រាងច្បាប់ខាងលើ ក៏បានចែងអំពីទោសបន្ថែមសម្រាប់ការអនុវត្តទាំងចំពោះជនល្មើសជារូបវន្តបុគ្គល ក៏ដូចជាទោសបន្ថែមដែលអាចអនុវត្តចំពោះនីតិបុគ្គលបានផងដែរ។

បទល្មើសពាក់ព័ន្ធនឹងការញុះញង់តាមប្រព័ន្ធបច្ចេកវិទ្យានេះ វានឹងក្លាយជារូបភាពថ្មីមួយទៀតក្នុងការទប់ស្កាត់បទល្មើសតាមរយៈប្រព័ន្ធអ៊ីនធឺណេត ដែលច្បាប់នេះនឹងក្លាយជាតម្រូវការមួយដែលមិនអាចខ្វះបានក្នុងជីវភាពរស់នៅរបស់មនុស្សនាពេលខាងមុខ ដោយផ្អែកលើទិដ្ឋភាពជាក់ស្តែងនូវតម្រូវការកើនខ្ពស់មិនឈប់ឈរ នៅចំនួនអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងក្នុងថ្ងៃអនាគត។ យ៉ាងណាក៏ដោយគេជឿជាក់ថា សេចក្តីព្រាងច្បាប់នេះនៅត្រូវការពេលវេលាបន្ថែមសម្រាប់ការប្រមូលធាតុចូល និងការពិគ្រោះជាចាំបាច់ដើម្បីកុំឱ្យមានផលអវិជ្ជមានណាមួយកើតឡើង នាពេលដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ និងចូលជាធរមាននាពេលខាងមុខនេះ។

[53] មាវាក្យខណ្ឌទី៥ និងវាក្យខណ្ឌទី១០ មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រព័ន្ធបច្ចេកវិទ្យា

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវ និងស្វែងយល់យ៉ាងលម្អិត និងស៊ីជម្រៅបន្ថែមទៀតដែលពាក់ព័ន្ធទៅនឹងប្រធានបទកិច្ចការស្រាវជ្រាវដែលស្តីអំពី "**ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស**" រួចមក ពិតជាបានបកស្រាយ និងពន្យល់យ៉ាងក្បោះក្បាយអំពីសញ្ញាណនៃបទល្មើសនេះ ទាំងនៅក្នុងក្រមព្រហ្មទណ្ឌអន្តរកាល ទាំងច្បាប់ដែលកំពុងអនុវត្តបច្ចុប្បន្នដែលរួមមានក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីរបបសារព័ត៌មាន និងបានផ្សារភ្ជាប់ទៅដល់សេចក្តីព្រាងច្បាប់ដោយឡែកមួយផ្សេងទៀត គឺច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យាបន្ថែមទៀត។ ប្រាកដណាស់ថា នៅក្នុងសង្គមមួយដែលកំពុងមាននូវសុខសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ពិតជាមានតម្រូវការនៃការចូលរួមទាំងអស់គ្នាពីប្រជាពលរដ្ឋដើម្បីជាកត្តាជម្រុញឱ្យសង្គមមួយ ក៏ដូចជាប្រទេសជាតិទាំងមូល ឈានឆ្ពោះទៅមុខស្របតាមគោលដៅដែលជាការចង់បានរបស់ប្រជាពលរដ្ឋទាំងអស់ ក៏ដូចជាគោលដៅរួមមួយដែលជាទស្សនវិស័យរបស់រាជរដ្ឋាភិបាលផងដែរ។

ឆ្លងកាត់ការបកស្រាយនៅក្នុងប្រធានបទខាងលើនេះ អំពើញុះញង់ទាំងឡាយក្នុងគោលបំណងទុច្ចរិតមិនថាតាមទម្រង់ណាមួយ ឬក្នុងគោលដៅអ្វីនោះឡើយមិនមែនជារឿងដែលពុំគួរគប្បីក្នុងការប្រព្រឹត្តនោះទេ។ ជានិច្ចកាល ទាំងការញុះញង់ឱ្យមានការរើសអើង ទាំងការញុះញង់ឱ្យប្រព្រឹត្តឧក្រិដ្ឋ ក៏ដូចជាការរើសអើងផ្សេងៗទៀត សុទ្ធតែអាចនាំឱ្យមាននូវព្យសនកម្មកើតឡើង ទាំងស្រាល និងធ្ងន់ធ្ងរសម្រាប់បុគ្គល ក្រុមណាមួយ ឬអាចប៉ះពាល់ទៅដល់សង្គមជាតិទាំងមូលក៏សឹងមាន។ ក្នុងប្រទេសកម្ពុជា ស្រមោលពីអតីតកាលតាមការតំណាលប្រាប់ដោយចាស់ព្រឹទ្ធាចារ្យ និងថ្នាក់ដឹកនាំវ័យចំណាស់កន្លងមក ដែលធ្លាប់បានឆ្លងកាត់របត់សង្គមច្រើនជំនាន់កន្លងមកនោះ ក៏ធ្លាប់បញ្ជាក់ឱ្យយើងបានដឹងដែរថា ការញុះញង់ក្នុងគោលបំណងទុច្ចរិតទាំងអស់ មិនបានផ្តល់ឱ្យយើងគ្រប់គ្នានូវលទ្ធផលល្អប្រសើរនោះឡើយ ផ្ទុយទៅវិញការញុះញង់ទាំងឡាយដែលធ្លាប់មាន បានត្រឹមបន្សល់ទុកនូវស្លាកស្នាម ដំបៅ ការបែកបាក់ សង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃ និងស្លាប់បាត់បង់ជីវិតប្រជាជនខ្មែរស្លូតត្រង់រាប់សិបនាក់ ដែលនាំឱ្យប្រទេសជាតិដើរថយក្រោយសឹងតែហៅមិនឮ។

ជាងនេះទៅទៀត ប្រទេសកម្ពុជាដែលទើបទទួលបានសុខសន្តិភាពពេញលេញក្រោមការបង្រួបបង្រួមជាតិពីថ្នាក់ដឹកនាំកំពូលៗ ក៏កំពុងបានបង្ការនិងទប់ស្កាត់នូវរាល់ទម្រង់នៃការញុះញង់ឱ្យមានការរើសអើង និងការញុះញង់ឱ្យប្រព្រឹត្តបទល្មើសនានាទាំងឡាយ នេះគេនៅមិនទាន់រាប់បញ្ចូលការបង្ការទប់ស្កាត់នូវការចែកចាយព័ត៌មានមិនពិត ដែលនាំឱ្យមានការចលាចល និងប៉ះពាល់ដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមផង។ ត្រឡប់មកកាន់ប្រធានបទរបស់យើងដែលបានសិក្សា និងចងក្រងខាងលើវិញ ការញុះញង់ដែលអាចនាំឱ្យមាននូវការប្រព្រឹត្តបទល្មើស ឬប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ឬប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀប

រៀបរយសង្គមជាតិ ត្រូវបានច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបទដ្ឋានគតិយុត្តិអន្តរជាតិនានាបានហាមឃាត់។ យ៉ាងណាក្តី បើទោះបីជាមានការហាមឃាត់ពីច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិនានាយ៉ាងណាក៏ដោយ ក៏គេនៅតែសង្កេតឃើញបទល្មើសញុះញង់នៅតែកើតមានឡើងជាហូរហែរនៅក្នុងសង្គមនៃប្រទេសកម្ពុជាយើងដដែល។ គុណវិបត្តិមួយផ្សេងទៀត ក្រៅតែពីព្យសនកម្មដែលអាចកើតមានឡើងពីអំពើទាំងនោះ គេនៅសង្កេតឃើញមានការរិះគន់ វាយប្រហារដោយខ្វះការពិចារណាពីប្រជាពលរដ្ឋមួយចំនួនតូច ដែលពួកគាត់ទាំងនោះភាគច្រើនយល់ឃើញថា ការប្រព្រឹត្តអំពើញុះញង់ទាំងអស់នោះ គឺជាសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដែលជាសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពួកគាត់ទៅវិញ។

ជាចុងក្រោយ បន្ទាប់ពីបានសិក្សាស្វែងយល់ និងបកស្រាយនូវចំណុចនៃប្រធានបទសារណាខាងលើនេះ ខ្ញុំបាទក៏មានជាមតិយោបល់ខ្លះដែលជាទុននៃការចូលរួមក្នុងបទល្មើសនេះ ចំពោះចំណុចមួយចំនួន ក៏ដូចជាសំណូមពរបន្ថែមចំពោះប្រធានបទនេះ ដែលនឹងលើកឡើងដោយធ្វើជាអនុសាសន៍នៅក្នុងទំព័របន្ទាប់។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការបកស្រាយអំពីប្រធានបទ "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" ខ្ញុំបាទបានសង្កេតឃើញមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានដែលនេះជាចំណុចសំខាន់ ដោយសារតែអំពើនេះបានប៉ះពាល់ជាខ្លាំងទៅដល់ជីវភាពរបស់បុគ្គល និងក្រុមមនុស្ស ក៏ដូចជាជះឥទ្ធិពលដោយផ្ទាល់ និងដោយលក្ខណៈប្រយោលចំពោះសណ្តាប់ធ្នាប់សង្គម ក៏ដូចជាស្ថេរភាពនៃប្រទេសជាតិទាំងមូល។ កង្វះខាត គឺជាគុណវិបត្តិដែលទាមទារឱ្យមាននូវការដោះស្រាយ ដោយការបញ្ជ្រាប ពន្យល់ណែនាំឱ្យបានក្បោះក្បាយ និងទូលំទូលាយ អំពីឧទាហរណ៍ និងករណីជាក់ស្តែងណាមួយ ពាក់ព័ន្ធទៅនឹងការញុះញង់នេះ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបបានយល់ដឹង។ ដោយឡែកសម្រាប់ប្រជាពលរដ្ឋទៀតសោត ក៏គប្បីចំណាយពេលវេលាមួយផ្នែកក្នុងជីវភាពរស់នៅប្រចាំថ្ងៃដើម្បីមកស្វែងយល់ពីបញ្ហាប្រឈម និងការវិវត្តន៍របស់ច្បាប់ ដើម្បីជាពុទ្ធិក្នុងការត្រិះរិះពិចារណា និងជៀងវាសនូវការប្រព្រឹត្តអំពើទាំងឡាយណា ដែលអាចបង្កនាំឱ្យមានបទល្មើសកើតឡើង។

ក្រសួង ស្ថាប័នពាក់ព័ន្ធគប្បីបង្កើតជាយន្តការ ឬវិធីសាស្ត្រនានា ដែលអាចមានជាកិច្ចផ្សព្វផ្សាយ សិក្ខាសាលា និងការបកស្រាយឱ្យបានច្បាស់លាស់ អំពីចំណុចដែលនាំឱ្យមានការភ័ន្តច្រឡំរបស់ប្រជាពលរដ្ឋទូទៅអំពីបទល្មើសទាំងនេះ។

ចំណុចប្រឈមមួយទៀត ប្រជាពលរដ្ឋគប្បីស្វែងយល់អំពីប្រភពព័ត៌មានទាំងអស់ដែលខ្លួនទទួលបានតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា មិនថារដ្ឋ ឬឯកជន រាប់ទាំងប្រភពអនឡាញផងនោះ គឺជាប្រភពព័ត៌មានដែលអាចទុកចិត្តបាន ជៀសវាងនូវការទទួលបាននូវព័ត៌មានក្លែងក្លាយ នាំឱ្យមាននូវការភ័ន្តច្រឡំដោយអចេតនាណាមួយ ដែលការភ័ន្តច្រឡំនេះអាចនាំឱ្យប្រជាពលរដ្ឋចែកចាយបន្តទៀតដោយមិនបានពិចារណាគ្រប់ជ្រុងជ្រោយ និងអាចបណ្តាលឱ្យក្លាយជាបទល្មើសញុះញង់បានផងដែរ។

ចំណុចចុងក្រោយដែលខ្ញុំចាប់អារម្មណ៍ជាមតិយោបល់ផ្ទាល់ខ្លួន ពោលគឺនៅក្នុងមាត្រា ៤៩៦ បទញុះញង់ឱ្យមានការរើសអើង ដោយការញុះញង់ឱ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬហិង្សាទៅលើបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ ដោយច្បាប់ក្រមព្រហ្មទណ្ឌពុំបានរាប់បញ្ចូលការញុះញង់ដោយផ្ទាល់ឱ្យមានការរើសអើង គុំកួន ឬហិង្សាទៅលើបុគ្គលណាម្នាក់ ដោយហេតុផលបុគ្គលនោះជាក្រុមមនុស្សស្រឡាញ់ភេទដូចគ្នាមកដាក់បញ្ចូលនោះឡើយ។ ត្រង់ចំណុចនេះខ្ញុំបាទទទួលស្គាល់ដោយសារតែកម្ពុជា ពុំទាន់បានអនុម័ត ឬតាក់តែងច្បាប់ណាមួយស្តីពីការទទួលស្គាល់នូវសិទ្ធិ និងកិច្ចគតិយុត្តិដូចជាការចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើម ចំពោះក្រុមស្រឡាញ់ភេទដូចគ្នា។

នាថ្ងៃអនាគត ខ្ញុំសង្ឃឹមថាចំណុចនេះនឹងមានការដាក់បញ្ចូល ដោយវិសោធនកម្មក្រមព្រហ្មទណ្ឌនាពេលខាងមុខ ជាពិសេសក្នុងលក្ខខណ្ឌ និងពេលវេលាសមស្របណាមួយ ដែលច្បាប់ពាក់ព័ន្ធនឹងក្រុមមនុស្សស្រឡាញ់ភេទដូចគ្នាត្រូវបានតាក់តែង និងចូលជាធរមាននៅកម្ពុជា។ ប្រាកដណាស់ កម្ពុជាជាប្រទេសដែលកំពុងមានការអភិវឌ្ឍន៍ ដែលត្រូវការជាចាំបាច់នូវកំណែទម្រង់ច្បាប់ នៅក្នុងវិស័យផ្សេងៗទៀត ដើម្បីឱ្យកម្ពុជាមានអាចដើរឱ្យទាន់នូវភាពរីកចំរើនរបស់បណ្ដាប្រទេសធំៗនានាក្នុងពិភពលោក ជាពិសេសនៅក្នុងសម័យកាលបច្ចេកវិទ្យាដ៏ទំនើប និងសម័យកាលជើងមេឃបើកទូលាយនេះ។

# ឯកសារយោង

# **ឯកសារយោង**

## **លិខិតបទដ្ឋានគតិយុត្តិជាតិ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៥៦
- ក្រមព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២
- ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥
- ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ ប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ឆ្នាំ២០២១
- សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឆ្នាំ២០១៤

## **សៀវភៅមេរៀន**

- សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយ **លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ** និង**លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត** ឆ្នាំ២០០៧
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ **លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** ឆ្នាំ២០១០
- សៀវភៅនីតិព្រហ្មទណ្ឌពិសេស រៀបរៀងដោយ **លោកសាស្ត្រាចារ្យ កៅ សីហា** ឆ្នាំ២០១៤

## **វចនានុក្រម និងសទ្ទានុក្រម**

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ដោយក្រុមការងារពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៨
- សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០៧
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ២០០៩

ការបកស្រាយច្បាប់ព្រហ្មទណ្ឌរបស់ឯកឧត្តម ហ៊ី សោភា នៅក្នុងការអនុម័តក្រមព្រហ្មទណ្ឌកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ តំណភ្ជាប់:

https://www.youtube.com/watch?v=AdG-oxdvqN4&t=932s

កម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបកស្រាយដោយឯកឧត្តម កើត រិទ្ធ ឯកឧត្តម ប៊ុន ហុន និងឯកឧត្តម ផូវ សំភី តាមរយៈកិច្ចសហប្រតិបត្តិការរបស់ក្រសួងយុត្តិធម៌ សហការជាមួយក្រសួងព័ត៌មាន លើការផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា។

ការផ្សាយរបស់គេហទំព័រវិទ្យុបារាំងអន្តរជាតិ RFI។

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ខ្លឹមសារពាក់ព័ន្ធ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣<br>និង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ |
| **ឧបសម្ព័ន្ធទី២** | ខ្លឹមសារពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល (ឆ្នាំ១៩៥៦)<br>និងខ្លឹមសារពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល (ឆ្នាំ១៩៩២) |
| **ឧបសម្ព័ន្ធទី៣** | ខ្លឹមសារពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ |
| **ឧបសម្ព័ន្ធទី៤** | ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥<br>និងខ្លឹមសារពាក់ព័ន្ធ ក្នុងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឆ្នាំ២០១៤ |

# ឧបសម្ព័ន្ធទី១

# ខ្លឹមសារពាក់ព័ន្ធក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិ-នារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រ-កាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើក-លែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមា-ជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស

ច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណង ជូសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមនី និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

# ខ្លឹមសារពាក់ព័ន្ធក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

### មាត្រា ១៨

១. ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួន ដោយម្នាក់១ឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្ត និងការបង្ហាត់បង្រៀន។

២. គ្មានជនណាម្នាក់ ត្រូវរងការបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ដែលបំពារបំពានធ្វើឱ្យខូចខាត ដល់សេរីភាពនៃការកាន់ ឬកាគោរពសាសនា ឬជំនឿតាមការជ្រើសរើសរបស់ខ្លួនឡើយ។

៣. សេរីភាពសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន នឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដល់ការការពារសន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិនិងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនជាមាន ក្នុងការធានាដល់ការអប់រំខាងសាសនានិងសីលធម៌បុត្រធីតារបស់គេ ស្របតាមជំនឿរបស់គេ។

### មាត្រា ១៩

១. ជនគ្រប់រូបមាន សិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី :

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

## មាត្រា ២០

១. ការឃោសនាណាជាគុណប្រយោជន៍ដល់សង្គ្រាម ត្រូវហាមឃាត់ដោយច្បាប់ ។

២. ការអំពាវនាវណាឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់នាំឱ្យកើតមានការរើសអើង ការប្រទូស្តរ៉ាយ ឬហឹង្សា ត្រូវហាមឃាត់ដោយច្បាប់ ។

## មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធី ត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

## មាត្រា ២២

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិតខាងផ្លូវច្បាប់ លើសមាជិកយោធា និងនគរបាល ក្នុងការប្រើប្រាស់សិទ្ធិនេះទេ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះអនុញ្ញាតឱ្យរដ្ឋភាគីនៃអនុសញ្ញាឆ្នាំ ១៩៤៨ របស់អង្គការការងារអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិខាងសហជីព ចាត់វិធានការខាងផ្លូវច្បាប់ ឬអនុវត្តច្បាប់ តាមរបៀបដែលធ្វើឱ្យប៉ះពាល់ដល់ការធានា ដែលមានចែងក្នុងអនុសញ្ញានោះឡើយ ។

# ឧបសម្ព័ន្ធទី២

# ខ្លឹមសារពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល (ឆ្នាំ១៩៥៦)



មាត្រា ៤៩៩– ជនណា បង្កហេតុ ឬ បំណងនឹងបង្កហេតុ នៅមុខប្រជាជន ដោយពាក្យ ឬ ដោយលាយលក្ខណ៍អក្សរ, ដោយគំនូរ, រូប ឬ ទស្សនីយភាព, ទោះបី គ្រឿងប្រដាប់ សម្រាប់មើល ឬ សម្រាប់ស្តាប់ ដែលយកមកប្រើ ក្នុងការឃោសនា ដល់ប្រជាជននោះ មានគុណដូចដូចម្តេចក្តី, ទោះបី ភាសា ដែលប្រើនោះ, ជាភាសា ជាតិ ណាៗ ក្តី ដើម្បីឲ្យមាន ការប្រព្រឹត្ត ឧក្រិដ្ឋកម្ម ឬ ទោសកម្ម, ជននោះត្រូវទុក ជាអ្នកសមគំនិត ក្នុងឧក្រិដ្ឋកម្ម ឬ ទោសកម្មនោះ, ប្រសិនបើ បទល្មើសទាំងនោះ បានប្រព្រឹត្ត រួចហើយ ឬ មានបំណងនឹងប្រព្រឹត្ត មែន ។ បើ ការបង្កហេតុនេះ គ្មានបាន ផល សោះទេ, វិទូជន ត្រូវមាន ទោសមធ្យម ជាក់ទីពីរ ។ ក្នុងករណី ទាំងពីរនេះ, វិទូជន ទឹងត្រូវ អនុទោសក្រឹង ស្ថាន បន្ថយសិទ្ធិស៊ីវិល និង គំហាត់លំនៅ ទៀតក៏បាន ។

ការបង្កហេតុ គឺ ការញុះញង់ ដោយផ្ទាល់ ឬ ដោយមិនផ្ទាល់, ឲ្យប្រព្រឹត្ត ឧក្រិដ្ឋកម្មឬ ទោសកម្ម, បញ្ឆោរ ឬ ពាក់ជើង ជន ដែលបានប្រព្រឹត្ត ឬ បំណងនឹងប្រព្រឹត្ត នូវ អំពើល្មើសនោះ ជាដើម ។

( វគ្គ បន្ត ពីវគ្គ ខាងលើនេះ បានត្រូវនិរាករណ៍ហើយ ។ ត្រូវយក មាត្រា ១៩និង២០ នៃ ព្រះរាជក្រម លេខ ៦៥០-នស. ចុះថ្ងៃ ១០-៣-៥១ ដែលមាន សេចក្តីស្រង់ ដូចខាងក្រោមនេះ មកជំនួស វិញ ។ )

មាត្រា ១៩ – ជន អ្នកមានទោស តាម លំដាប់ ដូចខាងក្រោមនេះ,



ដែលបានប្រព្រឹត្ត បទឧក្រិដ្ឋ និង មជ្ឈិម តាមផ្លូវសារពត៌មាន, ត្រូវទុកដូច ជាតារី :

១– ចាងហ្វាងផ្សាយដំណឹង ឬ អ្នកបោះពុម្ពផ្សាយ (éditeur), បើ ទុកជាមាន ងារ ឬ មានឈ្មោះ ជាអ្វី ក៏ដោយ ។

២– បើ គ្មានជន ខាងលើនេះទេ, ត្រូវយក អ្នកនិពន្ធ ។

៣– បើ គ្មានអ្នកនិពន្ធ ត្រូវយក អ្នកបោះពុម្ព(imprimeur) ។

៤– បើ គ្មានអ្នកបោះពុម្ព, ត្រូវយក អ្នកលក់, អ្នកចែកផ្សាយនិង អ្នកបិទផ្សាយ ។

មាត្រា ២០ – កាលណា ចាងហ្វាងផ្សាយដំណឹង ឬ អ្នកបោះពុម្ពផ្សាយ ត្រូវទោស ជាតួការី, អ្នកនិពន្ធ នឹងត្រូវទោស ជាអ្នកសមគំនិត ។ ជន ដែលមានលក្ខណៈ ដូចមានក្នុង មាត្រា ពី៨២ ដល់ ៨៨ នៃក្រមព្រហ្មទណ្ឌនេះ អាចត្រូវមាន ទោស ដូចគ្នា ទាំងអស់ ។

បើ មាន វិទ្ធជនខ្លះ មាន លក្ខន្តិក របស់ខ្លួន ឬ មានហេតុអ្វីផ្សេងទៀត ដែលមិនអាច ឲ្យគេ ចោទប្រកាន់ បានទេនោះ , គេ អាចចោទតែ វិទ្ធជន ដទៃទៀត តែម្នាក់ ឬ ច្រើននាក់ ក៏បាន ។

វត្ថុទាំងឡាយ, ជាសម្ភារៈ សម្រាប់ប្រព្រឹត្ត បទល្មើសនោះ ឬ សម្រាប់ផ្សាយ ដល់សាធារណជននោះ, ត្រូវរឹបអូសទុក ។ វត្ថុទាំងឡាយ, ដូចជាពត៌មាន, វិញ្ញាសារ (Morasse) ម៉ាស៊ីនបោះពុម្ព. ប្រដាប់



បញ្ចាំងរូប ឬ ប្រដាប់ថតសំឡេងជាដើម, ក៏ត្រូវរឹបអូស ដូចគ្នា ។ ព្រះរាជក្រឹត្យ ដែលមានគណៈរដ្ឋមន្ត្រី បានយល់ព្រម ផង អាចឃាត់ហាមបាន នូវការបោះពុម្ព, ការបោះផ្សាយ ជាសៀវភៅ (édition), ផលិតកម្ម នៃលេខនា សម្រាប់មើល ឬ សម្រាប់ស្តាប់ (reproduction graphique visuelle ou phonique), ការធ្វើទស្សនីយភាព(mise en spectacle ),ការផ្សាយដល់សាធារណៈជន(publication),ការបិទផ្សាយ ( affichage), ពិព័រណ៍ ( exposision ), ការបញ្ជូនចុះឡើង (circulation) , ការដឹកជញ្ជូន(transport),ការចែកផ្សាយ(distribution),ការលក់(vente) ការផ្សព្វផ្សាយ (diffusion )ដោយរបៀបយ៉ាងណា ។ក្តី នូវលិខិត(écrits) សុន្ទរកថា(disconrs ), គំនូរ (dessins),រូប(image), រូបថត,(photographies), ទស្សនីយភាព (spectacles),វត្ថុផ្សេង ៗ, បដិមរូប (emblèmes) ដែលយល់ថា ខុស នឹងសេចក្តីរៀបរយ របស់មហាជន , របស់ទំនៀមទម្លាប់ ឬ ដែលយល់ថា ប៉ះពាល់ ដល់សេចក្តីគោរព ព្រះមហាក្សត្រ, ដល់ព្រះរាជវង្សានុវង្ស, ដល់សាសនា របស់រដ្ឋ , ដល់អាជ្ញាធរ ដែលតែងតាំង ដោយរដ្ឋធម្មនុញ្ញ ។

ព្រះរាជក្រឹត្យ ដែលហាមឃាត់នេះ ត្រូវដាក់ឲ្យប្រតិបត្តិ ភ្លាម ៗ ក្រោយដែលព្រះមហាក្សត្រ ទ្រង់មាន ព្រះរាជឱង្ការ ប្រកាស ឲ្យប្រើ ។

ប្រសិនបើ ការបង្កហេតុនោះ , ថ្វីបើ មាន ព្រះរាជក្រឹត្យហាមឃាត់

យ៉ាងនេះហើយ , ព្រមទាំងមាន សេចក្ដីប្រកាស ឲ្យប្រើព្រះរាជក្រឹត្យ នោះហើយ, ហើយនៅតែបំណង នឹងប្រព្រឹត្ត ឬ នៅតែប្រព្រឹត្ត ទៀត, អំពើនោះនឹងត្រូវមាន ទោស ដល់អតិបរមា , កាលណាបើ ទោសនោះ នៅត្រឹមតែទោសមជ្ឈិម ។

មាត្រា ៣០០– ( ព្រះរាជក្រមលេខ ៤១ ន.ស. ចុះថ្ងៃ ២២ - ៩ - ៥៥ )

១.– ជន ណា បានផ្សាយ ដោយប្រើ មធ្យោបាយ ណាមួយ បណ្ដា មធ្យោបាយ ទាំងឡាយ ដូចដែលមានសំដែង ក្នុងមាត្រា ២៩៩ ខាង លើនេះ ជាភាសា អ្វីក៏ដោយ នូវវិទ្ធង្សនា ដែលមាន គោលបំណង ជាប្រត្យក្ស ថា នឹង :

ក) បញ្ជាក់ឲ្យប្រាកដ, បង្រៀន ឬ ធ្វើឲ្យជឿច្បាស់ ថា ត្រូវតែ ផ្ដួលរំលំ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ, អង្គការ នៃអំណាចសាធារណៈ, ច្បាប់ ឬ បទបញ្ជា ខាងរដ្ឋបាល ដោយមធ្យោបាយទាំងឡាយ ផ្សេង ពីមធ្យោបាយ ដែលរដ្ឋធម្មនុញ្ញ ឬ ដែលច្បាប់ អនុញ្ញាត ឲ្យធ្វើ ព្រោះថាការផ្ដួលរំលំនេះ សមស្រប តាមច្បាប់ហើយ ជាចាំបាច់ហើយ ឬ សមគួរ ដល់ពេលវេលាហើយ, យ៉ាងនេះក្ដី ។

ខ) ពោលឃាត់, បង្រៀន ឬ ធ្វើឲ្យជឿ ថា ត្រូវតែកែប្រែ រដ្ឋធម្មនុញ្ញ ត្រង់ចំណុច ទាំងឡាយ ដែលរដ្ឋធម្មនុញ្ញ បានហាម មិនឲ្យកែ



ប្រែ ដោយមធ្យោបាយ, ដែលតាមទំនងក្រៅ, ហាក់ជា ត្រឹមត្រូវ តាមច្បាប់ ក៏ដោយ, ដោយហេតុថាការកែប្រែនេះ សមស្រប តាមច្បាប់ហើយ, ជាចាំបាច់ហើយ ឬ សមគួរដល់ពេលវេលាហើយ, យ៉ាងនេះ ក្ដី ។

គ) អុចអាល ឲ្យមើលងាយ ឬ ឲ្យស្អប់ រដ្ឋាភិបាលខ្មែរ ឬ ប្រទេស សម្ពន្ធមិត្ត ឬ ជាមិត្ត យ៉ាងនេះ ក្ដី ។ ក៏ប៉ុន្តែ ចំពោះបទល្មើស ក្នុងវគ្គនេះ បើរដ្ឋាភិបាល ជាសាមីខ្លួន មិនបានប្ដឹង មក ជាមុន ទេ នោះ, ការចោទប្រកាន់ ក៏មិនអាចធ្វើ បាន ដែរ ។

ឃ) អុចអាល ឲ្យស្អប់ ឬ ឲ្យមើលងាយ រវាងរាស្ត្រ នឹងអ្នករាជការ ក្ដី, រវាងវណ្ណៈ ក្ដី, រវាងពួក ឬ ជន នៃពលរដ្ឋ នឹងពួក ឬ ជន នៃ ពលរដ្ឋ ក្ដី, រវាងតំបន់ មួយ នឹងតំបន់ មួយ នៃប្រទេសកម្ពុជា ក្ដី, រវាងសាសនា នឹង សាសនា ដែលរដ្ឋាភិបាល ទទួលស្គាល់ ក្ដី ឬ ប្រឆាំងនឹងសាសនា ណាមួយ បណ្ដាសាសនា ទាំងឡាយ នោះ ក្ដី ។

ង)អំពុកាលមិនឲ្យស្តាប់បង្គាប់, ដោយឲ្យធ្វើតែព្រងើយៗ ក៏ដោយ, នូវច្បាប់ , បទបញ្ជា , បទបង្គាប់ តាមច្បាប់ របស់អាជ្ញាធរ ជាធម្មានុរូប ខាងវេជ្ជបាល ឬ ខាងតុលាការ , យ៉ាងនេះ ក្តី ; ប៉ុន្តែ បើការអំពុកាល ឲ្យធ្វើ ឧក្រិដ្ឋកម្ម នេះ បានផល របស់វា មែនទោះ, ត្រូវយក បទបញ្ញត្តិ ស្តី ពីឧក្រិដ្ឋកម្ម ដែលមាន ទោសធ្ងន់ជាង ទោស នៃបទល្មើស កន្លែងនេះ មកអនុវត្ត វិញ ។

-១៧៩-

ជននោះ ត្រូវផ្តន្ទាទោស ទុក្រិដ្ឋថ្នាក់ទីមួយ ; ប៉ុន្តែទោសនេះក៏មិនជាឧបសគ្គឲ្យខានអនុវត្ត ទោសធ្ងន់ជាងនេះទៅទៀតទេ, ប្រសិនបើមានការណ៍ ត្រូវអនុវត្ត ។

# ខ្លឹមសារពាក់ព័ន្ធ ក្នុងក្រមព្រហ្មទណ្ឌអន្តរកាល (ឆ្នាំ១៩៩២)

## មាត្រា ៥៩ : ការញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋដោយបានសំរេចផល

នឹងត្រូវផ្តន្ទាទោសពីបទសមគំនិត ក្នុងអំពើដែលចាត់ថាជាបទឧក្រិដ្ឋតាមបទបញ្ញត្តិនេះ ជនទាំងឡាយណាដែល តាមរយៈសន្ទរកថា, តាមសម្រែក ឬ ការគំរាមកំហែង បន្លឺឡើងក្នុងកន្លែងនានាឬ ក្នុងទីប្រជុំជនសាធារណៈ, តាមការសរសេរ, ការបោះពុម្ព, គំនូរ, ចម្លាក់, វិចិត្រកម្ម, និម្មិតរូប, រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ, សំដី ឬរូបភាព ដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ, តាមផ្ទាំងបដា ឬប័ណ្ណប្រកាសដែលតាំងអោយសាធារណៈជនឃើញ, តាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សនៈ បានបង្កដោយផ្ទាល់អោយមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសំរេចផល ។

លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ ។

## មាត្រា ៦០ : ការញុះញង់អោយប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិមដោយពុំបានសំរេចផល

ជនណា តាមមធ្យោបាយណាមួយដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ដែលបានញុះញង់ដោយផ្ទាល់អោយមានបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ដែលមានចែងក្នុងបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ក្នុងករណីណាដែលការញុះញង់នោះពុំបានសំរេចផល ។

## មាត្រា ៦១ : ការញុះញង់អោយមានការរើសអើង

១ : ជនណា តាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ ដែលបានញុះញង់អោយមានសម្អប់ជាតិ, ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់អោយមានការរើសអើង, អរិភាព ឬហឹង្សា នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ខែ ទៅ ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១,០០០,០០០ ទៅ ១០,០០០,០០០រៀល ឬផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

២ : ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាអោយបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយ ឬច្រើន ដោយអោយជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កំរិតច្រើនបំផុត ១០,០០០,០០០ រៀល ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមដែលតាំងឡើងតាមវិធាន ដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណី ជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៣ : ក្នុងករណីណាក៏ដោយ និយោជក, អ្នកបោះពុម្ព, ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់អោយជនរងគ្រោះម្នាក់ ឬច្រើននាក់ ។

# ឧបសម្ព័ន្ធទី៣

**មាត្រា ២៨.- និយមន័យនៃអ្នកផ្ដើមគំនិត**

ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា ។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

## ផ្នែកទី ៣

## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

**មាត្រា ៤៩៤.- លក្ខខណ្ឌអត្ថិភាពនៃការញុះញង់**

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្ដន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត :

១-ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬ នៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬ គំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយ នៅក្នុងចំណោមសាធារណជន ឬ តាំងឱ្យសាធារណជនមើល ។

៣-ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៤៩៥.- បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍**

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ ប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៤៩៤(លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០(បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៤៩៦.-** បទញុះញង់ឱ្យមានការរើសអើង

អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ឱ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬ ហិង្សា ចំពោះបុគ្គលណាម្នាក់ ឬ ក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬ មិនមែនជាសមាជិកនៃជាតិពន្ធ ក្រុមជាតិ ពូជសាសន៍ ឬ នៃសាសនាណាមួយជាក់លាក់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៤៩៧.-** អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

បទល្មើសដែលមានចែងក្នុងផ្នែកនេះ ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៤៩៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Ksl

# ឧបសម្ព័ន្ធទី៤

## ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥

# ច្បាប់
## ស្តីពី
# របបសារព័ត៌មាន

### ជំពូកទី ១
### សិទ្ធិនិងសេរីភាពខាងសារព័ត៌មាន

មាត្រា ១.-

ច្បាប់នេះកំណត់របបសារព័ត៌មាននិងធានារ៉ាប់រងសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឲ្យបានសមស្របតាមមាត្រា ៣១ និងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

សារព័ត៌មានមានសិទ្ធិរក្សាការសម្ងាត់ស្តីពីប្រភពព័ត៌មានរបស់ខ្លួន ។

មាត្រា ៣.

ដើម្បីរក្សាឯករាជ្យនៃសារព័ត៌មាន ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយត្រូវហាមឃាត់ ។

មាត្រា ៤.-

ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត ។

ព័ត៌មានផ្លូវការដែលជាកម្មវត្ថុនៃមាត្រានេះសំដៅចំពោះ ៖

១- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍របស់រដ្ឋសភារាប់ទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាផង លើកលែងតែក្នុងករណីរដ្ឋសភាធ្វើការប្រជុំសម្ងាត់ដូចមានចែងក្នុងមាត្រា ៨៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២- សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍នៃផ្នែកនីតិប្រតិបត្តិរួមទាំងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រី និងមន្ត្រីនានាផង ។

៣- គ្រប់ទិដ្ឋភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែក្នុងករណី ដូចខាងក្រោមនេះ ៖

- តុលាការហាមមិនឲ្យបើកចំហដល់សាធារណជន
- បញ្ញត្តិដោយមាត្រា ១៦ នៃច្បាប់នេះដែលទាក់ទងទៅនឹងរាជកំបាំងរបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជំរះក្តី
- សំណុំរឿងដែលនៅក្នុងការអង្កេតស៊ើបសួររបស់តុលាការនៅឡើយ ។

មាត្រា ៥.-

១- គោលការណ៍ទូទៅ

សារព័ត៌មាន មានសិទ្ធិទទួលព័ត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែព័ត៌មានណាដែលបណ្ដាលឲ្យ ៖

- អន្តរាយដល់សន្តិសុខជាតិ
- អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ
- មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ ដោយរាប់ទាំងសំណុំរឿងរបស់មន្ត្រីរាជការ សំណុំរឿងពេទ្យ សំណុំរឿង និងឯកសារផ្លូវការសម្ងាត់ៗដទៃទៀតជាដើម
- មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ ដែលបានមកពីបុគ្គល ឬអង្គភាពត្រឹមត្រូវតាមច្បាប់ណាមួយ និងការលាតត្រដាងនូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងបទបញ្ជា ឬការត្រួតពិនិត្យរបស់ស្ថាប័នហិរញ្ញវត្ថុ
- ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំឲ្យមានជំនុំជំរះក្ដីដោយអយុត្តិធម៌
- មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ ឬត្រូវបំពេញបេសកកម្មរបស់ខ្លួន ។

២- ការស្នើសុំព័ត៌មាន

ការស្នើសុំព័ត៌មានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីព័ត៌មានដែលស្នើសុំទៅស្ថាប័ននានា ។

មន្ត្រីមានសមត្ថកិច្ចដែលគ្រប់គ្រងស្ថាប័ននោះ ត្រូវឆ្លើយតបទៅនឹងពាក្យសុំក្នុងរយៈពេលសាមសិបថ្ងៃ (៣០ថ្ងៃ) យ៉ាងយូរ ។ ប្រសិនបើការស្នើសុំនោះ ត្រូវបានបដិសេធទាំងស្រុង ឬខ្លះៗនោះ ហេតុផលនៃការបដិសេធត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

## ជំពូកទី ២

## ការទទួលខុសត្រូវនៃអ្នកសារព័ត៌មាន

មាត្រា ៦.-

អ្នកសារព័ត៌មានមានសិទ្ធិបង្កើតសមាគមអ្នកសារព័ត៌មាន ។ សមាគមអ្នកសារព័ត៌មាននោះត្រូវមានលក្ខណៈឯករាជ្យ ។ សមាគមអ្នកសារព័ត៌មាននីមួយៗ ត្រូវអនុម័តលក្ខន្តិកៈរបស់ខ្លួនដែលមិនផ្ទុយនឹងច្បាប់ជាធរមានដោយមានការយល់ព្រមពីសមាជិកតាមការបោះឆ្នោត ។ អ្នកដឹកនាំសមាគមអ្នកសារព័ត៌មានដែលជាសមាជិកក្រុមអភិបាល ត្រូវមានការបោះឆ្នោតជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យ ។

មាត្រា ៧.-

សមាគមអ្នកសារព័ត៌មាននីមួយៗត្រូវតាក់តែងក្រមសីលធម៌ដើម្បីអនុវត្តក្នុងសមាគមរបស់ខ្លួនដែលអ្នកសារព័ត៌មានមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ជាអាទិ៍ដូចតទៅ ៖

១- គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន ។

២- ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឲ្យត្រឹមត្រូវ និងសមស្របតាមគតិយុត្តិធម៌ ។

៣- ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ ។ អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ ។

៤- ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ ។

៥- ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឲ្យមានការយល់ច្រឡំ ។

៦- ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឲ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬទិដ្ឋិការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត ។

៧- ត្រូវគោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល ។

៨- ត្រូវគោរពឲ្យបានហ្មត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរ ក្នុងការសរសេរអត្ថបទ ។

៩- ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា ។

១០- ហាមរំលោភលើសិទ្ធិ ដើម្បីមានការជំនុំជំរះក្តី ដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១១- ត្រូវចាត់ទុកចំណុចដូចខាងក្រោមនេះជាការរំលោភដ៏ធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ៖

- ការលួចចម្លងគំនិត ឬស្នាដៃរបស់អ្នកដទៃមកដាក់ថាជារបស់ខ្លួន
- បន្លំឲ្យគេយល់ខុស ដូចជាការសរសេរបញ្ឆិតបញ្ឆៀងដើម្បីឲ្យអ្នកអានមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុម បក្សណាមួយ
- ការបួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ
- ការទទួលសំណូកក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការបោះពុម្ពផ្សាយ ឬមិនបោះពុម្ពផ្សាយនូវព័ត៌មានណាមួយ ។

មាត្រា ៨.-

មុនពេលចាប់ផ្តើមចែកចាយសារព័ត៌មាន និយោជក ឬនិពន្ធនាយក ត្រូវធ្វើពាក្យមួយច្បាប់ (០១ច្បាប់) ជូនមកក្រសួងព័ត៌មានដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ។ ក្រសួងនេះត្រូវចេញបង្កាន់ដៃឲ្យទៅសារព័ត៌មានពេលបានទទួលសំណុំបែបបទទាំងមូល ។

ក្នុងករណីដែលនាយកការផ្សាយជាសមាជិករដ្ឋសភា ឬស្ថាប័នដែលមានអភ័យឯកសិទ្ធិ សារព័ត៌មាននោះត្រូវចាត់តាំងឲ្យមានសហនាយកការផ្សាយម្នាក់ទៀត ។

និយោជក ឬនិពន្ធនាយកដែលមិនគោរពបែបបទនេះជាមុន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ពីប្រាំសែនរៀល (៥០០.០០០រៀល) ទៅមួយលានប្រាំសែនរៀល(១ ៥០០ ០០០រៀល) ។ ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេឡើង ។

មាត្រា ៩.-

សំណុំបែបបទដែលនិយោជក ឬនិពន្ធនាយក ត្រូវបំពេញមានជាអាទិ៍ :

- អត្តសញ្ញាណប័ណ្ណនៃសារពត៌មាន
- ឈ្មោះ និងអាស័យដ្ឋានរបស់និយោជក ឬនិពន្ធនាយក
- ឈ្មោះ និងអាស័យដ្ឋានរបស់រោងពុម្ព
- លិខិតថ្កោលទោស

រាល់ការផ្លាស់ប្តូរពត៌មានខាងលើនេះ ត្រូវជូនដំណឹងទៅក្រសួងពត៌មានប្រាំថ្ងៃ (៥ ថ្ងៃ) មុន លើកលែងតែករណីប្រធានសក្តិ ។

មាត្រា ១០.-

ជនណាម្នាក់ដែលយល់ថាអត្ថបទណាមួយ ទោះជាសរសេរបញ្ឆិតបញ្ឆៀងក៏ដោយ រូបគំនូរ ឬរូបថតណាមួយនៃសារពត៌មានណាមួយដែលមានលក្ខណៈខុសពីការពិត ធ្វើឲ្យខូចខាតដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួន មានសិទ្ធិទាមទារឲ្យសារពត៌មាននោះធ្វើការកែតម្រូវឬមានសិទ្ធិឆ្លើយតប និងធ្វើបណ្តឹងពីបទបរិហារកេរ្តិ៍ ពីបទមួលបង្កាច់ ឬពីបទជេរប្រមាថ ចំពោះការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ។ ចម្លើយកែតម្រូវ ឬឆ្លើយតបត្រូវចុះផ្សាយក្នុងរយៈពេលប្រាំពីរថ្ងៃ (៧ថ្ងៃ) យ៉ាងយូរ ឬនៅលេខបន្ទាប់ក្រោយពីបានទទួលការទាមទារឲ្យកែតម្រូវ ឬឆ្លើយតប ។

ចំពោះករណីដែលពាក់ព័ន្ធដល់បុគ្គលសាធារណៈ គ្រប់ការពោលរះរាំងឬការទំលាក់កំហុសដែលអ្នកសារពត៌មានយកមកចុះផ្សាយដោយផ្ទាល់ឬក៏យកមកចុះផ្សាយបន្តខុសពីការពិត ក្នុងបំណងបំផ្លាញបុគ្គលសាធារណៈនោះ គឺជាការមួលបង្កាច់ដែលច្បាប់ហាមឃាត់ ។

បើតុលាការរកឃើញថា ការផ្សាយណាមានលក្ខណៈខុសពីការពិតតាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការអាចបង្គាប់ឲ្យសារពត៌មាននោះ ៖

- ចុះផ្សាយនូវការកែតម្រូវ ឬ
- សងជំងឺចិត្ត ឬ
- ចុះផ្សាយនូវការកែតម្រូវផង និងបង់ប្រាក់សងជំងឺចិត្តផង ។

អត្ថបទកែតម្រូវដែលអ្នកសារពត៌មាន មានកាតព្វកិច្ចផ្សាយ ត្រូវចុះផ្សាយនៅទំព័រដូចគ្នា និងមានទំហំអក្សរប៉ុនគ្នានិងអត្ថបទដែលបានចាត់ទុកថា ជាអត្ថបទធ្វើឲ្យខូចខាតកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់គេ ។

លើសពីនេះតុលាការអាចផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ទៀតក៏បាន ។

ម្យ៉ាងទៀតក្នុងករណីដែលមានការវិនិច្ឆ័យរំពឹងរំពើណាមួយដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឲ្យបិទផ្សាយសេចក្តីសំរេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយឬច្រើននិងឲ្យជនជាប់ចោទទទួលបន្ទុកចេញសោហ៊ុយទាំងអស់ដោយកម្រិតត្រឹម មួយលានរៀល (១.០០០.០០០ រៀល) យ៉ាងច្រើនបំផុត ។

មាត្រា ១១.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា។

ការប្រព្រឹត្តបទល្មើសដែលមានចែងខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

បុគ្គលរងគ្រោះដោយអំពើខាងលើ មានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅតុលាការ ។

គ្រប់ករណីទាំងអស់ តុលាការត្រូវពិនិត្យទៅលើទំនាក់ទំនងដោយផ្ទាល់រវាងអត្ថបទញុះញង់និងអំពើនោះ ។ អត្ថបទដែលមានចំណាស់លើសពីបីខែ (៣ ខែ) មិនអាចយកមកសំអាងក្នុងការចោទប្រកាន់បានឡើយ ។

មាត្រា ១២.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយឬផ្សាយបន្តនូវពត៌មានដែលបណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ ។

និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥.០០០.០០០ រៀល) ទៅដប់ប្រាំលានរៀល (១៥.០០០.០០០ រៀល) ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ ។

ក្រសួងពត៌មាននិងក្រសួងមហាផ្ទៃ មានសិទ្ធិប្រមូលយកអត្ថបទល្មើសនិងសារពត៌មានលេខចេញផ្សាយអត្ថបទល្មើសដែលចេញផ្សាយដោយសារពត៌មាននោះ ។ ក្រសួងពត៌មាន មានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួសពីសាមសិបថ្ងៃ (៣០ថ្ងៃ) ហើយបញ្ជូនសំណុំរឿងទៅតុលាការ ។

មាត្រា ១៣ .-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តការមិនពិតដែលជាការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ ។ ការផ្សាយបែបនេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ពីរលានរៀល (២.០០០.០០០ រៀល) ទៅ ដប់លានរៀល (១០.០០០.០០០ រៀល) ។

មាត្រា ១៤.-

សារពត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិជាអាទិ៍ ៖

- ពាក្យអសុរោះមិនគួរគប្បី ដូចជា អា មីង ជាដើម
- ពាក្យដែលពិពណ៌នាថាំ អំពីសកម្មភាពរួមរក្ស
- រូបគំនូរ ឬរូបថត ដែលបង្ហាញនូវ កេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងតែទិសដៅសំរាប់អប់រំចេញ
- រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរច្ឆាន ។

ការរំលោភទៅលើមាត្រានេះ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

មាត្រា ១៥.-

លើកលែងតែមានការអនុញ្ញាតពីតុលាការ សារពត៌មានពុំអាចផ្សាយដំណឹង រូបថត ឬគំនូរ ដែលអាចឲ្យអ្នកអានស្គាល់ឈ្មោះ និងអត្តសញ្ញាណ ៖

- ភាគីក្នុងរឿងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងបិតុភាព អាពាហ៍ពិពាហ៍ រឿងលែងលះប្ដីប្រពន្ធ ឬរឿងអាណាព្យាបាលលើកុមារ
- យុវជនអាយុតិចជាងដប់ប្រាំបីឆ្នាំ (១៨ ឆ្នាំ) ក្នុងរឿងវិវាទរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ
- ស្ត្រីដែលទទួលរងគ្រោះដោយអំពើរំលោភលើរាងកាយ ឬអំពើចាប់បង្ខំសេពសន្ថវៈ ។

ក្នុងករណីដែលសាមីជន ឬអ្នកអាណាព្យាបាលយល់ព្រមជាលាយលក្ខណ៍អក្សរ សារពត៌មានអាចផ្សព្វផ្សាយរឿងនេះបាន លើកលែងតែការផ្សាយនេះ នាំឲ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។

បុគ្គលណា ដែលត្រូវសារពត៌មានបំពានសិទ្ធិខាងលើនេះ មានសិទ្ធិប្ដឹងទៅតុលាការដើម្បីទាមទារជម្ងឺចិត្ត ។ ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅប្រាំលានរៀល (៥.០០០.០០០ រៀល) ។

មាត្រា ១៦.-

ដំណឹងផ្សាយពាណិជ្ជកម្ម អាចចាត់ទុកថាមានលក្ខណៈភូតកុហក បើការផ្សាយនោះ មានន័យបំផ្លើសហួសហេតុអំពីគុណភាព ឬគុណសម្បត្តិផលិតផល ឬសេវាណាមួយ បណ្ដាលឲ្យអ្នកប្រើប្រាស់មានការភ័ន្តច្រឡំអំពីគុណភាព ឬគុណសម្បត្តិនោះ ។

ការផ្សាយពាណិជ្ជកម្មរបៀបនេះត្រូវហាមឃាត់ ប៉ុន្តែសារពត៌មានដែលចុះផ្សាយដំណឹងភូតកុហកនេះ មិនមែនជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ទេ លើកលែងតែសារពត៌មាននេះ នៅតែបន្តផ្សាយដំណឹងនេះ ក្រោយពីបានទទួលការហាមប្រាមជាលាយលក្ខណ៍អក្សរពីតុលាការ ឬពីក្រសួងមានសមត្ថកិច្ចរួចហើយ ។

ផ្ទុយទៅវិញអ្នកម្ចាស់ឃោសនាពាណិជ្ជកម្ម ជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ និងចំពោះតុលាការ បើមានការប្ដឹងផ្ដល់អំពីបុគ្គល ឬសមាគមអ្នកប្រើប្រាស់ណាមួយ ដែលបានទទួលការខូចខាតប្រយោជន៍បណ្ដាលមកពីការផ្សាយពាណិជ្ជកម្មភូតកុហកនេះ ។

ការផ្សាយពាណិជ្ជកម្មភូតកុហក អាចត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅ ប្រាំលានរៀល (៥.០០០.០០០ រៀល) ។

## ជំពូកទី ៣

## ការកម្រិតកម្មសិទ្ធិ

មាត្រា ១៧.-

បុគ្គលណាក៏ដោយ ទោះជារូបវន្តបុគ្គលក្ដី ឬនីតិបុគ្គលក្ដី មិនអាចធ្វើជាម្ចាស់ ឬជាអ្នកកាន់កាប់សារព័ត៌មានជាភាសាខ្មែរលើសពីពីរ (២) ឡើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៨.-

ចំនួនសរុបទាំងអស់នៃសារព័ត៌មានជាភាសាខ្មែរដែលកាន់កាប់ដោយជនបរទេស មិនត្រូវឲ្យលើសពីម្ភៃភាគរយ (២០%) នៃចំនួនសារព័ត៌មានជាភាសាខ្មែរទាំងអស់ដែលចេញផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

សារព័ត៌មានដែលកាន់កាប់ដោយជនបរទេស ដែលបានអនុញ្ញាតឲ្យចេញផ្សាយរួចហើយមិនអាចត្រូវបិទដោយមូលហេតុថយចុះចំនួនសរុបទាំងអស់ នៃសារព័ត៌មានជាភាសាខ្មែរនោះទេ ។

## ជំពូកទី ៤

## ការតម្កល់ទុក

មាត្រា ១៩.-

និពន្ធនាយក ឬនាយកការផ្សាយ ត្រូវតម្កល់ទុកសារព័ត៌មានរាល់លេខរបស់ខ្លួនចំនួនពីរច្បាប់ (០២ ច្បាប់) នៅបណ្ណាល័យជាតិ និងប្រាំមួយច្បាប់ (០៦ ច្បាប់) ទៀតនៅក្រសួងព័ត៌មាន ។ ការតម្កល់ទុកនេះត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ ថ្ងៃ) ចំពោះការបោះពុម្ពនៅភ្នំពេញ និងសែសិបប្រាំថ្ងៃ (៤៥ ថ្ងៃ) នៅកន្លែងដទៃទៀត ដោយគិតពីកាលបរិច្ឆេទនៃការចេញផ្សាយ ។

ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិខាងលើនេះ ត្រូវផ្ដន្ទាទោសពិន័យជាអន្តរការណ៍ដោយក្រសួងព័ត៌មានជាប្រាក់ពីបីម៉ឺនរៀល (៣០.០០០ រៀល) ទៅបីសែនរៀល (៣០០.០០០ រៀល) ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២០.-**

រាល់ការប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ ។

**មាត្រា ២១.-**

បទបញ្ញត្តិទាំងឡាយដែលមានពីមុនមកហើយទាក់ទងនឹងសារព័ត៌មានត្រូវចាត់ទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ១៩៩៥ នាសម័យ
ប្រជុំលើកទី ៤ នីតិកាលទី ១ ។

ភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ១៩៩៥

ប្រធានរដ្ឋសភាស្តីទី

# ខ្លឹមសារពាក់ព័ន្ធ ក្នុងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឆ្នាំ២០១៤

## ជំពូកទី៤
## បទល្មើស

**មាត្រា ២១**.. ការភ្ជាប់ដោយខុសច្បាប់

១. ជនណាដែលធ្វើការភ្ជាប់ដោយគ្មានសិទ្ធិទៅកាន់ប្រព័ន្ធកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ (ប្រាំមួយ) ខែទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។

២. សកម្មភាពដែលមានចែងក្នុងកថាខ័ណ្ឌទី១ ដោយធ្វើឡើងក្នុងគោលបំណងទាញយកនូវទិន្នន័យ កុំព្យូទ័រ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

៣. សកម្មភាពដែលមានចែងក្នុងកថាខ័ណ្ឌទី១ និង/ឬ ទី២ ដែលត្រូវបានធ្វើឡើងដោយរំលោភ បំពានលើវិធានការសន្តិសុខ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ១២ (ដប់ពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលដល់ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ២២**.. ចារកម្មទិន្នន័យ

១. ជនណាដែលទាញយកទិន្នន័យសំរាប់ផ្ទាល់ខ្លួន ឬសម្រាប់អ្នកដទៃ ដោយគ្មានការអនុញ្ញាត ហើយទិន្ន័យនោះ មិនមែនជារបស់ខ្លួននិងត្រូវបានការពារយ៉ាងពិសេសទៅនឹងការភ្ជាប់ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

២. ទិន្ន័យដែលមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើសំដៅដល់ទិន្ន័យដែលត្រូវបានរក្សាទុកបញ្ជូនតាមបែប អេឡិកត្រូនិក ម៉ាញេទិកទំរង់ទាំងឡាយណាដែលមិនអាចមើលឃើញដោយផ្ទាល់។

**មាត្រា ២៣**.. ការស្ទាក់ចាប់ដោយខុសច្បាប់

ជនណាដែលធ្វើការស្ទាក់ចាប់ដោយគ្មានសិទ្ធិតាមមធ្យោបាយបច្ចេកទេសនៃការបញ្ជូនទិន្នន័យកុំព្យូទ័រមិនមែនជាសាធារណៈ ទៅកាន់ មកពី ឬក៏នៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយរួមមាននូវការបញ្ជូនទិន្នន័យបែប អេឡិចត្រូម៉ាញ៉េទិចចេញពីប្រព័ន្ធកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀលទៅ ១៤ ០០០ ០០០ (ដប់បួនលាន) រៀល។

**មាត្រា ២៤**.. ការជ្រៀតជ្រែកទិន្នន័យ

ជនណាដែលធ្វើការកែប្រែ ការលុប ការធ្វើអោយខូច ឬក៏ការដាក់កំហិតនូវទិន្នន័យកុំព្យូទ័រដោយគ្មានសិទ្ធិ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំ និងពិន័យប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀលដល់ ១៤ ០០០ ០០០ (ដប់បួនលាន) រៀល។

**មាត្រា ២៥**.. ការផ្ទេរទិន្នន័យដោយគ្មានការអនុញ្ញាត

ជនណាដែលផ្ទេរទិន្នន័យដោយគ្មានការអនុញ្ញាតចេញពីប្រព័ន្ធកុំព្យូទ័រ ឬដោយប្រើប្រាស់មធ្យោបាយផ្ទុកទិន្នន័យកុំព្យូទ័រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី)ឆ្នាំទៅ១២ (ដប់ពីរ) ឆ្នាំនិងពិន័យប្រាក់ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ២៦**.. ការជ្រៀតជ្រែកប្រព័ន្ធ

ជនណាដែលធ្វើសកម្មភាពដោយគ្មានសិទ្ធិ ដែលបណ្តាលអោយមានការខាតយ៉ាងធ្ងន់ធ្ងរទៅលើមុខងាររបស់ប្រព័ន្ធកុំព្យូទ័រ ដោយការបញ្ចូល ការ បញ្ជូន ការកែប្រែ ឬការធ្វើអោយខូចដល់ទិន្នន័យកុំព្យូទ័រ ឬដោយការកំហិតការភ្ជាប់ទៅកាន់ទិន្នន័យ ទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា ២៧**.. រូបអាសអាភាសកុមារ

១. ជនណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- ក. ផលិតរូបអាសអាភាសកុមារសំរាប់យកទៅចែកចាយតាមរយៈប្រពន្ធ័កុំព្យូទ័រ
- ខ. ផ្តល់ឬដាក់អោយមានរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ
- គ. ចែកចាយឬបញ្ជូនរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ
- ឃ. ទាញយកឬផ្តល់អោយអ្នកដទៃនូវរូបអាសអាភាសកុមារតាមរយៈប្រពន្ធ័កុំព្យូទ័រ
- ង. ធ្វើជាម្ចាស់រូបអាសអាភាសកុមារនៅក្នុងប្រពន្ធ័កុំព្យូទ័រឬឧបករណ៍ស្តុកទិន្នន័យ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

២. រូបអាសអាភាសកុមារដែលមានចែងក្នុងកថាខណ្ឌ័ទី១ខាងលើ រួមមានរូបអាសគ្រាមដែលអាចមើល ឃើញនឹងភ្នែកបាន៖

- ក. អនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិអារម្មណ៍ផ្លូវភេទ
- ខ. បុគ្គលម្នាក់ដែលបញ្ចេញកាយវិការដូចនិងអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិ អារម្មណ៍ផ្លូវភេទ
- គ. រូបភាពជាក់ស្តែងដែលតំណាងអោយអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តិអារម្មណ៍ ផ្លូវភេទ

**មាត្រា ២៨.**. ខ្លឹមសារនិងគេហទំព័រ

ជនណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១. តាក់តែងមាតិកាព័ត៌មានដែលធ្វើអោយអន្តរាយដល់ឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីរបស់ ព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

២. ធ្វើការផ្សព្វផ្សាយខ្លឹមសារអ្វីដែលនាំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយ ញុះញង់ដោយផ្ទាល់ អោយមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហឹង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៣. ផ្សព្វផ្សាយខ្លឹមសារឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលអោយប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាព នយោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៤. ផ្សព្វផ្សាយខ្លឹមសារឬផ្សាយបន្តព័ត៌មានមិនពិតដែលជាការជេរប្រមាថការមើលងាយដល់ ស្ថាប័នជាតិ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៥. ផ្សព្វផ្សាយខ្លឹមសារអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិជាអាទិ៍៖

ក. ព័ត៌មានដែលញុះញង់អោយមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន និងស្ថានភាពដទៃទៀត

ខ. អត្ថបទឬរូបអាសអាភាស និងរូបភាពនៃអំពើហឹង្សា

គ. ការមួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ

ឃ. រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរច្ឆាន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។

៦. តាក់តែងខ្លឹមសារគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។ ចំពោះប្រភេទនៃការគំរាមកំហែងត្រូវអនុវត្ត តាមច្បាប់និងបទប្បញ្ញត្តជាធរមាន។

**មាត្រា ២៩.**. កម្មសិទ្ធិបញ្ញា

សម្រាប់បទល្មើសដែលទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញាគឺត្រូវបានអនុវត្តទៅតាមច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលនៃព្រះរាជាណាចក្រកម្ពុជាដែលចូលជាធរមាន។

**មាត្រា ៣០.**. ការឆបោកតាមរយៈកុំព្យូទ័រ

ជនណាដែលមានចេតនាក្នុងការធ្វើអោយបាត់បង់កម្មសិទ្ធិ (property) របស់អ្នកដទៃតាមរយៈការ បញ្ចូល ការកែប្រែ ឬលុបទិន្នន័យកុំព្យូទ័រ ការរាំងនូវការភ្ជាប់ទៅកាន់ទិន្នន័យ ការជ្រៀតជ្រែកទៅលើ មុខងាររបស់ប្រព័ន្ធកុំព្យូទ័រក្នុងគោល បំណងទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សម្រាប់ខ្លួនឯង ឬក៏អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំទៅ ១២ (ដប់ពីរ)ឆ្នាំ និងពិន័យប្រាក់ពី ៦ ០០០ ០០០ (ប្រាំមួយលាន) រៀលទៅ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។

**មាត្រា ៣១.**. ការក្លែងបន្លំតាមរយៈកុំព្យូទ័រ

ជនណាដែលមានចេតនាក្នុងការបញ្ចូល ការកែប្រែឬលុបទិន្នន័យកុំព្យូទ័រ ការរាំងទៅលើការភ្ជាប់ ទៅកាន់ទិន្នន័យទាំងនោះ ដោយគ្មានសិទ្ធិ ក្នុងគោលបំណងប្រើប្រាស់សម្រាប់ផ្លូវច្បាប់ ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៧ (ប្រាំពីរ) ឆ្នាំនិងពិន័យប្រាក់ពី ៤ ០០០ ០០០ (មួយលាន) រៀលទៅ ១៤ ០០០ ០០០ (ដប់បួនលាន)រៀល។

**មាត្រា ៣២.**. ការប្រើឧបករណ៍ក្នុងផ្លូវខុស

១. ជនណាដែលធ្វើសកម្មភាពណាមួយខាងក្រោម ដោយគ្មានសិទ្ធិ៖

ក. ការផលិត ការលក់ ការធ្វើលទ្ធកម្មប្រើប្រាស់ ការនាំចូល ការចែកចាយ ឬក៏ធ្វើអោយទទួល បានតាមទម្រង់ណាក៏ដោយនូវ៖

ក.១. ឧបករណ៍រួមមានកម្មវិធីកុំព្យូទ័រដែលបង្កើតឡើងឬយកលំនាំតាមសម្រាប់គោល បំណងក្នុងការប្រព្រឹត្តិនូវរាល់បទល្មើសដែលបានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ។

ក.២. អក្សរក្រមសម្ងាត់កុំព្យូទ័រ កូដភ្ជាប់ ឬក៏ទិន្នន័យប្រហាក់ប្រហែល ដែលផ្នែកទាំង មូលឬផ្នែកណាមួយនោះមានសមត្ថភាពអាចភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័របាន ក្នុងគោលបំណងប្រព្រឹត្តិនូវរាល់បទល្មើសដែលមានចែកក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ ។

ខ. ចំពោះការកាន់កាប់ដោយគ្មានសិទ្ធិនូវរាល់ធាតុផ្សំទាំងឡាយណាដែលមានចែងក្នុងកថា ខណ្ឌ ក.១ ឬ ក.២ ខាងលើ ក្នុងគោលបំណងប្រើប្រាស់ដើម្បីប្រព្រឹត្តនូវរាល់បទល្មើសណាមួយដែល មានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ខាងលើ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំទៅ ៦ (ប្រាំមួយ) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (មួយលាន) រៀលដល់ ១២ ០០០ ០០០ (ដប់ពីរលាន)រៀល។

២.មិនត្រូវបានរាប់ចូលជាបទល្មើសខាងលើឡើយនៅពេលដែលការ ផលិត ការលក់ ការធ្វើលទ្ធកម្មប្រើ ប្រាស់ ការចែក ចាយ ឬការធ្វើអោយមាន ឬការកាន់កាប់នូវអ្វីដែលមានចែងនៅក្នុង កថាខណ្ឌទី១ ខាងលើមិនមានបំណងក្នុងការប្រព្រឹត្ត បទល្មើសដែលមានចែងក្នុងមាត្រា៥ ដល់មាត្រា១៤ ដូចជាសិទ្ធិអនុញ្ញាតក្នុងការធ្វើកោសល្យវិច្ច័យ ការធ្វើតេស្ត ឬការ ការពារប្រព័ន្ធកុំព្យូទ័រជាដើម។

**មាត្រា ៣៣**.. ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹតបទមជ្ឈឹមដែលមានចែងក្នុងមាត្រា៤២៧ (បទចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធ ប្រព្រឹត្តិ កម្មស្វ័យប្រវត្តិនៃទិន្នន័យ) មាត្រា៤២៨ (បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធ ប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ) មាត្រា៤២៩ (បទបញ្ចូល លុបបំបាត់ ឬកែប្រែដោយទុច្ចរិត នូវទិន្នន័យ) មាត្រា៤៣០ (បទចូលរួមក្នុងក្រុមប្រមូលផ្តុំ ឬក្នុងសន្ធិផ្ទិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស) នៃក្រមព្រហ្មទណ្ឌ និងមាត្រា២១(ការភ្ជាប់ដោយខុសច្បាប់) មាត្រា២២ (ចារកម្មទិន្នន័យ) មាត្រា២៣ (ការស្ទាក់ចាប់ដោយខុសច្បាប់) មាត្រា២៤ (ការជ្រៀតជ្រែកទិន្នន័យ) មាត្រា២៥ (ការផ្ទេរទិន្នន័យ ដោយគ្មានការអនុញ្ញាត) មាត្រា២៦ (ការជ្រៀតជ្រែកប្រព័ន្ធ) មាត្រា២៧ (រូបអាសអាភាសកុមារ) មាត្រា២៨ (បទល្មើសទាក់ទងនឹងខ្លឹមសារ) មាត្រា៣០ (ការឆបោកតាមរយៈកុំព្យូទ័រ) មាត្រា៣១ (ការក្លែងបន្លំតាមរយៈកុំព្យូទ័រ) មាត្រា៣២ (ការប្រើឧបករណ៍ក្នុងផ្លូវខុស) នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ។

**មាត្រា ៣៤**.. ទោសបន្ថែមអនុវត្តចំពោះបទល្មើសបច្ចេកវិទ្យា

ចំពោះបទល្មើសបច្ចេកវិទ្យាដូចមានចែងក្នុងច្បាប់នេះ ទោសបន្ថែមមួយឬច្រើនដូចខាង ក្រោមអាចត្រូវបាន ប្រកាស៖

១- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

២- ហាមឃាត់មិនអោយប្រើប្រាស់កុំព្យូទ័រសម្រាប់រយៈពេលមិនល្មើសពី៥ (ប្រាំ)ឆ្នាំ

៣- ការហាមឃាត់ចំពោះការប្រកបមុខរបរជាស្ថាពរ ឬសម្រាប់រយៈពេលមិនលើសពី៥ (ប្រាំ)ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបមុខរបរ ឬក្នុងឱកាសនៃ ការប្រកបនេះ។

៤- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមាន គោលដៅប្រព្រឹត្តបទល្មើស។

៥- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

៦- ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៧- ការរឹបអូសឧបភោគកណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបាន ប្រព្រឹត្ត។

៨- ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបល្មើសឬប្រព្រឹត្ត បទល្មើសជាស្ថាពរឬ សម្រាប់រយៈពេលមិនល្មើសពី៥(ប្រាំ)ឆ្នាំ។

៩- ការហាមឃាត់ការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើសឬប្រព្រឹត្តបទល្មើសជាស្ថាពរឬ សម្រាប់រយៈពេលមិនល្មើសពី៥(ប្រាំ)ឆ្នាំ។

១០- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១១- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។

១២- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៣- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់ រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

**មាត្រា ៣៥**.. ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

នីតិបុគ្គលដែលបានចូលរួមប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាដូចដែលមានចែងក្នុងមាត្រា២១ ដល់មាត្រា៣២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី .............រៀលដល់ .....................រៀល និងទទួលទោសបន្ថែមមួយ ឬច្រើនដូចខាងក្រោមនេះ៖

១- ការរំលាយចោល។

២- ការដាក់អោយស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំឬប្រព្រឹត្តបទល្មើស។

៦- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជនឬដែលបានប្រើប្រាស់ដោយសាធារណជន។

៧- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើសឬដែលមានគោលដៅ សម្រាប់ប្រព្រឹត្តបទល្មើស។

៨- ការរឹបអូសនូវវត្ថុឬមូលនិធិដែលជាទីដៅនៃបទល្មើស។

៩- ការរឹបអូសនូវឧបភោគកណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

១០- ការបិទផ្សាយនៃសេចក្តីសម្រេចផ្តន្ទាទោស។

១១- ការផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានឬផ្សាយតាមមធ្យោបាយគមនាគមន៍ សោតទស្សន៍។